
វាសនាគឺនៃជីវិត
www.lovekhmer.com
Love ខ្មែរ
www.lovekhmer.com
ផ្សាយចេញពីបណ្ណាគារបន្ទាយស្រី

# វគ្គទី១
# ជីវិតកម្រិតទឹកប្រាក់

កង់រាជរថនៃព្រះសុរិយាធ្វើគោចរនៅលើផ្លូវនភាល័យ កំពុងតែបោះជំហានសន្សឹមៗ បំភាយកម្តៅបន្តិចម្តងៗ មកលើភពផែនដីឲ្យហួតហែងក្រៀមក្រោះអស់សម្រស់រុក្ខជាតិនានានៅជុំវិញជងផ្លូវ ។

នៅក្នុងគេហដ្ឋានមួយដែលតូចល្មមប្រក់ដំបូលទៅដោយបន្ទះសង្កសី មានន័យថាជាទីលំនៅសម្រាប់ជនក្រីក្ររស់នៅ។ គ្រួសារមួយកំពុងតែជជែកគ្នាតិចៗ បើយើងផ្ទៀងសោតាស្តាប់ទៅ យើងនឹងឮសូរនូវសំឡេងរបស់មាតានៃបុរសម្នាក់ ដែលឱនត្រចៀកប្រុងស្តាប់ហេតុផលរបស់ម្តាយ ។

- សុជាតិកូន...! កូនត្រូវតែរៀបការជាមួយនឹងក្មួយស្រីបុប្ផ ដែលជាកូនរបស់លោកសក្តិ៣នោះ មិនអាចប្រកែកបានទេ !

យុវកំលោះដែលមានឈ្មោះថាសុជាតិមើលទៅមុខមាតាបន្តិចមុននឹងឆ្លើយតបទៅវិញ :

- ទេម៉ាក់ ! ទឹកប្រាក់១លានកូនអាចមានលទ្ធភាពរកសងគេបានតើ ! សូមម៉ាក់កុំភ័យអី ហើយកូនក៏មិនចង់រៀបការដោយសារតែរឿងនេះដែរ កូនសន្យាថានឹងរកប្រាក់មកសងគេវិញក្នុងរយៈពេល

២ ខែខាងមុខនេះ ហើយកូននឹងយកប្រាក់ទាំងនោះមកប្រគល់ជូនម៉ាក់ ដើម្បីយកទៅសងគេចុះ ! ចំណែកការប្រាក់ទាំងប៉ុន្មានកូននឹងបំពេញតាមតម្រូវការរបស់គេបានទាំងអស់ !

- គេមិនទាមទារប្រាក់ទាំងនោះវិញទេ ម៉ាក់ប្រាប់កូននេះគឺគ្រាន់តែចង់បញ្ជាក់កូនថាគេជាអ្នកមានគុណលើយើង ដូច្នេះកូនត្រូវតែរៀបការជាមួយនឹងបុប្ផា កូនស្រីលោកវិបុលនិងអ្នកស្រីសាវីជាដាច់ខាត កូនគួរតែដឹងហើយថាការដែលគេហ៊ានលើកកូនស្រីគេមកឲ្យកូននោះ គាត់ច្បាស់ជាជឿជាក់ទៅលើសមត្ថភាពរបស់កូនហើយ កូនមិនត្រូវធ្វើឲ្យក្តីសង្ឃឹមរបស់ម៉ាក់ រលាយសូន្យទៅវិញនោះទេ !

- តែម៉ាក់គួរយល់ហើយ បើកូនក្រមុំរបស់គេល្អត្រឹមត្រូវនោះគេមិនដែលលើកយកមកឲ្យយើងទទេៗនោះទេ មុខមាត់របៀបគេនេះដែរស្មានថាគេខ្លាចសល់កូនក្រមុំឬ? នេះមកពីវាមិនកើតបានជាប្រថុយដើរលើកឲ្យគេឯងនោះ ! ការលើកកូនក្រមុំឲ្យនេះ ម៉ាក់ស្មានថាមានតម្លៃណាស់ទៅឬ គឺថោកទាបជាទីបំផុត !

- មកពីកូនមានការងារល្អហ្នឹងណា៎ តែបើតាមម៉ាក់សង្កេតមើលបុប្ផានាងជាក្មេងស្រីម្នាក់ត្រឹមត្រូវណាស់ សុភាពដូចសំពត់ក្នុងផ្នត់អ៊ីចឹង !

- សំពត់ក្នុងផ្នត់ជួនកាលវាល្អតែខាងក្រៅទេ ឯខាងក្នុងវិញមានកន្លាតចូលពងផងក៏មិនដឹង ! ម៉ាក់មើលឃើញថានៅផ្ទះសុភាព

រាបសា តើម៉ាក់មានដែលបានតាមដានគេគ្រប់ជំហានដែរទេ ?

- ម៉ាក់ដូចជាចាញ់ចំណេះនឹងពន្យល់ឯងហើយ តែឯងត្រូវដឹងថាម៉ាក់បានយល់ព្រមភ្ជាប់ពាក្យជាមួយនឹងគេរួចទៅហើយ មិនអាចនឹងក្រឡាស់សម្តីវិញបានទេ !

- ស្រេចតែម៉ាក់ទេ តែថ្ងៃស្អែកនេះកូនត្រូវត្រឡប់ទៅភ្នំពេញវិញ ព្រោះដល់ពេលដែលគេហៅកូនចូលធ្វើការហើយម៉ាក់ !

- ទៅក៏ទៅចុះ តែដល់ពេលកំណត់កូនត្រូវតែត្រឡប់មករៀបការវិញជាដាច់ខាត !

- បើម៉ាក់នៅតែបង្ខំកូនយ៉ាងនេះ កូនប្រាកដជាគ្មានមុខមកជាន់លើទឹកដីសៀមរាបនេះវិញទៀតទេ !

និយាយចប់គេទាញកង់កញ្ចាស់របស់គេជិះចេញទៅបាត់ អ្នកសាយយុតបានត្រឹមតែគ្រវីក្បាល តាមមើលដំណើរបុត្រដោយក្តីអស់សង្ឃឹម តែប៉ុណ្ណោះ ។

ស្អែកឡើង សុជាតិត្រូវធ្វើដំណើរត្រឡប់មកបំពេញការងារឯទីក្រុងភ្នំពេញវិញ អ្នកប្រុសយើងត្រូវបានរាជការចាត់តាំងឲ្យចូលមកបម្រើការងារនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ដោយគេបានជួលផ្ទះស្នាក់នៅក្បែរស្តាតអូឡាំពិក ។ មករស់នៅក្នុងទីក្រុងភ្នំពេញដោយសារតែគ្មានលុយសម្រាប់ស្នាក់នៅមួយរយៈពេលខ្លី គេបានទៅខ្ចីលុយពីមិត្តភក្តិម្នាក់ឈ្មោះវិសាលដើម្បីយកមកទិញសម្ភារៈប្រើប្រាស់ទម្រាំ

ដល់ថ្ងៃបើកប្រាក់ខែចាំទូទាត់សងគេវិញ ព្រោះអ្នកត្រូវបើកមើលអ្នកជំងឺក្រៅម៉ោង គ្រាន់នឹងបានកម្រៃខ្លះទប់ទល់នឹងជីវភាព ។

ពេលវេលាចេះតែកន្លងផុតទៅ សុជាតិអ្នកអាចរកប្រាក់បានគ្រាន់បើខ្លះហើយ គេក៏រំដោះសងទៅវិសាលវិញរហូតទាល់តែគ្រប់ចំនួនទើបដល់ពេលបើកប្រាក់ខែ នៅសេសសល់ខ្លះអ្នកផ្ញើទៅឲ្យម្ដាយនៅឯស្រុកដើម្បីចាយវាយនិងសងបំណុលលោកវិបុលវិញ ។

៣ខែបានកន្លងផុតទៅ អ្នកកំលោះសន្សំប្រាក់ទិញបានម៉ូតូហុងដា១គ្រឿងសម្រាប់ជិះទៅធ្វើការ កុំឲ្យពិបាកជិះស៊ីក្លូនិងដើររោយជើងដូចកាលពីលើកមុនទៀត ។

ថ្ងៃមួយពេលដែលអ្នកប្រុសកំពុងតែមានការស្មុគស្មាញពីរឿងអ្នកជំងឺដែលចេះតែមានជំងឺប្លែកៗពិបាកនឹងព្យាបាលនៅកន្លែងធ្វើការនោះស្រាប់តែមានសំបុត្រមួយបានផ្ញើមកដល់ដៃអ្នក ដោយរវល់ពេកគេក៏ញាត់ចូលទៅក្នុងហោប៉ៅរហូតដល់ពេលបរិភោគបាយរួច បានអ្នកកំលោះចាប់កូនលិខិតនោះមកអាន !

## ចំពោះសុជាតិកូនសម្លាញ់របស់ម៉ាក់ !

សុជាតិកូនសម្លាញ់ម៉ាក់ បើកូនចាត់ទុកថា ម៉ាក់ជាអ្នកមានគុណរបស់កូននោះ គឺកូនត្រូវត្រឡប់មករៀបការវិញណាំកូន ព្រោះលោកវិបុលនិងលោកស្រីសាវីកំពុងតែរង់ចាំកូនខ្លាំងណាស់ ចំណែកប្រាក់ដែលកូនផ្ញើមកសងនោះគេមិនទទួលយកទេ ! សំខាន់ឲ្យតែកូន

វិលមករៀបការវិញគឺមិនពិបាកអ្វីទាំងអស់ ពេលដែលរៀបការរួចហើយ លោកវិបុលសុំកូនផ្លាស់មកធ្វើការនៅខេត្តសៀមរាបវិញ បើកូនមិនវិលមកវិញទេគេនឹងដេវ្យលត្រូះដល់ម៉ាក់ជាមិនខានឡើយ ម៉ាក់សូមអង្វរចិត្តកូនទៅចុះធ្វើម្តេចបានជាជ្រុលយ៉ាងនេះទៅហើយនោះ !

ពីម្តាយកូនរបស់

សាយយុត

វត្តមាននៃលិខិតនេះមិនបានធ្វើឲ្យសុជាតិរីករាយឡើយ អ្នកប្រុសហែកក្រដាសនោះបោះចោលទៅក្រៅជាប្រញាប់ អ្នកដូចជាឆ្ងល់នឹងមាតាណាស់ ហេតុអីក៏គាត់មិនចេះពិចារណាអ្វីបន្តិចសោះអីចឹង ? ឬមួយក៏គាត់ថារៀបអាពាហ៍ពិពាហ៍នោះ វាគ្មានឥទ្ធិពលសម្រាប់អនាគតទេ ចុះបើភាគីម្ខាងគ្មានការពេញចិត្តទេនោះ តើឯណាទៅដែលហៅថាសុភមង្គលក្នុងជីវិត ? ដាច់ខាតអ្នកត្រូវតែស្វែងរកនារីណាម្នាក់ដែលមានភាពបរិសុទ្ធមកធ្វើជាសម្លាញ់១០០ឆ្នាំ ទោះជានារីនោះក្រខ្សត់យ៉ាងណាក៏ដោយ ។ ការតប់ប្រមល់ខ្វល់គំនិតកើតមាននៅក្នុងអារម្មណ៍របស់របស់អ្នកកំលោះធ្វើឲ្យគេមានទឹកមុខស្រពោនជាប់ក្នុងរយៈពេលដែលបានទទួលសំបុត្រនេះ ។

ថ្ងៃនេះ... ក្រោយពេលដែលធ្វើការវះកាត់ស្ត្រីដុះពោះម្នាក់រួចមក សុជាតិចុះមកឈរលេងនៅមុខសួនច្បារនៃមន្ទីរពេទ្យដោយក្នុងអារម្មណ៍របស់គេសែនច្របូកច្របល់រកទីបំផុតគ្មាន...កំពុងតែបណ្តែត

ភាពស្រមើស្រមៃ ស្រាប់តែសំឡេងមួយបានមកដាស់សតិអ្នកឲ្យបំបែរចេញពីការគិតមួយរំពេច :

- សុជាតិ ! ឯងឈរធ្វើអីនៅកន្លែងហ្នឹង ?

គេនិយាយទាំងដើរមករកមិត្តកាន់ស្មាជាប់ !

- តប់ប្រមល់ខ្លាំងពេក ឯងទៅណាដែរហ្នឹងវិសាល ?

- គ្នាមករកដកធ្មេញតែគ្រូពេទ្យមិននៅ !

- ថ្ងៃសុក្រនេះគេមិនព្យាបាលទេ ទៅអង្គុយលេងលើបង់ជាមួយនឹងគ្នាសិនទៅ គ្នាចង់ពិគ្រោះជាមួយឯងបន្តិចណាំ !

វិសាលមើលទៅមុខមិត្តបន្តិចទើបសួរ :

- ថ្ងៃនេះឯងទំនេរច្រើនណាស់មែនទេ ?

- មិនទំនេរទេ ទើបតែវះដុំពោះស្ត្រីម្នាក់ហើយមុននេះបន្តិចទើបចុះមកឈរលេងទៅណាំ !

- សុជាតិឯងឥឡូវដូចជាស្រពាប់ស្រពោនម្ល៉េះ ឯងមានរឿងអីមែនទេ ?

- មនុស្សដូចជាគ្នានេះមិនដែលថាមិនចេះមានរឿងនោះទេ ! បញ្ហាជីវិតសម្រាប់ដោះស្រាយមានមិនចេះចប់ !

- រឿងស្អីទៀតហើយ ប្រាប់គ្នាមកមើល៍ក្រែងលោអាចជួយដោះស្រាយឯងបានខ្លះណាំ !

- គឺជារឿងផ្ទាល់ខ្លួន ម៉ាក់គ្នាបានបង្ខំឲ្យគ្នារៀបការជាមួយ

www.lovekhmer.com

នឹងនារីម្នាក់ ដែលគ្នាមិនពេញចិត្តទាល់តែសោះ !

- វាដូចតែគ្នាដែរហ្នឹង ! តែវាមិនមែនបង្ខំឲ្យរៀបការជាមួយនារីណានោះទេ !

- បើអ៊ីចឹងវិសាលឯងស្រួលជាងគ្នាទៅវិញទេ !

- មិនជាងាយប៉ុន្មានឡើយសុជាតិ ប៉ាគ្នាតែគាត់និយាយយ៉ាងម៉េចគឺអ៊ីចឹងហើយ គ្នាវាគ្មានបញ្ហាទេ តែអាណិតអាមលព្រោះនាងជឿជាក់មកលើគ្នាថា ស្មោះតែនាងមួយទៅហើយ បើដឹងថាប៉ាគ្នាមិនពេញចិត្តអ៊ីចឹងមិនដឹងជានាងពិបាកចិត្តយ៉ាងណាទេ !

- និយាយអ៊ីចឹង ឥឡូវនេះនិមលទៅណាហើយ គ្នាដូចជាមិនដែលឃើញនាងអ៊ីចឹង ?

- ផ្លាស់ទៅនៅទួលគោកវិញហើយ សុជាតិអ្ហាំ គ្នាគិតបបួលឯងទៅ... ( គេឱនខ្សឹបដាក់ត្រចៀកមិត្ត )

- មិនហ៊ានទេវិសាល គ្នាចេះតែញញើតឯងដឹងទេកន្លែងហ្នឹងជាសំបុកមេរោគចម្លងណាំ ! គ្នាមិនរវល់ទេសម្លាញ់ !

- អ្ហេ៎ តែមីងមេបនហ្នឹងបាននិយាយប្រាប់គ្នាថា ថ្មីស្រឡាងណាំសម្លាញ់ !

- គ្នាមិនជឿទេ ស្រីដែលថ្មីស្រឡាងនៅកន្លែងបន តើឯងជឿដែរឬ ? យ៉ាងអន់ណាស់ក៏៤-៥ទឹករួចមកហើយដែរ ឯងជឿគ្នាទៅកុំទម្លាប់អារឿងមិនល្អនោះ !

- គ្នាឃើញសុជាតិឯងដូចជាពិបាកពេក ទើបបបួលឲ្យទៅកម្សាន្តសប្បាយម្តងហ្នឹងណា !

- ឯងចូលកន្លែងហ្នឹងមិនខ្លាចអាប់មុខអាប់មាត់ទេឬ ?

- គេមិនមែនបើកចំហឯណា គឺជាកន្លែងលួចលាក់ទេ ណ្ហើយបើមិនទៅកន្លែងហ្នឹងទេក៏ហីទៅចុះ ថ្ងៃនេះគ្នាបបួលឯងទៅញ៉ាំអីនៅហាងម្តងបានទេ ?

អ្នកកំលោះងក់ក្បាលជំនួសចម្លើយ !

ម៉ោងប្រហែលជា៧យប់ទៅហើយ វិសាលបើករថយន្តមកដល់ផ្ទះរបស់មិត្តគេ ចតរថយន្តស្រួលបួលហើយក៏ដើរចូលទៅ សុជាតិកំពុងអង្គុយធ្វើមុខស្មើរកលើកៅអីយ៉ាងកម្សត់ !

- តោះ សុជាតិ... រួចចុះឯណាអ្នកជំងឺទៅណាអស់ហើយ ?

- គ្នាឈប់ទទួលហើយ !

- ម៉េចអ៊ីចឹងទៅវិញ ? បែបនៅសល់លុយច្រើនពេកទេដឹង !

- មិនមែនទេវិសាល តែវាពិបាកពេកទៅធ្វើការបាត់ៗគ្មានអ្នកណានៅមើលការខុសត្រូវសោះ !

- ស្រេចតែឯងគិតទេរឿងនេះ ឆាប់ស្លៀកពាក់មកកុំអង្គុយធ្វើមុខមើលតែតាប៉ែដូរផ្ទួមបែបនេះមិនល្អទេ !

សុជាតិខ្ជិលប្រកែកច្រើន អ្នកចូលទៅផ្លាស់សម្លៀកបំពាក់រួច **ចេញដើរលេងកម្សាន្តជាមួយនឹងវិសាល** លាងអារម្មណ៍ឲ្យវាបានជ្រះ

ស្រឡះនៅក្នុងចិត្តកុំឲ្យស្មុគស្មាញពេក ។

ស្បៃរាត្រីបានគ្របដណ្តប់មកលើវិសាលភាពទីកដីក្រុងភ្នំពេញ មានរស្មីភ្លឺត្រចះមិនខុសពីពេលថ្ងៃទេ ដោយសារតែអំពូលភ្លើងគ្រប់ពណ៌ចាំងចោលរស្មីដ៏ស្រទន់មកលើទីក្រុងទាំងមូល ។ ដូងព្រះចន្ទ្រារះមូលក្រឡង់នៅលើព្វជនភាល័យ កំពុងចោលឥទ្ធិពលនៃលំអងអន្ទិកាបានឱបក្រសោបផែនភពទាំងមូល ឲ្យរីកស្រស់បំព្រងនាពេលរាត្រី ។

ផ្ទាំងទស្សនីយភាពទាំងនេះ គឺជាខ្សែចក្ខុរបស់កញ្ញាមួយរូបដែលកំពង់ងើបភក្ត្រា សម្លឹងទៅលើវេហាស៍យ៉ាងជក់ចិត្តជិតអារម្មណ៍ ផ្គួបផ្សំទៅដោយទឹកមុខស្រពោនដែលដក់ជាប់នូវកង្វល់យ៉ាងប្រាកដ ។

ស្រីល្អមានសម្លៀកបំពាក់ដូចទេពធីតាច្បុតចុះមកពីឋានត្រៃ-ត្រិង្សអង្គុយលើពូក ដែលមានកម្រាលសភ្លឹងមិនសមនឹងមនោសញ្ចេត-នាសញ្ចប់សញ្ចឹងអីចឹងសោះ ។ សម្រិបទ្វាររបើកឡើងបានដាស់នូវអារម្មណ៍របស់ស្រីដែលកំពុងតែស្លុងនោះ ឲ្យងាកមកពិភពស្ទរយ៉ាងរហ័ស !

មនុស្សដែលបើកទ្វារចូលមក គឺជាស្ត្រីម្នាក់ពាក់កណ្តាលវ័យមានភក្ត្រាស្រស់ញញឹម ស្ថិតក្នុងសម្លៀកបំពាក់ទាន់សម័យបំផុត បោះជំហានចូលមករកយុវនារីយើង ជាមួយនឹងផ្កាញញឹមវាចាយ៉ាងទន់ភ្លន់មួយៗថា :

- ម៉ូលីយ៉ាកូយ ថ្មើរណោះទៅហើយកូយមិនទាន់គេងទេឬ ?

- ចាសនៅទេមីង ថ្ងៃនេះអ្នកមីងឆាប់អញ្ជើញមកម្ល៉េះ ?

- ម៉ូលីយ៉ា ( គាត់ដាក់ខ្លួនអង្គុយក្បែរស្រស់ស្រី ) មីងមានរឿងមួយចង់ពឹងក្មួយបន្តិច !

- មានរឿងអីដែរទៅ សូមអ្នកមីងមានប្រសាសន៍មកចុះ.. ទោះជាកិច្ចការនោះលំបាកយ៉ាងណាក៏ដោយ ក៏ក្មួយអាចជួយអ្នកមីងបានដែរ ព្រោះគុណអ្នកមីងចំពោះក្មួយវាមានច្រើនលើសលប់ណាស់ មួយជីវិតនេះខ្ញុំមិនដឹងជាបានអ្វីយកមកសងគុណអ្នកមីងវិញទេ !

- ម៉ូលីយ៉ា ក្មួយកុំពោលពាក្យអីចឹង រាល់ថ្ងៃនេះមីងតែងតែចាត់ទុកក្មួយដូចជាកូនមីងបង្កើតអីចឹង ក្មួយមិនត្រូវគិតគុណស្រ័យអ្វីទៀតទេ យប់នេះមីងឲ្យក្មួយជួយទទួលភ្ញៀវនៅក្នុងភោជនីយដ្ឋានក្រុមហ៊ុនមីងបាន១យប់ ព្រោះអ្នកដែលទទួលភ្ញៀវរាល់ថ្ងៃនោះបានឈឺបាត់ទៅហើយ ! មីងមិនមែនឲ្យក្មួយទៅបម្រើភ្ញៀវទេ គឺគ្រាន់តែជួយឈរទទួលភ្ញៀវប៉ុណ្ណោះ !

- ចាស មិនអីទេអ្នកមីង ទោះជាបម្រើភ្ញៀវផង ក៏ខ្ញុំអាចធ្វើបានដែរ !

- តែ មីងមិនឲ្យឯងទៅបម្រើភ្ញៀវនាំតែគេមើលងាយទេ ! ក្មួយប្រញាប់រៀបចំខ្លួនទៅ មីងនៅចាំខាងក្រោមណា !

- ចាសអ្នកមីង !

**...ក្រោយពីរស្សៀកពាក់ហើយ** ..ម៉ូលីយ៉ាស្រីតូចចុះមកខាងក្រោម

ជាបន្ទាន់ តែភាពស្រពាប់ស្រពោននៅតែមិនអាចរលុបចេញពីវង្វង់ភ័ក្ត្ររបស់នាងដដែល តើនាងខ្វាយខ្វល់ពីរឿងអ្វីដែរទៅ ?

អ្នកស្រីគន្ធារហ័សបញ្ជារថយន្ត ទៅកាន់ភោជនីយដ្ឋានរបស់គាត់ ដែលមានភ្លេងប្រគំរណ្តំចិត្តស្រីក្រមុំឲ្យព្រឺព្រួច នេះបើកុំតែអ្នកស្រីគន្ធាជួយសង្គ្រោះនាង ម្ល៉េះនាងមិនដឹងក្លាយទៅជាយ៉ាងណាហើយទេ ប្រហែលជាស្លាប់ឬក៏ជា...! ស្រស់ស្រីនាងតែងតែគិតថានឹងសងគុណដល់គាត់វិញនៅថ្ងៃណាមួយមិនខាន ឲ្យសមនឹងគុណបំណាច់នេះទោះជាការងារនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ សំខាន់ឲ្យតែជីវិតរបស់នាងរស់នៅមានសេរីភាព គេចផុតពីក្រញាំគាបសង្កត់បង្ខំចិត្តដ៏ក្រពុំបរិសុទ្ធធ្លាក់ចូលក្នុងភក់ជ្រាំស្អុយកេរ្តិ៍ឈ្មោះអស់មួយជីវិតនោះ គឺបានណាស់ទៅហើយ ។

រថយន្តបញ្ឈប់ង៉ក់ បទភ្លេងកាន់តែកញ្ជ្រោលឮពេញត្រចៀកម៉ូលីយ៉ា ស្រីតូចចុះដើរតាមអ្នកស្រីគន្ធា កែវល្អៀនស្ទើរតែលើកជើងមិនចង់រួច ព្រោះកែវភ្នែករបស់គេគ្រប់គ្នាបានផ្តោតមកលើនាងជាប់ ។

- ម៉ូលីយ៉ា ក្មួយចូលក្នុងបន្ទប់នេះសិនទៅ !

- ចុះក្រែងអ្នកមីងឲ្យខ្ញុំមកទទួលភ្ញៀវឬ ?

- ចាំបន្តិចទៀតសិន ភ្ញៀវថ្មើរនេះមិនទាន់មានច្រើនទេ !

ស្រស់ស្រីនៅតែមិនទាន់អស់ចិត្តទៀត តែស្រីតូចមិនហ៊ានប្រកែកក៏ចូលទៅតាមគាត់ គឺជាបន្ទប់តូចល្មមមានតែគ្រែ ១ កម្រាល

ពូកពណ៌កុលាបច្រាលនឹងពន្លឺភ្លើងក្រហមព្រិល១ ទិដ្ឋភាពអស់ទាំងនេះធ្វើឲ្យម៉ូលីយ៉ាអស់សង្ឃឹមរលីង នាងបម្រុងនឹងច្រានទ្វារចេញមកក្រៅវិញ តែបន្ទប់ត្រូវជាប់សោដោយស្នាដៃអ្នកស្រីចាក់ពីខាងក្រៅជាប់បាត់ទៅហើយ ។ មាណវីចាប់ផ្ដើមភិតភ័យបុកពោះមួយរំពេច តើគាត់យកមនាងមកដាក់នៅទីនេះធ្វើអ្វីដែរទៅ ? ហេតុអ្វីក៏នៅក្នុងភោជនីយដ្ឋាននេះចាំបាច់មានបន្ទប់សម្រាកអ៊ីចឹង ? ទាំងនេះក៏ជាចម្ងល់មួយសម្រាប់ស្រស់ស្រីម៉ូលីយ៉ាដែរ ធីតានាងត្រដាក់ខ្លួនស្រើបអង្គុយលើពូកទាំងក្ដីអស់សង្ឃឹម ។ បើយើងក្រឡេកមើលមកកំលោះទាំងពីរវិសាល ហើយនិងសុជាតិវិញម្ដង គេអង្គុយនៅតុមួយដាច់ពីគេបន្តិចដែលមានពន្លឺមិនសូវភ្លឺច្បាស់ទេ តែយើងអាចសម្គាល់មើលបានច្បាស់ថាគេទាំងពីរកំពុងតែលើកកែវស្រាអកបន្តិចម្ដង១។ សុជាតិមិនសូវចេះញ៉ាំស្រាឡើយ ទោះជានៅប្រទេសបារាំងដែលអ្នកធ្លាប់បានទៅសិក្សា មានអាកាសធាតុត្រជាក់យ៉ាងណាក៏ដោយ នៅពេលនេះវារុកកួនពេញខួរក្បាលរបស់អ្នកចង់ឲ្យសាកថា អ្វីទៅដែលជារសជាតិសុរានោះ ? ជាតិស្រាបានចូលជ្រាបមកក្នុងពោះរបស់អ្នកប្រុសយើងយ៉ាងច្រើន ទុក្ខកង្វល់ក៏បានរសាយចេញពីខួរក្បាលរបស់អ្នកបន្តិចម្ដង១ជំនួសវិញដោយនឹកឃើញតែការសប្បាយម៉្យាងប៉ុណ្ណោះ ក្នុងភាពជាយុវវ័យគ្មាននរណាម្នាក់ខ្វះសេចក្ដីភ្លើតភ្លើននោះទេ គ្រាន់តែអ្នកខ្លះទប់បាន **អ្នកខ្លះទប់មិនបានតែប៉ុណ្ណោះ** ។

វិសាលមិនមានវាចាអ្វីទាំងអស់ លោកស្រីក៏បន្តទៀត :

- លោកប្អូនគួរតែកម្សាន្តម្តងទៅ ស្រីមានសម្រស់ល្អផ្តាច់គេ ពិតជានៅបរិសុទ្ធល្អណាស់ បងយល់ថាប្អូនទើបនឹងមកហាងរបស់បង នេះជាលើកដំបូង ទើបបងសម្រាំងទុកយ៉ាងពិសេសជូនហ្នឹងណាំ !

សុជាតិសួរកាត់ប្រយោគអ្នកស្រីគន្ធា :

- អ្នកបង ខ្ញុំសូមសួរដូចជាឆោតទៅចុះ អ្នកបងនិយាយអំពីអ្វីហ្នឹង ? កន្លែងអ្នកបងនេះមានកន្លែងសម្ងាត់មែនទេ ?

អ្នកស្រីញញឹមបន្តិចទើបតបទៅវិញ :

- ចាសពិតមែនណាស់ បងមើលទៅឃើញលោកប្អូនដូចជាតប់ប្រមល់ខ្លាំងពេកបានជាមកជម្រាបដំណឹងនេះហ្នឹងណាំ ! ចំណែកគេគ្រប់គ្នាវិញបងមិនបានប្រាប់ទេ ព្រោះគេធ្លាប់បានដឹងរួចអស់ទៅហើយ និយាយប្រាប់តាមត្រង់ទៅចុះ តែសូមកុំនិយាយបន្តទៅទៀតអី បងប្រាប់លោកប្អូនទៅចុះដោយសារតែលោកប្អូនវិសាលធ្លាប់មកលេងនៅកន្លែងនេះគឺពិតជាមានបើកបនប្រាកដមែន តែស្រី១សុទ្ធតែថ្មីស្រឡាង បានតែ១អាទិត្យត្រូវបញ្ជូនទៅលក់នៅកន្លែងផ្សេងហើយ !

- អ្នកបងធ្វើយ៉ាងនេះខុសច្បាប់ខ្លាំងណាស់ !

- ខុសមែន តែជារបររកស៊ី លោកប្អូនរវល់តែគិតខុសច្បាប់យ៉ាងនេះ ច្បាស់ជារកប្រាក់មិនបានទាន់សម័យនឹងគេទេ !

- សាកម្តងទៅសុជាតិ គ្នាឃើញឯងដូចជាខ្វះភាពរីករាយនៅ

ក្នុងខ្លួនណាស់ !

- មែនហើយលោកប្អូន !

កំលោះដុកទ័រយើងមិននិយាយទេ គេគ្រាន់តែញញឹមហើយងក់ក្បាលមួយៗ ! លោកស្រីគន្ធាត្រេកអរណាស់ គាត់ក្រោកឡើងហើយនិយាយថា :

- តែថ្លៃបន្តិចហើយណាំលោកប្អូន !

- ប៉ុន្មានក៏ដោយស្រេចតែលើបងចុះ ឲ្យតែបរិសុទ្ធ !

- បងមិនកុហកទេ គឺបន្ទប់លេខ៦និងលេខ៣ លោកប្អូនទាំងពីរចូលបន្ទប់មួយណាក៏បានដែរ !

សុជាតិនិងវិសាលមិនមាត់ទេ គេទាំងពីរងើបចេញពីតុហើយដើរទៅខាងក្រោយ វិសាលខ្សឹបដាក់ត្រចៀកសុជាតិបន្តិច គេក៏បែកគ្នាដោយវិសាលចូលទៅបន្ទប់លេខ៣ ចំណែកសុជាតិចូលទៅបន្ទប់លេខ៦ ។ អ្នកប្រុសឈោងដៃចាក់សោទាំងស្ទាក់ស្ទើរក្នុងចិត្ត តែគេប្រកាន់ខ្ជាប់នូវគំនិតប្រពៃណីមួយដែលយើងមិនអាចស្មានដល់ឡើយ ! ទ្វាររបើកខ្វាក អ្នកប្រុសហាក់ដូចជាភាន់ភាំងបន្តិច ព្រោះយុវនារីម្នាក់ដែលមានសម្ផស្សត្រកាលដូចជាបុប្ផាក្រពុំក្នុងឧទ្យាន កំពុងតែគេងយំសសឹកនទៀលពេញពូក នាងសម្លឹងមើលមកអ្នកយ៉ាងភ្ញាក់ផ្អើល !

- ហេតុអ្វីបានជាអ្នកឯងហ៊ានមកទីនេះ ?

សុជាតិមិនស្តីទេ គេទាញគន្លឹះទ្វារបិទជិត មាណវីភ័យខ្លាំង

ណាស់ ចេះតែគេចចេញពីសុជាតិបុរសដែលនាងពុំធ្លាប់ស្គាល់សោះ គេដើរតាមនាងដល់ជញ្ជាំង ចាប់ស្មានាងទាំងពីរជាប់ហើយនិយាយថា :

- ហេតុអីក៏នាងគេចអីចឹង នាងមិនដឹងថាទីនេះជាកន្លែងអីទេឬ ?

- ទេ លែងខ្ញុំ... អ្នកឯងមកពីណាធុំស្រាផង ខ្ញុំស្រែកឥឡូវហើយ !

- មកពីណាអ្ហេ្ន ? គឺមកសប្បាយជាមួយនឹងនាងហ្នឹងណាំ.. ឆាប់ឡើងទៅលើពូកភ្លាមទៅ !

- ទេ ! ទេ ! អ្នកមីង !

ស្រស់ស្រីស្រែកសុជាតិខ្ទប់មាត់ជាប់ គេសម្លឹងស្រីមួយសន្ទុះទើបច្រាននាងឲ្យដួលទៅលើពូក ។ ម៉ូលីយ៉ាប្រឹងរើអស់ទំហឹង តែមិនឈ្នះបុរសនេះបានទេ អស់សង្ឃឹមរលីងស្រីបានតែសម្រក់ទឹកភ្នែកតែប៉ុណ្ណោះ. យល់ភាពពិតនិងជឿជាក់ថានាងពិតជានៅក្រមុំមែន !

- សូមនាងកុំងើបទៅណាឲ្យសោះ គេងវិញទៅ ខ្ញុំមិនធ្វើបាបនាងទេ តែខ្ញុំត្រូវការចង់ដឹងការពិតមួយអំពីនាង !

- លោកជាអ្នកណាហើយចូលមកកន្លែងនេះធ្វើអីដែរ ?

សុជាតិមិនឆ្លើយនឹងសំណួររបស់នាងទេ គេសួរត្រឡប់ទៅវិញថា :

- ចុះនាងយ៉ាងណាដែរបានជាមកទីនេះអីចឹង ?

- ទីនេះជាកន្លែងអ្វីដែរទៅ ?

- ទីនេះជាបនល្ងចលាក់ដែលខ្ញុំទើបតែនឹងដឹងនាងមិនដឹងទេឬ ?

សម្ដីមួយឃ្លា ពិតជាដាស់សតិអារម្មណ៍នាងឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង កញ្ញាបើកភ្នែកធំៗសម្លឹងគេចំ ទាំងស្មារតីភិតភ័យហួសប្រមាណសុជាតិក៏បន្ថែមទៀត :

- នាងមិនជឿថាកន្លែងនេះជាបនមែនទេ ខ្ញុំសូមប្រាប់នាងតាមត្រង់ទៅចុះ ខ្ញុំចូលមកនេះគ្មានបំណងសប្បាយដូចជាគេដទៃទេ តែខ្ញុំចង់កសាងអំពើល្អចំពោះនារីរងគ្រោះ កាយវិការរបស់ខ្ញុំអម្បាញ់មិញនេះ គឺប្រឌិតទាំងទើសទាល់ដើម្បីពិសោធរកការពិតតែប៉ុណ្ណោះ !

ម៉ូលីយ៉ានៅតែបើកភ្នែកក្រឡង់ដដែល នរៈបន្ត :

- សម្ដីខ្ញុំជាការពិតមែនណា !

- ខ្ញុំជឿសម្ដីលោកហើយ សូមលោកយកអាសាខ្ញុំផងទៅ ខ្ញុំនឹងចងចាំគុណនេះមិនអាចបំភ្លេចបានទេ !

- ចុះនាងមិនខ្លាចខ្ញុំបោកនាងយកទៅលក់នៅកន្លែងណាមួយទៀតទេឬ ?

- បើសិនជាលោកមានគំនិតបែបនោះដែរ ខ្ញុំសុខចិត្តស្លាប់មុនពេលដែលសេចក្ដីឈឺចាប់ និងភាពពាលាទាំងនោះកើតឡើង តែបើលោកធ្វើបែបនេះមែនខ្ញុំសូមអង្វរលោកទៅចុះ សូមលោកកុំប្រកាន់គំនិតបែបនេះអី ទុកសេរីភាពឲ្យខ្ញុំដោះស្រាយបញ្ហាទាំងនេះដោយខ្លួន

ឯងចុះ ម៉្យាងទៀតមុខមាត់អត្តចរិតរបស់លោកមិនសមមានចិត្តអាក្រក់យ៉ាងនេះទេ លោកគួរតែព្យាយាមរំងាប់ដួងចិត្តទៅតាមសម្តី និងអាកប្បកិរិយារបស់លោកដែលប្រពៃនោះជាមនុស្សល្អផងចុះ !

- បើអ៊ីចឹងបានន័យថា នាងទុកចិត្តខ្ញុំហើយមែនទេ ?

- ចាស តែសូមលោករក្សាសេចក្តីទុកចិត្តរបស់ខ្ញុំឲ្យសមតាមជំនឿរបស់ខ្ញុំផង ឲ្យតែខ្ញុំបានរួចចេញពីទីនេះ ខ្ញុំមិនភ្លេចគុណលោកទេ ទោះជាខ្ញុំស្លាប់ទៅជាខ្មោចក៏ពាំនាំ និងរំលឹកជានិច្ចនូវរាល់អំពើល្អរបស់លោកគ្មានភ្លេច១នាទីណាឡើយ !

- សូមនាងឈប់ពោលពាក្យគុណស្រ័យតទៅទៀតទៅ ខ្ញុំស្អប់ពាក្យនេះណាស់ ព្រោះពាក្យមួយម៉ាត់នេះវាធ្វើឲ្យខ្ញុំគេងគិត និងមានសេចក្តីឈឺចាប់មិនទាន់រលុបចេញពីខ្លួនខ្ញុំទេ នាងគ្រាន់តែដឹងថាខ្ញុំជួយនាងដោយស្មោះគ្មានគិតពីគុណស្រ័យអ្វីទាំងអស់ ព្រោះខ្ញុំពេញចិត្តនឹងកសាងអំពើនេះចំពោះរូបនាង ខ្ញុំនឹងនាំនាងចេញពីទីនេះក្នុងពេលឥឡូវហើយ ពេលដែលខ្ញុំចេញទៅ នាងត្រូវដាក់គន្លឹះខាងក្នុងឲ្យជាប់ ក្រៅពីរូបខ្ញុំហៅឲ្យបើកទ្វារនាងកុំបើកឲ្យសោះ ទោះបីជាអ្នកស្រីគន្ធាក៏ដោយ យ៉ាងម៉េចនាងស្តាប់បានទេ ?

- ចាស ស្តាប់បានហើយ !

សុជាតិសម្លឹងមុខនាងបន្តិចទើបបើកទ្វារចេញទៅក្រៅ ស្រីតូចម៉ូលីយ៉ារហ័សទាញទ្វារបិទទៅវិញ ទាំងថយខ្លួនមកអង្គុយលើពូកដោយ

អាការៈភិតភ័យនូវហេតុដែលកើតឡើងដោយនាងមិនបានដឹងខ្លួន តែនាងមិនទាន់ជឿស៊ប់ទៅលើទឹកចិត្តបុរសនោះទេ នាងរឹតតែព្រួយពីឆាកជីវិតដែលជួបប្រទះនូវសេចក្តីសោកសៅមិនចេះចប់ អ្វីដែលជាអ្នកជួយរំលែកទុក្ខរបស់នាងពេលនេះ គឺមានតែទឹកភ្នែកនិងសេចក្តីក្រៀមក្រំប៉ុណ្ណោះ ។

សុជាតិ ដើរចេញមកខាងក្រៅជួបនឹងវិសាលដែលចេញពីបន្ទប់លេខ៣នោះល្មម គេសើចស្រស់ដាក់អ្នកហើយទះស្មាតិច១សួរ :

- យ៉ាងម៉េចដែរអាសម្លាញ់ ?

- វិសាលគ្នាអាណិតនារីម្នាក់នោះណាស់ នាងពិតជានៅបរិសុទ្ធប្រាកដមែនឥតមានក្លែងក្លាយទេ !

- ឯងគិតយកនាងហ្នឹងធ្វើជាប្រពន្ធឬ ច្បាស់ជាគេសើចរយះមាត់ហើយសម្លាញ់ !

- ទេ ឯងយល់ច្រឡំហើយវិសាល គ្នាមិនយកនាងមកធ្វើជាប្រពន្ធនោះទេ តែគ្នាអាណិតនាងចង់ជួយនាងឲ្យចេញពីទីនេះ ព្រោះតាមអាកប្បកិរិយារបស់នាង ប្រាកដជាមិនបានដឹងខ្លួនថា ត្រូវគេយកមកសម្រាប់បម្រើការសប្បាយរបស់គេនោះទេ !

- បើអីចឹងឯងគិតជួយនាងដោយវិធីណាទៅ ?

- គិតសុំទិញពីបងស្រីគន្ធាណាំ !

- ក្រែងគេមិនលក់វិញណាំ នាងនោះស្អាតគ្រាន់បើដែរទេ ?

- ពិបាកនិយាយណាស់ ស្រេចតែឯងឲ្យពិន្ទុនៅពេលដែលបាន ឃើញទៅចុះ គ្នាសុំពឹងឯងឲ្យជួយនិយាយជាមួយនឹងបងស្រីគន្ធានោះ ដើម្បីលោះនាងចេញពីទីនេះ !

- ចុះឯងមានបាន... អី... អី ៗ ទេអម្បាញ់មិញនេះ ?

សុជាតិគ្រវីក្បាលញាប់ស្អេក :

- គ្នាទៅមិនរួចទេ វិសាល ចេះតែនឹកអាណិត តែបានសាក ល្បងពិសោធចិត្តនាងដែរ នាងពិតជានៅបរិសុទ្ធ ឯងអាណិតនាងទៅ និយាយជាមួយនឹងបងស្រីគន្ធានេះបន្តិចមើល៍ !

- ប្រហែលជាមិនថោកទេមើលទៅ !

- បើសិនជាជួយសង្គ្រោះនាងហើយ ត្រូវតែពុះពាររាល់ការ លំបាកទាំងអស់ណាំ !

- តោះ...អីចឹងទៅជាមួយគ្នា តែឯងត្រូវកុហកគាត់ថានាង នោះជាប្អូនជីដូនមួយរបស់ឯង តើឯងមានស្គាល់ឈ្មោះនាងដែរទេ ?

- ស្គាល់ នាងមានឈ្មោះថា ម៉ូលីយ៉ា !

សុជាតិនិងវិសាលនាំគ្នាចេញមកក្រៅវិញ ជួបនឹងអ្នកស្រីគន្ធា ដែលកំពុងតែញញឹមមកកាន់គេទាំងពីរ វិសាលបោះជំហានមករក លោកស្រីទាំងដាក់ខ្លួនអង្គុយក្បែរគាត់ជាមួយនឹងវាចាទៅកាន់គាត់ :

- អ្នកបង នាងដែលនៅបន្ទប់លេខ៦នោះអ្នកបងទិញពីណា មកដែរ ?

- អ៊ូ..ម៉ូលីយ៉ានោះឬ ទិញមកពីឆ្ងាយណាស់លោកប្អូនហើយមានតម្លៃថ្លៃណាស់ !

- នាងជាប្អូនជីដូនមួយរបស់សុជាតិមិត្តខ្ញុំនេះ !!

អ្នកស្រីគន្ធាភ្ញាក់ផ្អើលយ៉ាងខ្លាំង គាត់បើកភ្នែកធំៗសម្លឹងអ្នកទាំងពីរដោយអាកប្បកិរិយាភិតភ័យណាស់ដែរ ព្រោះសុជាតិកំពុងតែធ្វើមុខមាំ ឃើញអាកប្បកិរិយារបស់គាត់ភ័យបែបនេះអ្នកកំលោះក៏វាចាទាំងរក្សាទឹកមុខនៅមាំដដែល :

- ហេតុអីបានជាអ្នកបងយកប្អូនស្រីខ្ញុំមកនៅទីនេះទៅវិញ ?

- ទេលោកប្អូន បងឥតបានទិញដូរពីឈ្មួញកណ្តាលណាមកទេ គឺម៉ូលីយ៉ានាងស្ម័គ្រចិត្តយកសម្រស់របស់ខ្លួនមកប្តូរ ដើម្បីយកប្រាក់ចាយតែប៉ុណ្ណោះជាមួយនឹងរបរចិញ្ចឹមជីវិតរបស់នាង !

សុជាតិសួរបន្ថែមទៅគាត់ទៀតដោយសម្តីធ្ងន់ ៗ :

- បានសេចក្តីថា ម៉ូលីយ៉ាប្អូនស្រីខ្ញុំនាងបានយកខ្លួនមកលក់ឲ្យអ្នកបងដោយខ្លួនឯងផ្ទាល់មែនទេ ?

- ចាសប្រាកដណាស់ ព្រោះនាងទីទ័លក្រគ្មានប្រាក់កាសអ្វីបន្តិចសោះ បងអាណណិតនាងមិនចង់ឲ្យនាងប្រកបរបរចិញ្ចឹមជីវិតក្នុងន័យថោកទាបអីចឹងទេ តែម៉ូលីយ៉ាបានអង្វរបងឲ្យទទួលនាងមកនៅទីនេះផង ព្រោះនាងគ្មានមុខរបរអ្វីនឹងត្រូវដោះស្រាយសម្រាប់ជីវិតទេ

- ខ្ញុំមិនជឿទេ អ្នកបងនិយាយនេះខុសពីការពិតទាំងស្រុង

ម៉ូលីយ៉ាជានារីសុភាពពិតជាគ្មានចិត្តគំនិតបែបនេះទេ ហើយជីវភាពនាងក៏មិនទាន់ដូចជាសម្តីរបស់អ្នកបងដែរ ! ឥឡូវខ្ញុំមិនរករឿងអ្នកបងទេ !

- ចាស ទោះជាលោកប្អូនរករឿងក៏ឥតប្រយោជន៍ដែរ ព្រោះសម័យឥឡូវមនុស្សយកប្រាក់ធ្វើជាធំ ដើម្បីបំពេញសេចក្តីត្រូវការនិងការសប្បាយហ៊ឺហារបស់ខ្លួន !

- ខ្ញុំមិនរករឿងអ្នកបងទេ ខ្ញុំមានតែអង្វរអ្នកបងសុំទិញយកម៉ូលីយ៉ាទៅវិញ ព្រោះខ្ញុំជឿជាក់ថា អ្នកបងច្បាស់ជាចំណាយប្រាក់ដ៏ច្រើនសម្រាប់ទិញរូបនាងពីឈ្មួញម្នាក់ ត្រង់ថានាងស្ម័គ្រចិត្តចូលមកបម្រើនៅទីនេះខ្ញុំមិនជឿទេ !

- ខ្ញុំចង់ទុកម៉ូលីយ៉ានៅកន្លែងនេះ ព្រោះនាងមានសម្រស់ល្អអាចទាក់ទាញបុរសគ្រប់រូបឲ្យពេញចិត្ត !

- ខ្ញុំនឹងជូនប្រាក់តាមតម្រូវការរបស់អ្នកបង ទោះបីជាអ្នកបងត្រូវការចំណេញប៉ុន្មានក៏ដោយ !

- ល្អមហើយអ្នកបង ទុកជាការរាប់អានគ្នាទៅចុះ ( វិសាលពោលបន្ថែម ) ។

អ្នកស្រីគន្ធាសញ្ជឹងគិតបន្តិច ហើយតបទៅវិញដោយសម្តីមួយមួយថា :

- ចាំថ្ងៃស្អែកលោកប្អូនមកទទួលនាងយកចុះ រីឯតម្លៃដែល

ខ្ញុំបានទិញមកនោះគឺ ១៥ម៉ឺន !

- ខ្ញុំនឹងឲ្យអ្នកបងចំណេញ៥ម៉ឺន បើមិនសមតាមតម្រូវការរបស់អ្នកបងទេលើសពីនេះទៀតក៏បានដែរ ! តែខ្ញុំសុំយកម៉ូលីយ៉ាទៅក្នុងពេលឥឡូវនេះ ចំណែកប្រាក់ព្រឹកស្អែកម៉ោង៧ ឬ ៨ខ្ញុំនឹងយកមកប្រគល់ឲ្យអ្នកបងដល់ទីនេះតែម្តង សូមអ្នកបងកុំមានការសង្ស័យ ឬមិនទុកចិត្តយ៉ាងណាឲ្យសោះខ្ញុំមិនបោកប្រាស់អ្នកបងទេ !

- មែនហើយ បើសិនបងមិនទុកចិត្តសុជាតិទេ ចាំដកប្រាក់របស់ខ្ញុំក៏បានដែរ !

- ចាស មិនមែនខ្ញុំមិនទុកចិត្តលោកប្អូននោះទេ តែខ្ញុំចង់និយាយជាមួយនឹងម៉ូលីយ៉ាជាចុងក្រោយ មុនពេលដែលនាងឃ្លាតទៅនេះឲ្យបានច្រើនបន្តិច !

- ជាការងាយសោះ ខ្ញុំតែងតែចេញចូលញឹកញាប់ ដូច្នេះថ្ងៃណាមួយអ្នកបងចង់ជួបនឹងម៉ូលីយ៉ានិយាយកិច្ចការយ៉ាងណាក៏បានដែរ

- ចាស អ៊ីចឹងក៏បានដែរ តែលោកប្អូនទាំងពីរនៅចាំខ្ញុំទីនេះសិនហើយ !

អ្នកស្រីគន្ធារកលេសចង់ចំណេញច្រើនណាស់ តែធ្វើទៅមិនកើត ទីបំផុតគាត់បញ្ជារថយន្តទៅគេហដ្ឋានយកវ៉ាលីសសម្លៀកបំពាក់ម៉ូលីយ៉ាមកប្រគល់ឲ្យសុជាតិ រួចអនុញ្ញាតឲ្យគេនាំនាងទៅក្នុងពេលនេះតែម្តង ។

# វគ្គទី២
# ស្នេហ៍មិនបានព្រាងទុក

ពេលវេលាបានអនុញ្ញាតឲ្យអ្នកកំលោះយើងសម្រេចតាមចិត្ត របស់គេហើយ ទាំងពីរនាក់នាំគ្នាដើរសំដៅមកបន្ទប់របស់ម៉ូលីយ៉ា ហើយស្រែកពីក្រៅឲ្យនាងបើកទ្វារឡើង !

- ម៉ូលីយ៉ា នាងបើកទ្វារឲ្យខ្ញុំបន្តិច តើនាងចាំសំឡេងខ្ញុំបាន ដែរទេ ?

ឮសម្តីរបស់គេស្រែកពីក្រៅមកភ្លាម មាណវីស្លុះមកបើកទ្វារ ទាំងក្នុងចិត្តក្តុកក្តាក់រកស្មានមិនត្រូវលាយឡំនឹងការត្រេកអរ ! ទ្វារបើកឡើងភ្លាម អ្នកប្រុសហុចវ៉ាលីសទៅឲ្យនាង ស្រីក៏ទទួលយកពីដៃ គេទាំងសម្លឹងមើលគឺពិតជាវ៉ាលីសរបស់លនាងមែន សុជាតិក៏និយាយ ឡើងថា :

- ពីថ្ងៃនេះទៅនាងផុតក្តីលំបាកហើយ ព្រោះខ្ញុំបានទិញនាង ពីអ្នកស្រីគន្ធារួចហើយ ពេលនេះខ្ញុំប្រគល់សេរីភាពឲ្យនាងវិញដើម្បី រស់ជាមនុស្សដូចជាគេដទៃ សូមនាងជឿចិត្តខ្ញុំចុះ តែពេលនេះនាង គួរតែទៅផ្ទះរបស់ខ្ញុំសិនបានទេ !

ស្រស់ស្រីនៅស្ងៀមមិនវាចាអ្វីទាំងអស់ នាងដើរតាមគេពី

ក្រោយយ៉ាងស្ងៀមស្ងាត់ទាំងភ្នែកវេរកមើលលោកស្រីគន្ធា ។

អ្នកប្រុសឃើញដូច្នេះក៏ស្រដីឡើង :

- នាងចង់ជួបបងស្រីគន្ធានោះមែនទេ ? គាត់មិនឲ្យនាងជួបទេ ព្រោះគាត់ច្បាស់ជាមានការខ្មាសអៀនចំពោះនាងខ្លាំងណាស់ គឺរឿងបោកប្រាសនាងយកមកនៅក្នុងបននេះហ្នឹងណាំ !

ចេញផុតពីវិមាននរកនេះ សុជាតិ និងវិសាលបានបែកផ្លូវគ្នាដោយសារតែអ្នកប្រុសយើងត្រូវនាំស្រស់ស្រីនាងជិះម៉ូតូតែពីរនាក់នៅក្រោមពន្លឺអគ្គិសនីយ៉ាងភ្លឺចិញ្ចាច គេឃើញទឹកមុខរបស់ស្រីគឺស្រពាប់ស្រពោនជានិច្ច ហាក់ដូចជាភ័យបន្តិច អរបន្តិចរកស្មានមិនត្រូវឡើយដែលនាងត្រូវរួមដំណើរជាមួយបែបនេះ ។

មកដល់ផ្ទះភ្លាមអ្នកប្រុសរុញម៉ូតូយកទៅទុកស្រួលបួលហើយទើបមកចាក់សោបន្ទប់ !

- ចូលទៅក្នុងទៅនាង !

កញ្ញាចូលទៅខាងក្នុងតាមបញ្ជារបស់គេ ទិដ្ឋភាពនៅក្នុងផ្ទះស្ងាត់ឈឹង នាងដូចជាបុកពោះតិចៗដែរ តែសម្ដីនិងឫកពាររបស់គេមិនសមជាអ្នកបោកប្រាស់នោះទេ កំលោះសម្លឹងមុខនាងបន្តិចទើបបើកភ្លើងមួយទៀតឲ្យភ្លឺខ្លាំងជាងមុន ទើបនិយាយទៅកាន់នាង :

- ផ្ទះរបស់ខ្ញុំមិនសូវស្អាតទេ ម៉ូលីយ៉ា ខ្ញុំសម្រេចចិត្តថាឲ្យនាងសម្រាកនៅក្នុងបន្ទប់នេះគឺជាបន្ទប់សម្រាប់ទទួលអ្នកជំងឺ តើនាង

www.novelkhmer.com

ហ៊ានសម្រាកដែរទេ ?

- ចាស ខ្ញុំមិនខ្លាចទេលោក !

- នាងចូលទៅរៀបចំកន្លែងគេងសិនទៅ ពេលដែលរួចរាល់ហើយ ចេញមកចាំខ្ញុំនៅក្នុងបន្ទប់ទទួលភ្ញៀវនេះវិញ ព្រោះខ្ញុំត្រូវការចង់ដឹងរឿងរ៉ាវខ្លះៗរបស់នាង !

ម៉ូលីយ៉ាមិនឆ្លើយតបទៅវិញទេ នាងយួរវ៉ាលីសដើរចូលទៅក្នុងបន្ទប់តាមការណែនាំរបស់សុជាតិ ។ អ្នកប្រុសដុកទ័រតាមសម្លឹងមើលស្រីរហូតដល់នាងទាញទ្វារបិទ ទើបគេចូលទៅផ្លាស់សម្លៀកបំពាក់នៅក្នុងបន្ទប់របស់គេ រួចរាល់ហើយទើបចេញមកចាំនាងនៅឯបន្ទប់ទទួលភ្ញៀវវិញ ។

ម៉ូលីយ៉ាបោះជំហានមួយៗដើរមករកអ្នកទាំងឱនមុខចុះ អ្នកប្រុសចាក់ទឹកហុចមកឲ្យនាងទាំងស្រដីមិនបានសម្លឹងមើលទៅមុខនាងបន្តិចឡើយ :

- ម៉ូលីយ៉ា អង្គុយចុះសិនមក នាងហ៊ានមកតាមខ្ញុំបែបនេះនាងមិនខ្លាចទេឬ ?

- ចាស ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង គឺខ្ញុំជឿជាក់ក្នុងចិត្តដោយទុកចិត្តទៅលើលោកណាស់ !

- ផ្ទះនេះខ្ញុំនៅតែម្នាក់ឯងទេ តែមិនជាស្ងាត់ប៉ុន្មានដែរ ទើបតែប៉ុន្មានថ្ងៃនេះប៉ុណ្ណោះដែលស្ងាត់ ព្រោះខ្ញុំឈប់ទទួលអ្នកជំងឺមក

ព្យាបាលទៀត !

សម្ដីរបស់គេអាចឲ្យស្រស់ស្រីនាងកាត់យល់បានថា គេគឺជាគ្រូពេទ្យមួយរូបដែលធ្វើការនៅក្នុងមន្ទីរពេទ្យណាហើយ សុជាតិលើកកែវទឹកក្រេបបន្តិចទើបនិយាយតទៅទៀត :

- តែថ្ងៃនេះខ្ញុំបានទទួលនាងមកពីស្ថាននរកនោះទៀត ពិតជាលែងស្ទាត់ហើយ បើសិនជានាងចង់ត្រឡប់ទៅផ្ទះវិញក៏បានដែរ ខ្ញុំនឹងជូននាងទៅ ព្រោះនៅតែពីរនាក់ខ្ញុំបែបនេះអ៊ីចឹងក្រែងលោនាងមិនទុកចិត្តខ្ញុំ ហើយម៉្យាងទៀតខ្ញុំហាក់ដូចជាបិទសេរីភាពនាងពេក !

ម៉ូលីយ៉ាបើកភ្នែកសម្លឹងមុខគេ កែវភ្នែកស្រីមុតគ្រាន់បើដែរ ល្មមតែសុជាតិមិនហ៊ានសម្លឹងមើលទៅនាងវិញ កញ្ញាដាក់ភ្នែកចុះទើបវាចាយ៉ាងទន់ភ្លន់ :

- សន្ដានចិត្តរបស់លោកល្អណាស់ តែខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេ ខ្ញុំសុំនៅជាមួយនឹងលោកដែរ ទោះក្នុងឋានៈជាអ្នកបម្រើក៏ដោយក៏ខ្ញុំសុខចិត្តដែរ ឲ្យតែលោកអនុញ្ញាតផ្ដល់សេចក្ដីសុខសម្រាប់ជីវិតខ្ញុំ ចិត្តរបស់ខ្ញុំអរគុណចំពោះលោកគ្មានថ្ងៃដែលបំភ្លេចបានទេ !

- ម៉ូលីយ៉ា ខ្ញុំពេញចិត្តឲ្យនាងរស់នៅទីនេះណាស់ គឺមិនមែនចាត់ទុកនាងជាស្រីបម្រើនោះឡើយ គឺក្នុងឋានៈជាមិត្តរបស់ខ្ញុំមួយរូបណា ឬក៏ប្អូនស្រីតែមួយគត់របស់ខ្ញុំព្រោះខ្ញុំគ្មានបងប្អូនឯណាទេ មានតែម្នាក់ឯងគត់ តែខ្ញុំមានចម្ងល់ខ្លះ ហេតុអ្វីក៏នាងមិនចង់ត្រឡប់ទៅ

ផ្ទះវិញ ? តើនាងអាចប្រាប់ពីមូលហេតុទាំងនោះប្រាប់ខ្ញុំផងបានទេ ?

- ខ្ញុំចង់រស់នៅទីនេះ គឺព្រោះតែខ្ញុំចង់កសាងអំពើល្អដ៏ច្រើនចំពោះលោក ដើម្បីឲ្យខ្ញុំបានសងគុណលោកវិញខ្លះផង !

- តែខ្ញុំមិនចង់ឲ្យនាងសងគុណខ្ញុំវិញទេ ដូចជាខ្ញុំបានប្រាប់នាងរួចហើយទេតើ ! ឥឡូវនេះខ្ញុំចង់ដឹងរឿងមួយទៀត គឺចង់ដឹងថាតើហេតុអីក៏នាងទៅនៅទីដ៏ស្មោកគ្រោកនោះទៅវិញ ? សូមនាងនិយាយទៅតាមការពិតកុំបំផ្លើសឲ្យសោះ ទោះជាមិនសមរម្យយ៉ាងណាក៏ដោយក៏ខ្ញុំមិនសើចយំអ្វីដែរ !

ម៉ូលីយ៉ាលេបទឹកមាត់បន្តិចដើម្បីផ្សើមបំពង់ក ទើបចាប់ផ្ដើមនិយាយពីអតីតកាលរបស់នាងប្រាប់អ្នកប្រុសដែលមានដូចតទៅ...!..!

..................ក្រោមឥទ្ធិពលកម្រោលរបស់ព្រះពិរុណ ផ្សំនឹងមហិទ្ធិឫទ្ធិនៃវាសនាផង...កញ្ញាពីររូបដើរត្រសងកាត់តំណក់ទឹកភ្លៀងហាក់មានសភាពទ្រេតទ្រោតគ្មានលំនឹងនៅក្នុងខ្លួនបន្តិចណាសោះ ! មកដល់ពីមុខគេហដ្ឋានមួយ មាណវីដែលដើរខាងឆ្វេងដៃក៏ស្រដីទៅកាន់មិត្តរបស់នាងថា :

- ចិន្ដា គ្នាចូលផ្ទះហើយ ភ្លៀងខ្លាំងណាស់ឯងហ៊ានដើរទៅផ្ទះម្នាក់ឯងដែរទេ ? បើខ្លាចនៅជ្រកផ្ទះយើងសិនហើយចាំរាំងគ្នាជូនកង់ឯងទៅផ្ទះវិញណា៎ !

- មិនអីទេម៉ូលីយ៉ា ព្រោះភ្លៀងនេះបែបមិនងាយរាំងទេ គ្នា

ទៅហើយណា !

នារីទាំងពីរក៏បែកផ្លូវគ្នាត្រឹមនេះ ! ម៉ូលីយ៉ាបោះជំហានចូលទៅក្នុងផ្ទះទាំងភ័ក្ត្រស្រពាប់ស្រពោន ព្រោះទីនេះវាមិនអាចធានានូវសុភមង្គលសម្រាប់ជីវិតយុវវ័យរបស់ស្រីទេ កញ្ញាចូលទៅក្រោមផ្ទះដោះអាវភ្លៀងចេញព្យួរឲ្យវាស្រក់ទឹក ទើបនាងឡើងទៅលើផ្ទះ ។

ទើបតែបោះជំហានមកដល់មាត់ទ្វារ មាណវីត្រូវទច់ដំណើរង៉ក់ទាំងភ្ញាក់អារម្មណ៍ព្រោះមានមនុស្សជាច្រើនសុទ្ធតែចាស់ៗ ធ្វើឲ្យស្រស់ស្រីនៅទ្រឹងបន្តិច ទើបហួសដំណើរតាមយ៉ខាងមុខដាក់សៀវភៅលើកៅអីដែលមានសភាពសើមតិចៗ ដោយសារការជ្រាបទឹកភ្លៀងសាចមកតាមជញ្ជាំង ។

- នាងយ៉ា មកដល់ហើយចុះទៅដាំបាយភ្លាមទៅ នាងឯងមិនដឹងថាខែនេះមេឃឆាប់ងងឹតទេឬ នៅទ្រេតទ្រោតដល់ណាទៀត !

ម៉ូលីយ៉ា ងើបមុខសម្លឹងមើលម្ដាយចុងទាំងតូចចិត្តព្រោះសម្ដីគ្មានខ្លឹមសាចំពោះនាងបន្តិចណាសោះ និយាយមកកាន់នាងដូចជាស្រីបម្រើអីចឹង !

- ថ្ងៃនេះត្រូវដាំបាយប៉ុន្មានកំប៉ុងហើយធ្វើម្ហូបអីដែរទៅ ?

- រាល់ថ្ងៃមិនធ្លាប់ដាំទេឬ ? ចាំបាច់មកសួរអញទៀត !

- ធ្លាប់ហើយ តែឃើញមានភ្ញៀវច្រើនក្រែងគេនៅញាំបាយទីនេះដែរ !

- មិនបាច់សួរនាំពីរឿងភ្ញៀវទេ បើទុកជាគេនៅបាយក៏មិនឲ្យនាងឯងដាំដែរ ឥឡូវមិនបាច់និយាយច្រើនទេរហ័សចុះភ្លាមទៅនៅធ្វើឫកធ្វើរាងឲ្យគេមើលដល់ណាទៀត ចំណែកម្ហូបឃើញមានស៊ីដាំស្ងួហ្នឹងទៅ !

ម៉ូលីយ៉ាមិននិយាយអ្វីទេ ដើម្បីកុំសម្តីម្តាយចុងឮដល់ត្រចៀកនាងទៀត ដំណើររបស់ស្រីដែលដើរកាត់មាត់ទ្វារបានធ្វើឲ្យទាក់ភ្នែកដល់បុរសម្នាក់ដែលមានវ័យប្រមាណ ២៧ ឆ្នាំ ជាភ្ញៀវនៅក្នុងផ្ទះនេះចោលការចាប់អារម្មណ៍មកលើរូបនាងយ៉ាងខ្លាំង អ្នកប្រុសម្នាក់នេះមានឈ្មោះថាបូរីជាអ្នកកាសែតអន្តរជាតិមួយរូប ទើបតែត្រឡប់មកពីយកព័ត៌មាននៅប្រទេសអាមេរិក ។

អ្នកប្រុសបូរីជាកូនប្រុសទីពាររបស់លោកមេគយ សេដ្ឋា កាលពីអ្នកស្រីម៉ូលីនជាម្តាយនៅរស់ បូរីនិងម៉ូលីយ៉ាបានរាប់អានគ្នាយ៉ាងជិតស្និទ្ធតាមការណែនាំរបស់ឪពុកម្តាយទាំងសងខាង ។ រយៈពេល ១៤ឆ្នាំដែលអ្នកប្រុសបានឃ្លាតចេញពីនាង ម៉ូលីយ៉ាមើលគេមិនស្គាល់ទេគ្រាន់តែមានការសង្ស័យខ្លះៗប៉ុណ្ណោះ ព្រោះនាងមិនហ៊ានពិនិត្យមើលឲ្យបានច្បាស់ ។ អ្នកកំលោះសស្បៀវៗចេញមកយ៉ខាងក្រៅដើម្បីមានឱកាសបានជួបជាមួយនឹងនាង បើចុះទៅក្រោមត្រង់ៗទៅវាដូចជាមិនកើតព្រោះម្តាយចុងម៉ូលីយ៉ាសម្លឹងមករកអ្នកទាំងសង្ស័យ យូរណាស់ទើបគេសុំម្តាយចុងនាងចុះមកក្រោម ចំពេលដែលលោកស្រី

សំអឿនម្តាយចុងម៉ូលីយ៉ាកំពុងតែជាប់មាត់ជាមួយនឹងឪពុកម្តាយ និងជីតារបស់អ្នក ។

ស្រស់ស្រីម៉ូលីយ៉ានាងមិនបានចាប់អារម្មណ៍ថាមានបុរសម្នាក់កំពុងនៅឈរគយគន់គ្រប់កាយវិការរបស់នាងឡើយ កែវលាងអង្ករដាក់លើចង្ក្រាន ហើយចាប់ទាញយកបន្លែមកចិតទៀត ទាំងមិនរវល់ងើបមុខងាកចេញពីកិច្ចការនេះឡើយ ។ បូរីរង់ចាំឲ្យនាងស្គាល់គេមុនតែមិនអាចចាំបាន គេក៏ទាញកៅអីទាបមកអង្គុយក្បែរនាង ហើយសួរទៅកាន់ស្រីថា :

- ម៉ូលីយ៉ា តើអូនស្គាល់បងទេ ?

ភ្ញាក់ដូចគេកន្ត្រាក់ព្រលឹង ស្រស់ស្រីសម្លឹងមើលគេបន្តិចទាំងជ្រួញចិញ្ចើមពិតជាបូរីទាំងសាច់ទាំងឈាម នាងមិនច្រឡំទេថ្វីត្បិតតែរូបគេឃ្លាតពីនាងចំនួន១៤ឆ្នាំហើយក៏ដោយ ក៏ដួងចិត្តស្រីនៅតែរំលឹករាល់រូបភាពជាមួយកាយវិការ សម្តីសំដៅរបស់គេកាលពីមុន ! កញ្ញាដាក់មុខចុះវិញដំណាលនឹងសម្តីរបស់ស្រី :

- ម៉ូលីយ៉ាមិនភ្លេចទេ បងគឺជាបងបូរីដែលខ្ញុំធ្លាប់គោរពកាលពីអតីតកាលមកមែនទេ ?

ពាក្យសម្តីសាមញ្ញ មិនបង្ហាញពីភាពភ្ញាក់ផ្អើលរបស់អារម្មណ៍ទេ ធ្វើឲ្យបូរីមានការសង្ស័យនិងអន់ចិត្តខ្លះៗដែរ អ្នកប្រុសបន្តវាចាទៅទៀត :

ចូលធ្វើការនៅក្រសួងដូចជាបងដែរហើយ ដើម្បីឲ្យបានដើរលេងច្រើនប្រទេសដូចបង និងដកស្រង់បទពិសោធដទៃៗ នៅក្នុងពិភពលោកមនុស្ស តែគួរឲ្យស្ដាយណាស់ព្រោះខ្ញុំ....( នាងអាក់សម្ដី )

- ព្រោះអ្វីដែរទៅ ?

- គ្មានអ្វីទេ តែខ្ញុំជាមនុស្សគ្មានប្រាជ្ញារៀនឲ្យបានពូកែដូចជាបង ច្បាស់ជាគ្មានវាសនាក្លាយទៅជាអ្នកកាសែតបានទេ !

- មិនមែនអ៊ីចឹងទេ ព្រោះបងចាំច្បាស់ថាម៉ូលីយ៉ាប្អូនស្រីបងរៀនពូកែណាស់ គឺរាល់បំណាច់ឆ្នាំតែងតែបានទទួលរង្វាន់ការលើកទឹកចិត្តសរសើរពីលោកគ្រូអ្នកគ្រូមិនដែលខានទេ !

- ឥឡូវបច្ចុប្បន្នកាលមិនមែនជាអតីតកាលទេ អ្វីៗបានប្រែប្រួលអស់ទៅហើយ ឈប់រំលឹកទៀតទៅព្រោះពាក្យទាំងនេះមិនបានធ្វើឲ្យខ្ញុំរីករាយឡើយ គឺធ្វើឲ្យខ្ញុំឈឺចាប់គ្មានថ្ងៃណាបំភ្លេចបានទេ !

អ្នកប្រុសសែនឆ្ងល់នឹងសម្ដីស្រីណាស់ តើនាងចង់និយាយឲ្យអ្នកឬ ? ឬមួយក៏និយាយពីសភាពប្រែប្រួលនៅក្នុងគ្រួសាររបស់នាង អ្នកកំលោះគន់មើលម្រាមដៃស្រីដ៏ស្រឡូន ដែលកំពុងធ្វើសកម្មភាពគ្មានឈប់ គេសួរទៅនាងដោយវាចាតិចៗថា :

- ម៉ូលីយ៉ា បងមិនយល់ទេ អូនចង់និយាយឲ្យអ្នកណា ឬមួយក៏អូនថាឲ្យបង ?

- ទេ ! ទេ ! ខ្ញុំមិនហ៊ានថាអ្វីឲ្យបងទេ ! គឺនៅតែគោរពបង

ដូចពីមុនដដែល អ៊ំ...និយាយអីចឹងអូនមិនទាន់បានជួបមុខឪពុកម្ដាយបងផង គាត់ប្រហែលជាប្រែប្រួលច្រើនណាស់ហើយមើលទៅ !

- អ្វី១ដែលកន្លងហួសមកហើយ វាត្រូវតែប្រែប្រួលជាធម្មតារបស់មនុស្សទេ ទោះជាម៉ូលីយ៉ាក៏ដោយក៏បងសង្កេតឃើញថាប្លែកដែរ តើអូនមិនដឹងថាខ្លួនអូនប្លែកយ៉ាងណាទេឬ ? តែបងមិនគិតពីរឿងហ្នឹងទេ ទោះជាយ៉ាងណាក៏ត្រូវសន្មតថា យើងទាំងពីរស្ថិតក្នុងសភាពដើមដូចពីអតីតកាលដដែល !

- ខ្ញុំថាឈប់ឲ្យរំលឹកពីអតីតកាលហ្នឹងទៀតទៅ ព្រោះវាប្រៀបបាននឹងកប៉ាល់ដែលលិចទៅបាតសមុទ្រ ហើយមិនមែនជាការងាយស្រួលសម្រាប់អ្នកមានបំណងស្វែងរកវាមកវិញនោះ ដូចពាក្យដែលនិយាយនេះទេ !

បូរីហាក់យល់ខ្លះ១ពីសម្ដីស្រី តេនីកអាណិតនាងជាពន់ពេកម៉ូលីយ៉ាប្រាកដជាជួបនឹងបញ្ហាស្មុគស្មាញណាមួយ សម្រាប់ជីវិតនាងក្នុងពេលបច្ចុប្បន្នហើយ ទើបនាងពោលពាក្យមកយ៉ាងដូច្នេះ ។

អ្នកប្រុសឱនមើលមុខនាងហើយនិយាយទៀត :

- ម៉ូលីយ៉ា កប៉ាល់ដែលលិចហើយនោះ ពិតជាពិបាកស្រង់យកមកវិញមែន ព្រោះផ្ទៃសមុទ្រវាធំជាងផែនដី តែចំពោះប្អូនស្រីបងត្រូវតែពុះពារជានិច្ច ទោះត្រូវឆ្លងកាត់ការលំបាកជាងវិស្វករឬក៏អ្នកបច្ចេកទេស ដែលត្រូវដេកគិតបង្កើតមធ្យោបាយស្រង់កប៉ាល់នោះ

ក៏ដោយក៏បងនៅតែតស៊ូដែរ បើត្រូវរស់ជីវិតក្នុងបញ្ហានេះដោយសារវាមានភាពវែងអន្លាយ ក៏បងបានសន្មតទុករួចជាស្រេចទៅហើយ !

- ខ្ញុំវាមានអ្វីសំខាន់រហូតដល់ឲ្យបងប្ដូរផ្ដាច់យកកិត្តិយសមកតស៊ូដល់ម្ល៉ឹង ?

- ពិតជាសំខាន់ណាស់ ព្រោះ១៤ឆ្នាំ ដែលបងបានទៅសិក្សា និងធ្វើសកម្មភាព បូកផ្សំរយៈពេលដែលបងរវល់មិនបានមកជួបអូន បងគ្មានបានសេចក្ដីសុខ១វិនាទីណាឡើយ ទោះជាបានដើរពាសប្រទេសហើយក៏ដោយ ក៏បងនៅមិនទាន់ជួបក្ដីសប្បាយឲ្យធំធេងដូចពេលដែលបងធ្លាប់បានរស់នៅសើចលេងសប្បាយកាលពីក្មេងដែរ តែបើអូនចង់ក្លាយទៅជាអ្នកកាសែតហើយ យើងនឹងចេញទៅធ្វើសកម្មភាពជាមួយគ្នានោះបងពិតជាសប្បាយ គឺសប្បាយជាងពេលដែលយើងនៅពីវ័យក្មេងទៅទៀត !

- សប្បាយតែបងម្នាក់ ចំណែកខ្ញុំវិញ គឺត្រូវរងនូវទារុណកម្មមួយដ៏ធ្ងន់ធ្ងរបំផុត នៅពេលដែលខ្ញុំបានជួបនិយាយជាមួយនឹងបង !

- ព្រោះតែរូបបងធ្វើឲ្យរំខានដល់រឿងផ្ទាល់ខ្លួនរបស់អូនមែនដែរទេ ?

- មិនមែនទេ ! ( នាងឆ្លើយយ៉ាងកំបុត )

- អ៊ីចឹងយ៉ាងម៉េចទៅវិញ ? ( អ្នកប្រុសដាក់មុខស្ងួត )

- ខ្ញុំមិនដឹងទេ ស្រេចតែបងវិនិច្ឆ័យខ្លួនឯងចុះ តែគំនិតបង

អម្បាញ់មិញនេះមិនទាន់ត្រឹមត្រូវទេ គឺខុសពីការពិតនៃចិត្តខ្ញុំទាំងស្រុងទៅហើយ !

- បងពិតជាខ្វះការវិនិច្ឆ័យណាស់ ! ម៉ូលីយ៉ា...អូនប្រាប់ការពិតមក តើការរស់នៅរបស់អូនវាជួបនូវផលវិបាកស្មុគស្មាញយ៉ាងណាខ្លះ ? បងហ៊ានធានាដោះស្រាយរាល់បញ្ហាទាំងអស់ ឲ្យតែអូនស្រីតែមួយរបស់បង បានចាកផុតពីទុក្ខកង្វល់និងការគាបសង្កត់ចំពោះអូន !

- មិនពិតទេ !

- រឿងអ្វីក៏មិនកំបាំងដែរ បងដឹងទាំងអស់អូនមិនបាច់លាក់នឹងបងទេ ! សព្វថ្ងៃមីងសំអឿនកំពុងតែបញ្ចុកបន្សុំបងជាមួយនឹងរ៉ាវីសម្បើមណាស់ តែបេះដូងបងវារឹងដូចថ្មអង្គរមិនងាយចុះសម្រុងនឹងអ្នកណាផ្ដេសផ្ដាសទេក្រៅពីម្ចាស់របស់វា !

- ប្រហែលរ៉ាវីហើយបងមិនទាន់ចុះសម្រុង តើនារីណាទៅដែលជាម្ចាស់បេះដូងរបស់បងនោះ ?

- មានតែម្នាក់គត់ គឺជានារីដ៏ពិសេសដែលបងបានស្គាល់ចិត្តថ្លើមរបស់នាងតាំងពីតូច តែមកដល់ឥឡូវនេះនាងមិនដឹងជាកែប្រែយ៉ាងណាទេ ព្រោះរូបសម្ផស្សរបស់នាងប្លែកបែបនេះទៅហើយ !

- អីចឹងបងមិនអាណិតរ៉ាវីដែលនាងលួចពេញចិត្តនឹងបងអស់សន្ទឹកនោះទេឬ ? វាមិនស្មើនឹង១ភាគ៤ ចំពោះសេចក្ដីស្រឡាញ់របស់នាងតាំងពីតូចដល់ម្ចាស់បេះដូងបងទេឬ ?

តូចតន់នៅស្ងៀមបន្តិចព្រោះដួងចិត្តនាងកំពុងតែចោទសួរក្នុងខួរក្បាលជាច្រើនបញ្ហា បូរីក៏មិននិយាយស្តីអ្វីទៀតដែរ អ្នកគ្រាន់តែសម្លឹងកាយវិការនាងយ៉ាងពេញចិត្តប៉ុណ្ណោះ មួយសន្ទុះទើបម៉ូលីយ៉ានិយាយឡើង :

- បងអញ្ជើញទៅវិញចុះ ទីនេះមិនសមរម្យសម្រាប់បងទេ គ្រាន់តែមកជួបខ្ញុំនិយាយប៉ុណ្ណឹងខ្ញុំអរណាស់ទៅហើយ ព្រោះមុននេះខ្ញុំនឹកថាបងប្រហែលជាភ្លេចខ្ញុំហើយមើលទៅ !

- ភ្លេចឯណាងាយៗ បើរាល់ថ្ងៃឈ្មោះម៉ូលីយ៉ារបស់អូនបានដក់ជាប់នៅក្នុងខួរក្បាលបងមិនរបេះឡើយ !

- បងគួរតែលុបបំបាត់វាចោលទៅ គ្មានប្រយោជន៍អ្វីដែលបងត្រូវគិតពីខ្ញុំដល់ម្លឹងទេ ព្រោះខ្ញុំធំហើយមិនមែនដូចពីមុនទៀតទេ

- អូននិយាយយ៉ាងម៉េចហ្នឹង ?

- គ្មានយ៉ាងម៉េចទេ ក្រែងមនុស្សអាយុ១៦ឆ្នាំឡើងទៅ គេចាត់ទុកជាមនុស្សដែលចេះស្គាល់គុណទោស មានគំនិតទទួលខុសត្រូវហើយ ហេតុអីក៏បងនៅតែឆ្ងល់ទៀត !

- បងយល់ហើយ បងមិនមែនចង់គ្រប់គ្រងអូនដូចពីក្មេងទេ បងគ្រាន់តែចង់សុំចូលរួមសេចក្តីទុក្ខនិងសប្បាយជាមួយអូនប៉ុណ្ណោះ !

- ហួសពេលហើយបងបូរី !

- បើអីចឹងបានន័យថាអូនជិតរៀបការហើយមែនទេ ?

- ខុសស្រឡះ បើនិយាយថាបងបូរីជិតរៀបការក៏ដូចជាត្រូវជាងមែនទេ ?

- អ្នកណាប្រាប់ថាបងជិតរៀបការអ្នាំម៉ូលីយ៉ា ?

- បងស្មានថាខ្ញុំហ្នឹងជាទីងមោងមិនដឹងអីមែនទេ ? ថ្វីត្បិតតែគេទាំងនោះខំលាក់លៀមរឿងនេះមិនឲ្យខ្ញុំដឹងយ៉ាងណាក៏ដោយ ក៏វាមិនកំបាំងជិតដែរ ! គ្រាន់តែប៉ុណ្ណឹងបងកុហកខ្ញុំទៅហើយ ចុះទម្រាំរឿងធំដុំទៀត លើសពីនេះទៅទៀតមានសង្ស័យអ្វីដែលខ្ញុំត្រូវការភាពស្មោះត្រង់រាប់អានចំពោះបងទៀតនោះ !

- កុំចេះតែយល់ផ្ដេសផ្ដាសម៉ូលីយ៉ា បងសារភាពប្រាប់អូនអស់ត្រង់ប៉ុណ្ណឹងហើយ ពេលដែលអូនបានដឹងការពិតអូនច្បាស់ជាភ្ញាក់ខ្លួនមិនខាន ! គំនិតអូនសុទ្ធតែជាការយល់ច្រឡំចំពោះរូបបងទាំងអស់ បងទុកពេលសម្រាប់ឲ្យអូនគិតបានច្បាស់ កុំភ័ន្តភាំងដូចថ្ងៃនេះទៀត !

- អរគុណបងហើយ បើបងអាណិតខ្ញុំឆាប់អញ្ជើញទៅលើវិញទៅ បើសិនអ្នកមីងសំអឿនឃើញបងមកអង្គុយនៅទីនេះមិនសមរម្យគាត់ពិតជាស្ដីបន្ទោសឲ្យខ្ញុំទៀតជាមិនខាន !

- បងទៅហើយ តែម៉ូលីយ៉ា គួរតែឡើងទៅជួបប៉ាម៉ាក់បងសិនទៅ ព្រោះគាត់នឹកអូនណាស់ អម្បាញ់មិញគាត់មិនបានចាប់ភ្លឹកថាជារូបអូននោះទេ បើសិនជាគាត់ដឹងថា អូនគាត់ហៅអូនឲ្យចូលទៅខាងក្នុងបាត់ទៅហើយ !

- តែខ្ញុំជាប់រវល់កិច្ចការមិនអាចទៅណាបានទេ បងគួរតែយល់ហើយ !

បូរីស្រណោះសម្ដីនាងណាស់ ម៉ូលីយ៉ានាងធ្លាប់តែស្រណុកមិនដែលស្គាល់ទុក្ខព្រួយលំបាកទេ គ្រាន់តែម្ដាយនាងស្លាប់ទៅចំនួន៧ឆ្នាំប៉ុណ្ណោះ ស្រីត្រូវធ្លាក់ខ្លួនដោយសារតែការច្រណែនឈ្នានីសរបស់ម្ដាយចុង ! អ្នកប្រុសសម្លឹងមើលស្រីទាំងសោកស្ដាយ ទើបបង្វិលខ្លួនឡើងទៅខាងលើវិញ ដោយពាំនាំក្ដីសោកសៅនៅក្នុងអារម្មណ៍ទៅជាមួយផង ។

នៅខាងលើផ្ទះឯណោះលោកសេដ្ឋាស្រដីឡើង :

- បើសិនជាម៉ូលីយ៉ាវាយល់ព្រមពេលប្រឡងបាក់ឌុបនេះរួចហើយ ទោះជាជាប់ឬធ្លាក់បងគិតគួរឲ្យវារៀបការហើយ ព្រោះកូនបូរីមានអាយុ២៨ឆ្នាំទៅហើយ ចិត្តគំនិតក៏ចាស់ទុំអាចគ្រប់គ្រងនៅក្នុងគ្រួសារបាន !

លោកស្រីសំអឿនសែនទាល់គំនិតនឹងវាចានេះ គាត់ថែមទាំងរក្សាទឹកមុខដូចធម្មតា !

- បើតាមខ្ញុំសង្កេតឃើញមើលទឹកចិត្តនិងពាក្យសម្ដីរបស់វាតែងតែពោលរាល់ថ្ងៃ អាយ៉ាវាមិនទាន់ចង់រៀបការទេ វាចង់នៅបន្តការរៀនដល់មហាវិទ្យាល័យទៀត តែមិនអីទេចាំខ្ញុំសួរចិត្តវាសិន !

ភ្លៀងរាំងទៅហើយលោកសេដ្ឋានិងភរិយា ជីតាបូរីក៏លាម្ចាស់

ផ្ទះត្រឡប់ទៅវិញ តែបូរីខ្សឹបប្រាប់ឪពុកថា :

- លោកប៉ា ម៉ូលីយ៉ានៅក្នុងផ្ទះបាយឯណោះទេ !

- ពិតមែនឬ ?

- បាទ ខ្ញុំទើបតែនឹងមកពីជួបនាងអម្បាញ់មិញនេះឯង !

- អឺ... វាគ្មាននឹកនាមកសួរសុខទុក្ខឯងអីបន្តិចសោះ !

- ប៉ាកុំបន្ទោសអីចឹង អ្នកមីងសំអឿនធ្វើបាបអូនម៉ូលីណាស់ កូនបានស៊ើបដឹងអស់ហើយ !

អ្នកទាំងបួនដើរមកចង្ក្រានបាយ ដើម្បីទៅជួបជាមួយនឹងស្រីកម្សត់យើង ! គ្រាន់តែក្រឡេកឃើញក្មួយអ្នកស្រីមន្ថាសែនស្រណោះព្រោះខុសពីរាវីស្រឡះ សម្លៀកបំពាក់មិនសូវដូចគេ គាត់នឹកក្តៅដល់លោកចំរើនជាឪពុកម៉ូលីយ៉ាជាអនេក មិនសមណាខ្លាចប្រពន្ធមកធ្វើបាបកូនដល់ម្លឹងសោះ ។

ម៉ូលីយ៉ាស្ទុះមករកអ្នកស្រីមន្ថាទាំងទឹកភ្នែក ដោយក្តីរំភើបហួសប្រមាន :

- ម៉ាក់អ៊ំ !

- ម៉ូលីយ៉ា !

អ្នកស្រីអង្អែលក្បាលក្មួយដោយក្តីករុណា កញ្ញាហក់មករកលោកសេដ្ឋាព្រមទាំងជួបរាក់ជាមួយនឹងលោកតាជំនិត !

- ប៉ាអ៊ំ លោកតា !

លោកសេដ្ឋាចាប់ដៃក្មួយស្រីជាប់ទាំងរកាំឈឺផ្សា បញ្ចេញភាសាដួងចិត្តសាសងគ្នាតាមរយៈមនោសញ្ចេតនា ព្រោះគេឃ្លាតគ្នាអស់រយៈពេលរាប់ឆ្នាំមកហើយ គ្រាន់តែក្រុមគ្រួសារលោកសេដ្ឋាចេញផុត អ្នកសំអឿនចុះមករកស្រស់ស្រីទាំងទឹកមុខមាំចម្លែកធ្វើឲ្យតូចតន់តក់ស្លុតជាខ្លាំង គាត់ច្រត់ចង្កេះសម្លក់នាងយ៉ាងក្តាញ់ !

- នាងយ៉ា នាងឯងកុំស្ទូវប៉ិនកាច់ប្ញកម្ញិកម្ញ៉ក់ពេក នាងដឹងថាប្តីជាអ្នកណាដែរទេ ?

- ចាស ខ្ញុំស្គាល់ច្បាស់ណាស់អ្នកមីង បងប្តីគឺជាអ្នកកាសែតមួយរូបដែលមាននារីខ្លះបង្ខំបេះដូងបរិសុទ្ធរបស់គាត់ ឲ្យទៅស្រឡាញ់គេវាដូចជាមិនសមសោះ !

- ហងឯងចង់និយាយឲ្យអ្នកណា ? ប្រយ័ត្នណាំមីយ៉ា ចង់ឌឺដងឲ្យអញផងអ្ហេ៎ មិនបានទេវ៉ឺយ !

- ខ្ញុំមិនហ៊ានឌឺដងឲ្យអ្នកមីងទេ ខ្ញុំនិយាយគឺចង់ថាឲ្យបងប្តីប៉ុណ្ណោះ !

- ហ៊ឹះ ... សុទ្ធតែបងឲ្យរលួយ ហងដឹងខ្លួនថាហងជាស្រីក្រមុំដែរទេ ហេតុអីក៏ហៅកូនកំលោះគេសុទ្ធតែបងអីចឹង ? ចំជាថោកទាបមែនហើយ !

- ភាសានេះខ្ញុំធ្លាប់ប្រើតាំងពីយូរណាស់មកហើយ អ្នកមីងគ្មានសិទ្ធិអីមកហាមឃាត់ខ្ញុំមិនឲ្យនិយាយនោះទេ ខ្ញុំហៅយ៉ាងនេះ គឺ

ក្រោមការទូន្មានរបស់ម្ដាយឪពុកខ្ញុំ មិនមែនខ្ញុំហៅតាមតែចិត្តនឹកឃើញរបស់ខ្ញុំនោះទេ !

- យី... សម្ដីមីនេះខ្លាំងណាស់តើ ហងមើលមកអញស្មានថាជាខ្ញុំរបស់ហងឬ ?

ចប់សម្ដីអ្នកសំអឿនយារដៃបម្រុងទះម៉ូលីយ៉ាឲ្យសមនឹងចិត្តក្ដៅរបស់គាត់ តែស្រស់ស្រីនាងដឹងខ្លួនទាន់រហ័សគេចចេញបណ្ដាលឲ្យម្រាមដៃគាត់ហួសមកប៉ះចុងកាំបិត ដែលនាងកាន់ដាច់ចេញឈាមក្រហមច្រាល សម្រែកមួលបង្កាច់ក៏លាន់ឡើងមួយរំពេច !

- រ៉ាវី... ជួយម៉ាក់ផង មីយ៉ាវាចាក់ម៉ាក់ហើយ !

ស្រែករួចគាត់យំនឡៀលដូចកូនក្មេង រ៉ាវីនិងលោកចំរើនឮសូរសម្រែកនេះភ័យស្លន់ស្លោ រ៉ាវីស្ទុះមកឱបម្ដាយ !

- ហ៊ឺះ ... ម៉ូលីយ៉ា នាងឯងចង់សម្លាប់ម្ដាយអញ !

លោកចំរើននិយាយមិនចេញទេ គាត់ឈរសម្លឹងបុត្រីដៃកាន់កាំបិតដែលជិតជាប់នូវលោហិតទាំងភ័ន្តភាំង !

- ហ្នឹងហើយកូនស្រីល្អរបស់បងនោះ ! ខ្ញុំមិនសុខចិត្តទេ ខ្ញុំនឹងប្ដឹងអូសក្បាលវាចូលគុក !

លោកចំរើនស្ទុះទៅកញ្ឆក់កាំបិតពីដៃម៉ូលីយ៉ាទាំងកម្រោល.. ហើយទះតប់ទៅលើនាងគ្មានត្រាប្រណីដោយមិនបានពិចារណាអ្វីបន្តិចសោះ ព្រោះតែជឿសម្ដីភរិយាសម្លាញ់ ស្រស់ស្រីនាងឈឺចាប់ណាស់

លោហិតហូរច្រាលចេញពីច្រមុះខ្ទាតប្រឡាក់ពាសពេញមុខ នាងមិនខ្ចីជូតទាំងអស់ស្រីនៅតែសើចយ៉ាងស្រស់ តែមិនមែនក្នុងន័យសប្បាយទេ ភាពញញឹមនៃមនុស្សដែលកំពុងមានទុក្ខ និងមានការឈឺចាប់ខ្លោចផ្សាជាងទឹកភ្នែកស្រក់ចុះមកទៀត !

- ហាងឯងសើចស្អី ចង់បញ្ឈឺឲ្យអញដល់ណាទៀត ?

- ខ្ញុំមិនហ៊ានបញ្ឈឺឲ្យអ្នកមីងទេ ខ្ញុំសើចនេះព្រោះតែខ្ញុំហួសចិត្តពេក !

- បងឯងឃើញទេ ឮនឹងត្រចៀកហើយឬនៅ សម្ដីវាខ្លាំងណាស់ វាចាក់ខ្ញុំប៉ុណ្ណឹងហើយនៅតែហាមាត់និយាយបញ្ឈឺឲ្យខ្ញុំទៀត !

សម្ដីចាក់រុករបស់ភរិយា ធ្វើឲ្យលោកកចំរើនរឹតតែឆេះឆួលទ្វេឡើង គាត់វាយកូនស្រីគ្មានប្រណីដៃឈាមនៅតែហូរមិនដាច់ ! ធីតានាងខាំមាត់ដោយក្ដីឈឺចាប់ អ្នកសំអឿននិងវ៉ារីលែងហ៊ានមើលនូវស្ថានភាពបែបនេះទៀត នាំគ្នាបែរមុខចេញ !

- ចាំបាច់បែរមុខចេញធ្វើអីដែរទៅ ម្ដេចក៏មិនមើលទៀតទៅ ឬក៏វារន្ធត់នឹងការឈឺចាប់ ដោយសារតែខ្លួនបានផ្ដល់ឲ្យគេដែរ ?

- បានហើយបង ឈប់វាយវាទៀតទៅ !

- បងចង់ប្រដៅវាកុំឲ្យចិត្តធំដល់ម្ល៉ឹងទៀត !

- វាជាមនុស្សសាច់ឆ្អែ ទោះជាបងវាយវាដល់ស្លាប់ក៏វាមិនប្រែដែរ ឈឺចាប់ប៉ុណ្ណឹងហើយវានៅតែគ្រាន់បើទៀត !

ពេលលោកចំរើនបញ្ឈប់សកម្មភាពវាយដំនេះដោយចោលសម្តីទៅកាន់កូនស្រី :

- ថ្ងៃនេះអញអនុគ្រោះឲ្យដោយគ្រាន់តែដាក់ទារុណកម្មវាយដំបន្តិចបន្តួចថ្ងៃក្រោយបើមានកំហុសបែបនេះទៀត អញមិនអនុគ្រោះឲ្យទេស្លាប់បានហើយឬនៅម៉ូលីយ៉ា ?

តូចតន់រលាស់សក់ឲ្យមានរបៀប នាងសម្លឹងចំមុខឪពុកគ្មានព្រិច ទាំងក្រសែភ្នែកឈឺចាប់ ទើបឆ្លើយដោយសម្តីមួយៗថា :

- ចាស កូនស្លាប់បានហើយលោកប៉ា តាំងពីម៉ាក់នៅរស់ប៉ាមិនដែលលើកដៃវាយកូន១រំពាត់ទេ កូនចាំច្បាស់ណាស់នៅពេលដែលម៉ាក់វាយកូន លោកប៉ានិងម៉ាក់ឈ្លោះគ្នាមិនខាន តែពេលនេះកូនមិនតូចចិត្តទេព្រោះអ្នកម៉ាក់បានស្លាប់បាត់ទៅហើយ តែលោកប៉ាកុំភ្លេចថាមានកញ្ចក់ឆ្លុះមុខមែន ប៉ុន្តែខួរក្បាលមនុស្សគ្មានអ្វីឆ្លុះទេ ហេតុនេះលោកប៉ាត្រូវតែចេះពិចារណានាឲ្យបានហ្មត់ចត់ សម្តីដែលមាត់មនុស្សនិយាយចេញមក ពិតជាលាក់ទុកនូវការពិតមួយក្នុងខួរក្បាលសម្រាប់មនុស្សមានការច្រណែននិន្ទាឈ្នានីស ពាក្យសម្តីមួលបង្កាច់ទាំងអស់ !

- ស្អី...ហាងចង់ថាអញមួលបង្កាច់ទៀតឬ ? បានអញមិនប្តឹងវាជាសំណាងមួយធំហើយ !

- ឈប់និយាយសំអឿន បងប្រដៅវាប៉ុណ្ណឹងគ្រប់គ្រាន់ហើយ

លោកចំរើនប្រែទឹកមុខមាំដាក់ភរិយា !

- ប៉ុណ្ណឹងហើយបងនៅកាន់ជើងវាទៀត បងចង់ឲ្យវាសម្លាប់ខ្ញុំចោលទៅមែនទេ ?

- សូមអ្នកមីងកុំនិយាយមួលបង្កាច់ខ្ញុំដល់ម្ល៉ឹងពេក ខ្ញុំគ្មានគំនិតព្យាបាទអ្នកមីងតិចតួចទាល់តែសោះ អ្នកមីងទេដែលប្រឌិតនូវបុព្វហេតុទាំងនេះឡើងដោយខ្លួនឯង ហើយប្រើសម្ដីមួលបង្កាច់មកលើខ្ញុំវិញ តែខ្ញុំមិនចាប់កំហុសអ្នកមីងទេ ព្រោះការនិយាយបង្កាច់របស់អ្នកមីង កើតឡើងពីការច្រណែនចង្អៀតចង្អល់ក្នុងសតិអារម្មណ៍របស់អ្នកមីង ព្រោះខ្លាចរូបខ្ញុំវាមានវាសនាខ្ពស់ សេចក្ដីឈឺចាប់វាដល់កម្រិតមួយទៅហើយ សូមអ្នកមីង លោកប៉ា និងវ៉ារីមើលមុខខ្ញុំឲ្យច្បាស់ ម៉ូលីយ៉ា មិនសោកស្ដាយសញ្ញាបត្របាក់ឌុបមួយនោះទេ បើសិនជាអំពើអយុត្តិធម៌តម្រូវឲ្យខ្ញុំដើរចូលគុកហើយ ខ្ញុំបាននិយាយការពិតខ្លះៗនៃទឹកចិត្តខ្ញុំ ប្រាប់គេតែមួយម៉ាត់ដែលមានសុភវិនិច្ឆ័យគ្រប់គ្រាន់ ខ្ញុំសប្បាយជាងរស់នៅក្នុងផ្ទះដ៏សុខសាន្ដតែសំបកក្រៅនេះទៅទៀត !

ចប់សម្ដីស្រីបោះជំហានទាំងគ្មានលំនឹងឡើងទៅលើផ្ទះបាត់ ។

..............................និយាយមកដល់ត្រឹមនេះសុជាតិឃើញនាងមានទឹកភ្នែកហូរចុះមករហាមពេញថ្ពាល់ដ៏រលោង សេចក្ដីឈឺចាប់ឡើងដល់កម្រិតមួយ កំលោះសែនអាណិតនាងណាស់ គេវាចាតិចៗ :

- ម៉ូលីយ៉ា អតីតកាលដែលបានកន្លងផុតទៅ វាបានបង្កប់គ្រប់បែបយ៉ាង អំពើល្អ ក្តីសប្បាយរីករាយនិងការឈឺចាប់ រូបខ្ញុំក៏ដូច្នោះដែរ យើងត្រូវតែចេះលួងលោមចិត្តរបស់ខ្លួនដោយខ្លួនឯង ។ ដូច្នេះម៉ូលីយ៉ាមិនត្រូវអស់សង្ឃឹមសម្រក់ទឹកភ្នែកច្រើនពេកទេ ព្រោះមួយជីវិតមនុស្សតែងតែជួបប្រទះការលំបាកស្មុគស្មាញខ្លះជាមិនខាន ឲ្យតែម៉ូលីយ៉ាប្រកាន់ជាប់នូវសច្ចភាព មានការវិនិច្ឆ័យតស៊ូគ្រប់គ្រាន់ ខ្ញុំជឿថាឆាកជីវិតរបស់នាង ពិតជាលែងជួបប្រទះនឹងភាពលំបាកក្នុងជីវិតទៀតហើយ !

ម៉ូលីយ៉ាទឹកទៅដូចជាខ្មាសអ្នកកំលោះជាអនេក សម្តីគេបានន័យថា នាងជាមនុស្សមិនចេះអត់ធន់យកទឹកភ្នែកធ្វើជាធំ ។ យល់ថានាងដូចជាមិនពេញចិត្តនឹងសម្តីរបស់ខ្លួន សុជាតិក៏ពោលថា :

- ម៉ូលីយ៉ា នាងខឹងនឹងខ្ញុំមែនទេ ? ខ្ញុំគ្មានបំណងបន្ទោសបង្អាប់នាងទេ ខ្ញុំគ្រាន់តែជួយរំលឹកបំភ្លឺភាពស្មុគស្មាញក្នុងចិត្តរបស់នាងខ្លះតែប៉ុណ្ណោះ !

- ខ្ញុំមិនខឹងនឹងលោកទេ ផ្ទុយទៅវិញខ្ញុំរឹតតែអរគុណចំពោះលោកទ្វេឡើង ព្រោះសម្តីរបស់លោកអាចធ្វើឲ្យខ្ញុំភ្ញាក់ខ្លួនចេញពីភាពកំសាកមិនចេះអធននេះបាន !

- អីចឹងនាងនិយាយទៅទៀតចុះ ព្រោះសាច់រឿងរបស់នាងធ្វើឲ្យខ្ញុំចង់ដឹងជាខ្លាំង !

ម៉ូលីយ៉ាសម្លឹងមុខនរៈយើងបន្តិចទើបចាប់ផ្ដើមបន្តសាច់រឿងទៅមុខទៀត.....!.....!

..........តាំងតែពីម៉ូលីយ៉ា បានក្លាយជាគូដណ្ដឹងរបស់អ្នកប្រុសបូរីយ៉ាងពេញមុខមក ក្រោមការយល់ឃើញរបស់បិតាមាតាចំពោះកូនស្រីមកជាហេតុធ្វើឲ្យអ្នកសំអឿនកាន់តែក្ដៅក្រហាយខ្លាំងឡើង... គាត់ស្វែងរកវាល់មធ្យោបាយដើម្បីកម្ចាត់ម៉ូលីយ៉ាចេញពីបូរី ព្រោះអនាគតភរិយាអ្នកកាសែតអន្តរជាតិ ពិតជាមានវាសនាខ្ពស់ជាងកូនសម្លាញ់របស់គាត់ទៅទៀត ។

រាត្រីរនោចធម្មជាតិជុំវិញគេហដ្ឋាន មានសភាពខ្មៅងងឹតស្ទើរតែចាក់ភ្នែកមិនយល់ ដោយស្បៃអន្ធិកាគ្របដណ្ដប់មកជិតស្លុប ។

ជំនោររាត្រីបក់បោកយ៉ាងកំណាច ហាក់សម្ដែងពីប្រផ្នូលអ្វី១ ម៉ូលីយ៉ាហាក់ព្រួយចិត្តយ៉ាងចម្លែក នាងបន់ឲ្យតែដល់ថ្ងៃរៀបការតែម្ដង ព្រោះស្រីហាក់ដូចជាឃើញឧបសគ្គនៃការឈ្នានីសរបស់ម្ដាយចុងកាន់តែច្បាស់ឡើងៗ ។ ថ្ងៃប្រឡងក៏កាន់តែខិតជិតមកដល់ហើយ តែថ្ងៃអាពាហ៍ពិពាហ៍វាងនៅយូរបន្តិចដែរ ទុក្ខព្រួយរបស់ស្រីធ្វើឲ្យនាងចុះស្គមយ៉ាងច្រើន មេឃខ្មៅកាន់តែខ្លាំងឡើង មាណវីចាប់សៀវភៅមកមើលបន្តទៀត តែត្រូវអាក់សកម្មទៅវិញព្រោះស្នូរគោះទ្វារបានលាន់ឡើង !

តុក...តុក...តុក...!

- ម៉ូលីយ៉ា ម៉ូលីយ៉ា !

- អ្នកមីងឬ ?

- អី...ចេញមកណេះមួយភ្លែត មីងមានការបន្តិច !

សម្តីល្អគ្មានរម៉ាំងរម៉ោកយ៉ាងចម្លែកនេះ ម៉ូលីយ៉ាហាក់មានការមិនទុកចិត្តសោះ ស្រីតូចរាងអល់អែកនៅក្នុងចិត្តយូរណាស់ទើបនាងបើកទ្វារចេញមកជួបម្តាយចុង !

- ម៉េចក៏យូរម្ល៉េះ ?

មាណវីមិនឆ្លើយនឹងសំណួរនេះទេនាងបែរមកសួរអ្នកសំអឿនទៅវិញ :

- អ្នកមីងហៅខ្ញុំមានការអីដែរ ?

- អី...ជូនមីងទៅក្រោមមួយភ្លែត មីងភ្លេចសាខោអាវដែលបោកពីថ្ងៃនោះ ប្រហែលជាសាចទទឹកអស់ហើយ !

- តែខ្ញុំដូចជាឃើញវ៉ារីសាអស់ហើយទេតើអ្នកមីង !

- វ៉ាសាមិនអស់ទេ ហើយមីងត្រូវទៅមើលអីវ៉ាន់ផ្សេងៗផង!

- យប់ងងឹតណាស់អ្នកមីង ខ្ញុំដូចជាញញើតណាស់ !

- វាគ្មានអ្វីគួរឲ្យខ្លាចទេ មីងចុះទៅជាមួយដែរទេតើ !

- ចាស ខ្ញុំរៀបអីវ៉ាន់សិនក្រែងវាប៉ើងក្រដាស !

- អី...មីងចាំនៅមាត់ទ្វារ ឲ្យលឿនបន្តិចទៅណា៎ !

ស្រស់ស្រីនាងដើរចូលទៅក្នុងវិញទាញក្រដាសមួយសន្លឹកមក

សរសេរទាំងប្រញាប់ប្រញាប់ មានសេចក្តីថា :

.....................

*មុននឹងសម្រេចអ្វីមួយ សូមបងបូរីពិចារណាឲ្យគ្រប់ហេតុផលទាំងអស់ រឿងអ្វីដែលបងបានដឹងមិនត្រូវនិយាយប្រាប់គេទេ ហើយសម្តីដែលគេនិយាយមក បងក៏មិនត្រូវជឿទាំងអស់ដែរ ។*

*ម៉ូលីយ៉ា*

.........................

សរសេរចប់ តូចតន់បត់វាស៊កចូលក្នុងសៀវភៅទស្សនវិជ្ជាសូក្រាត ដែលបូរីចូលចិត្តអាននៅពេលដែលគេមកលេងជាមួយនឹងស្រីម្តងម្កាល ។

ចំណែកអ្នកសំអឿនវិញឈរចាំនាងទាំងចិត្តអន្ទះសា ចុះទៅដល់ដីស្រីសែនវន្ទត់ ព្រោះគ្មានសម្លៀកបំពាក់ដែលសេសសល់ដូចពាក្យម្តាយចុងថានោះឡើយ ! តើគាត់មានបំណងបែបណាទៅ ? ម៉ូលីយ៉ាមិនទុកចិត្តទេ នាងត្រៀមខ្លួនបម្រុងរត់ឡើងមកលើវិញ ស្រាប់តែយុវជន២រូបមកបិទមាត់នាងជាប់ដោយផ្ទាំងក្រណាត់មួយផ្ទាំង ទោះបីជាស្រីប្រឹងរើបម្រះយ៉ាងណាក៏ឥតប្រយោជន៍ដែរ ? រីឯអ្នកសំអឿនឡើងទៅលើវិញបាត់ យុវជនកំណាចទាំងពីរបានចាប់នាងដាក់ទៅលើរថយន្តបើកចេញទៅមួយរំពេច ។ ស្អែកឡើងម៉ូលីយ៉ាត្រូវគេនាំមកដល់មង្គលបូរីក្នុងន័យជាទំនិញដាច់មុខរបស់ឈ្មួញអយុត្តិធម៌ពុករលួយ

ម្នាក់ឈ្មោះប៊ុន ក្តីអស់សង្ឃឹមក៏កើតមានឡើងពេញដួងចិត្តរបស់នាង ផ្លូវដោះស្រាយមានតែមួយគត់ គឺត្រូវបញ្ចប់ជីវិតយ៉ាងកំសាកបំផុត ។

នៅក្នុងបន្ទប់ដ៏វិចិត្រនេះម៉ូលីយ៉ារុករើគ្រប់កន្លែង ដើម្បីស្វែងរកឧបករណ៍សម្រាប់ធ្វើអត្តឃាត ដើម្បីកុំឲ្យយល់នូវអំពើព្រៃផ្សៃជួរចត់មួយដែលគេបានផ្តល់សម្រាប់ជីវិតនាង ។ ពិភពលោកថ្មីត្បិតតែធំធេងពិតជាមិនធុញទ្រាន់នឹងការទ្រទ្រង់របស់សត្វលោក ដែលជ្រកកោននៅក្រោមបាទាលោកឡើយ ។

រថយន្តធុនតូចមួយគ្រឿងបានមកឈប់ពីមុខគេហដ្ឋាននេះ គឺជាស្ត្រីម្នាក់ ដែលមានគ្រឿងអលង្ការ និងសម្លៀកបំពាក់យ៉ាងទាន់សម័យបំផុត ម៉ូលីយ៉ាលួចមើលស្ត្រីនោះតាមបង្អួចបានតែមួយភ្លែត គេក៏ចូលទៅក្នុងបន្ទប់ទទួលភ្ញៀវបាត់ ។

ប្រហែលជា១ម៉ោងក្រោយមក ទើបឮសម្រឹបជើងមនុស្សពីរនាក់ដើរតម្រង់មកបន្ទប់នាង ! ម៉ូលីយ៉ាសែនភិតភ័យលើសពេលណាទាំងអស់ ទ្វាររបើកឡើងលេចស្រីពាក់កណ្តាលវ័យអម្បាញ់មិញនោះ និងលោកប៊ុន ដែលលើកដៃបង្ហាញដល់អ្នកស្រីហ៊ឺហានេះហើយក៏ចេញទៅវិញបាត់ដែរ ។

អ្នកស្រីដែលយើងមិនទាន់ស្គាល់ឈ្មោះ សម្លឹងមើលមកស្រស់ស្រីទាំងញញឹម ហើយដើរមកអង្គុយជិតនាងទាំងសួរថា :

- ក្មួយស្រីមានឈ្មោះអីដែរ ?

- ចាស ម៉ូលីយ៉ា !

- ម៉ូលីយ៉ាក្មួយ...ពិតជាមានសំណាងណាស់ហើយ មីងមកនេះគឺមកសុំទិញរូបក្មួយយកទៅនៅជាមួយមីងឯភ្នំពេញ ព្រោះតែមីងគ្មានកូននឹងគេ ក្មួយដឹងទេកន្លែងនេះជាកន្លែងទិញមនុស្ស តែថៃជន្យឬក៏ជាព្រេងវាសនាដ៏ល្អរបស់ក្មួយហើយ ព្រោះតែបន្តិចទៀតរូបក្មួយនឹងក្លាយទៅជាស្រីពេស្យា តែមីងបានដំណឹងថាមានគេចាប់ស្រីម្នាក់យកមកលក់នៅផ្ទះលោកប៊ុននេះ ទើបមីងមកជួបនឹងគាត់ហើយសុំទិញយកទៅនៅជាមួយតែម្តងទៅ ដល់ឃើញរូបក្មួយទៀតមីងរឹតតែពេញចិត្តទ្វេឡើង !

- អ្នកមីង បើអ្នកមីងមានចិត្តសប្បុរសយ៉ាងនេះសូមអ្នកមីងអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញចុះ ខ្ញុំនឹងជូនសោហ៊ុយដល់អ្នកមីងដែលអ្នកមីងទិញនេះចំពោះអ្នកមីងវិញ ! គុណបំណាច់ទាំងនេះខ្ញុំចងចាំមិនភ្លេចទេ !

- បានប្រយោជន៍អីដែលក្មួយត្រូវត្រឡប់ទៅផ្ទះវិញនោះតាមសាច់រឿងដែលមីងបានដឹងទាំងអស់ ព្រោះលោកប៊ុនបាននិយាយប្រាប់មីងគ្រប់យ៉ាងរួចហើយ !

- ខ្ញុំចង់វៃកញ្ចែកចំពោះអំពើល្អនិងអាក្រក់ !

- ក្មួយធ្វើយ៉ាងនេះមិនកើតទេ បើគេមានបំណងអាក្រក់មកលើក្មួយទៅហើយ ទោះជាក្មួយឈ្នះគេក្នុងពេលនេះ ក៏ពេលក្រោយ

គេនៅតែរិះរកមធ្យោបាយឈ្នានីសក្មួយដដែលជាដដែល ទៅនៅជាមួយនឹងមីងមិនខ្វះសេចក្តីសុខនោះទេ ព្រោះមីងគ្មានកូនឯណាសម្រាប់ឲ្យមកច្រណែនឈ្នានីសឡើយ សូមក្មួយសម្រេចចិត្តទៅ !

ម៉ូលីយ៉ាងើបភ័ក្ត្រដ៏ផូរផង់សម្លឹងចំអ្នកស្រីឆើតឆាយក្នុងន័យអង្វរករ :

-អ្នកមីងអនុញ្ញាតឲ្យខ្ញុំទៅជួបជាមួយនឹងលោកប៉ាខ្ញុំមួយភ្លែតបានទេ ?

- ចង់ទៅធ្វើអីក្មួយស្រី ឯងមិនចេះគិតទេឬ បើគេស្អប់ក្មួយដល់ថ្នាក់នេះទៅហើយ គេនឹងរកវិធីកម្ចាត់ក្មួយឲ្យទាល់តែបាន ក្នុងសម័យនេះគេប្រើទឹកប្រាក់ជាធំមីងមិនបង្ខំក្មួយទេ រឿងនេះស្រេចតែលើក្មួយសម្រេចចិត្តដោយខ្លួនឯងទៅចុះ !

ស្រស់ស្រីនាងសញ្ជឹងគិតបន្តិច ទីបំផុតក៏សម្រេចទៅតាមអ្នកស្រីគន្ធានេះតែម្តង ។

................និយាយដល់ត្រង់នេះស្រីបង្អាក់សម្តីបន្តិច សុជាតិអង្គុយភ្លឹកព្រោះកំពុងតែស្លុងអារម្មណ៍ទៅនឹងសាច់រឿងដ៏កម្សត់របស់ស្រី ទាល់តែម៉ូលីយ៉ាបញ្ជាក់ :

- រឿងខ្ញុំចប់តែប៉ុណ្ណេះហើយ ព្រោះបានជួបនឹងលោក តែតទៅមុខទៀតមិនដឹងជាមានរឿងអ្វីកើតឡើងនោះទេ ជីវិតកូនកំព្រាត្រូវតែឃ្លាតឆ្ងាយពីអ្វីៗទាំងអស់ដែលជាទីស្រឡាញ់ប៉ងប្រាថ្នា !

អ្នកប្រុសហាក់គ្មានស្តាប់សម្តីស្រីទេ គេឆ្លើយតបថា :

- ខ្ញុំធានានឹងស្វែងរកគូដណ្តឹងរបស់អ្នកនាងយកមកប្រគល់ឲ្យអ្នកនាងជួបគ្នាវិញ សូមនាងកុំអស់សង្ឃឹមអី !

- ហួសពេលហើយ ខ្ញុំគ្មានសេចក្តីប្រាថ្នាយ៉ាងនេះទេ !

- មិនទាន់ហួសពេលទេម៉ូលីយ៉ា បងប្រុសបូរីពិតជានៅរង់ចាំនាងជានិច្ច !

-ទោះជាគាត់នៅរង់ចាំខ្ញុំក៏ខ្ញុំមិនវិលទៅជួបគាត់វិញទៀតដែរ ព្រោះរយៈពេលជាង២ខែនេះ អ្វីៗវាបានកន្លងហួសអស់ទៅហើយ ជាពិសេសគឺភាពស្ងប់ស្ងាត់នៅក្នុងដួងចិត្តរបស់ខ្ញុំ !

- អ៊ីចឹងនាងមិនស្តាយអាពាហ៍ពិពាហ៍របស់នាងទេឬ ?

- ចាស ប្រាកដជាស្តាយ តែវាផុតពីសេចក្តីប្រាថ្នាយ៉ាងស្រឡះដូចជាផ្កាយរះនៅលើផែនដីអ៊ីចឹងឯង រៀងរាល់ថ្ងៃខ្ញុំបានជួបសុភមង្គលត្រឹមនេះវាជាការស្រមៃតែប៉ុណ្ណោះ ដើម្បីសងគុណដល់លោកវិញ ខ្ញុំសុខចិត្តលះបង់អ្វីៗទាំងអស់ ខ្ញុំលែងត្រូវការអ្វីទៀតហើយ !

- តែខ្ញុំមិនត្រូវការសងគុណអ្វីពីនាងនោះទេ ! សូមនាងកុំគិតថាខ្ញុំទើសទាល់ក្នុងការទទួលនាងឲ្យមករស់នៅទីនេះ ឬក៏មិនមានការអនុញ្ញាតឲ្យនាងចេញទៅនៅឯណានោះ ។ ឥឡូវនេះនាងសម្រេចចិត្តទៅ ចង់ទៅទីណាក៏បានដែរ ចង់ត្រឡប់ទៅវិញក៏បាន ព្រោះនាងមានកម្រិតវប្បធម៌ខ្ពង់ខ្ពស់អាចគិតគូរអ្វីក៏បាន ចំណែកសោហ៊ុយដែល

ចំណាយក្នុងការធ្វើដំណើរ ឬក៏ត្រូវការផ្តួងផ្តើមក្នុងការកសាងជីវិតជាថ្មី បើសិនជានាងចង់រស់នៅម្នាក់ឯងនោះ ខ្ញុំអាចជួយសម្រួលនាងបាន ដោយមិនគិតពីគុណស្រ័យអ្វីទាំងអស់ !

ម៉ូលីយ៉ាងើបភ័ក្ត្រសម្លឹងចំអ្នកប្រុសទើបវាចា :

-ខ្ញុំបានសម្រេចចិត្តត្រឹមត្រូវហើយ គឺខ្ញុំសុំរស់នៅទីនេះជាមួយនឹងលោកដែរ ទោះជាស្ថិតនៅក្នុងឋានៈជាអ្វីក៏ដោយខ្ញុំពេញចិត្តជានិច្ច

- បើចង់យ៉ាងនេះខ្ញុំពិតជាត្រេកអរណាស់ ព្រោះការរស់នៅម្នាក់ឯងមិនខុសីពីអ្នកទៅបួសនៅក្នុងព្រៃឬរូងភ្នំដាច់ស្រយាលឆ្ងាយពីសង្គមដែលឱបរឹតនូវបញ្ហារាប់ជំពូក ព្រោះការស្ងប់ស្ងាត់ខាងក្រៅមិនអាចធ្វើឲ្យអារម្មណ៍ខាងក្នុងស្ងប់ស្ងាត់បានទេ ។ ផ្ទុយទៅវិញវាធ្វើឲ្យយើងរំលឹកឡើងវិញរាល់បញ្ហាទាំងអស់ ។ ឥឡូវនាងចូលសម្រាកចុះ ព្រោះម៉ោង១២ទៅហើយក្រែងលោរំខានដល់សុខភាពរបស់នាង !

ម៉ូលីយ៉ាមិនមាត់កអ្វីទាំងអស់ នាងដើរចូលទៅក្នុងបន្ទប់វិញក្រោមការតាមសម្លឹងមើលមិនដាក់ភ្នែករបស់អ្នកកំលោះសុជាតិ គេញញឹមស្រស់តែម្នាក់ឯងដោយគ្មានមូលហេតុ ទើបគេត្រឡប់ទៅក្នុងបន្ទប់របស់គេវិញដែរ ព្រោះក្រឹត្យក្រមរាត្រីមិនអនុញ្ញាតឲ្យគិតបញ្ហាអ្វីទៅទៀតបានទេ ។

គ្នាមិនស្ទាត់សួរដែរ ជិតដល់ម៉ោងខ្ញុំទៅធ្វើការហើយ នាងយកប្រាក់នេះទៅទិញអ្វីក៏បានដែរ !

ស្រដីចប់គេក៏ឡើងម៉ូតូចេញទៅបាត់ ស្រស់ស្រីនាងដូចជាស្ទាក់ស្ទើរនៅក្នុងចិត្តសឹងតែមិនហ៊ានចេញទៅផ្សារខ្លាចជួបនឹងអ្នកស្រីគន្ធាចិត្តអប្រិយនោះទៀត តែកាលៈទេសៈតម្រូវឲ្យលះបង់សេចក្ដីខ្លបខ្លាចគ្រប់អ្វីៗទាំងអស់ដើម្បីឲ្យបានផ្គាប់ចិត្តបុរសចិត្តធម៌ម្នាក់ដែលនាងបានជួបប្រទះជាលើកដំបូង នាងត្រូវតែហ៊ានពុះពារ ។ ចំពោះបូរីនាងលែងនឹកនាទៀតហើយ នាងមិនស្ដាយរូបគេទេ ព្រោះជាស្នេហាដំបូងដែលកើតមាននៅក្នុងចិត្តរបស់នាង ហើយត្រឹមត្រូវសមស្របតាមប្រពៃណីពិតប្រាកដ ។

ម៉ោង១១និង២៥នាទីទៅហើយ សុជាតិត្រឡប់មកពីធ្វើការវិញ អ្នកប្រញាប់ចូលទៅផ្ទះបាយដើម្បីបានយល់ស្នាដៃរបស់នាង ដែលជាមេផ្ទះថ្មី ម៉ូលីយ៉ារៀបបាយដាក់លើតុពាសពេញមានមុខម្ហូបគួរឲ្យឈ្ងុយឆ្ងាញ់ ។

អ្នកប្រុសធ្វើមុខញញឹមជាប់ហើយសួរទៅនាង :

- ម្ហូបនេះប្រាកដជាឆ្ងាញ់ណាស់មែនទេ ម៉ូលីយ៉ា ខ្ញុំមិននឹកស្មានថានិស្សិតដូចរូបនាងប្រសប់ធ្វើម្ហូបដល់ថ្នាក់ហ្នឹងសោះ មិនដឹងជាឆ្ងាញ់យ៉ាងណាទេ !

- ទាល់តែលោកពិសាសាកមើលសិនទើបដឹង !

- បើតាមទ្រង់ទ្រាយពីក្រៅប្រហែលជាឆ្ងាញ់ហើយ !

ពោលបណ្តើរគេដើរចូលទៅក្នុងបន្ទប់វិញផ្លាស់សម្លៀកបំពាក់រួច សុជាតិអង្គុយបរិភោគបាយទល់មុខនឹងម៉ូលីយ៉ាដែរ ។ ញ៉ាំបានពីរបីម៉ាត់ គេងើបឡើងសម្លឹងមុខនាងហើយនិយាយថា :

- ម៉ូលីយ៉ា ម្ហូបនេះឆ្ងាញ់ណាស់ ! នាងពិតជាប្រសប់ធ្វើមែន ខ្ញុំសុំសរសើរដោយស្មោះណា៎ !

- ចាស ស្រេចតែលោកយល់ឃើញទេ តែបើថ្ងៃនេះឆ្ងាញ់ យូរៗទៅប្រាកដជាលែងឆ្ងាញ់ហើយ !

- ម៉េចអ៊ីចឹងទៅវិញ ឬមួយនាងធ្វើនេះដើម្បីតែបង្ហួតស្នាដៃប្រាប់ខ្ញុំជាលើកដំបូងទេ !

- ចាស ថាអ៊ីចឹងក៏បានដែរ តែខ្ញុំគ្មានចិត្តថាធ្វើម្ហូបនេះដើម្បីបង្ហួតស្នាដៃនៅចំពោះមុខលោកនោះទេ ជាធម្មតាអ្វីដែលគេបានជួបប្រទះជាលើកដំបូងនោះ ទោះឆ្ងាញ់ក្តីមិនឆ្ងាញ់ក្តី ក៏គេទទួលស្គាល់ថាឆ្ងាញ់ដែរ ដល់ពេលដែលគេនឹកធុញទ្រាន់ គឺព្រោះតែបានជួបជាញឹកញាប់រួចមកហើយ !

- អ៊ីចឹងបានសេចក្តីថានាងធ្វើម្ហូបតែពាមុខនេះទេ ហើយនាងនឹងធ្វើម្ហូបនេះជារាល់ថ្ងៃដែរមែនទេ ?

- ចាស ទោះជាលើសពីនេះក៏រសជាតិវាមិនហួសគ្នាដែរ បានសេចក្តីថាអ្វីដែលលោកបានយល់និងស្គាល់ក្នុងពេលនេះ លោកជួបវា

រាល់ថ្ងៃនៅពេលខាងមុខទៀត វាក៏មិនផ្លាស់ប្ដូរអត្ថន័យនៃឱជារស របស់វាប៉ុន្មានដែរ !

- ម៉ូលីយ៉ា នាងសម្បូរទ្រព្យស្ដីណាស់ តែកុំនាំខ្ញុំនិយាយច្រើន ពេក ញ៉ាំបាយហើយនាងទៅជួបខ្ញុំនៅលើកៅអីបង់ខាងមុខ ព្រោះខ្ញុំ មានរឿងមួយពិសេសសំខាន់ណាស់សម្រាប់នាង !

- ចាសលោក !

នាងមិនហ៊ាននិយាយអ្វីទៀតទេ ព្រោះខ្លាចរំខានការបរិភោគ របស់អ្នកប្រុស ។ ពេលដែលបាយរួចហើយគេចូលទៅទម្រេតខ្លួននៅ ក្នុងបន្ទប់រហូតដល់លង់លក់ ព្រោះថ្ងៃនេះគេមានការនឿយហត់ជា ច្រើនក្នុងការវះកាត់អ្នកជំងឺ ចំណែកមូលីយ៉ានាងចុះទៅអង្គុយចាំតែ ឥតហ៊ានធ្វើកិច្ចការអ្វីទេ ។ មួយម៉ោងបានកន្លងផុតទៅនៅមិនទាន់ ឃើញសុជាតិចេញមកសោះ ! តួចតន់មិនពេញចិត្តនឹងអាកប្បកិរិយា ទាំងនេះទេ ទោះបីរូបគេជាមនុស្សដែលនាងត្រូវតែគោរពដូចជាឪពុក យ៉ាងណាក៏ដោយ ព្រោះមនុស្សដែលមិនគោរពពាក្យសម្ដីរបស់ខ្លួន ពិតជាពិបាកឲ្យនាងមានទំនុកចិត្តណាស់ ថ្ងៃនេះគេកុហកនាងប៉ុណ្ណឹង ចុះទម្រាំរស់នៅជាមួយគ្នារាល់ថ្ងៃ រាល់ឆ្នាំតទៅមុខទៀត តើវាយ៉ាង ម៉េចទៅវិញដែរ ។ ចំណែកសុជាតិ អ្នកមិនមានបំណងគេងលក់យ៉ាង នេះទេ តែដោយភាពអស់កម្លាំងខ្លាំងពេក យូរណាស់ទម្រាំពេលភ្ញាក់ ខ្លួនពីការលង់លក់នេះអ្នកកំលោះលើកនាឡិកាមើលចង្អុលទ្រនិចម៉ោង

៧និង៣០នាទី គេរហ័សសម្អាតខ្លួនប្រាណ ស្លៀកពាក់ស្អាតបាតជាស្រេចចេញមកក្រៅ ឃើញម៉ូលីយ៉ាអង្គុយនៅលើបង់ជាស្រេច ភ្នែកនាងសម្លឹងទៅឆ្ងាយទាំងអារម្មណ៍ហាក់មិននៅនឹងខ្លួន ។

សុជាតិផ្ដើមនិយាយទៅកាន់នាងទាំងមិនមើលមុខថា :

- ម៉ូលីយ៉ា នាងចាំខ្ញុំនៅទីនេះយូរហើយមែនទេ ?

- ចាសយូរមែន តែវាជាការធម្មតាទេ ខ្ញុំគ្មានធុញទ្រាន់អ្វីទាំងអស់ !

- ខ្ញុំឃើញនាងរៀបចំទុកដាក់ចានឆ្នាំង ក៏ទម្រេតខ្លួនបន្ដិចទៅលក់បណ្ដោយ នាងប្រហែលជាអន់ចិត្តនឹងខ្ញុំហើយមើលទៅ !

ស្រស់ស្រីគ្រវីក្បាល :

- មិនអន់ចិត្តទេលោក ព្រោះជាអំពើអចេតនា គេមិនអាចចាត់ទុកថាជាកំហុសបានឡើយ !

- ម៉ូលីយ៉ាខ្ញុំចង់ឲ្យនាងចូលរៀនវិញ ដើម្បីប្រឡងសញ្ញាបត្របាក់ឌុប ខ្ញុំនឹងរកការងារឲ្យនាងធ្វើ តើនាងយល់យ៉ាងណាដែរ ?

- ចាស ខ្ញុំយល់ថាលោកជាមនុស្សមានសន្ដានចិត្តល្អចំពោះខ្ញុំយ៉ាងលើសលប់ តែបើសិនជាចូលរៀន ខ្ញុំមិនអាចបំពេញកិច្ចការសម្រាប់លោក ឲ្យសមនឹងចិត្តដែលខ្ញុំបានគ្រោងទុកនោះទេ !

- នៅក្នុងផ្ទះនេះគ្មានកិច្ចការអ្វីសំខាន់ រហូតដល់ចាំបាច់ទាមទាររូបនាងឲ្យបំពេញនោះទេ ចំណែកបាយទឹកចាំត្រឡប់មកពីធ្វើការ

វិញសឹមដាំក៏បានដែរ ព្រោះកាលពីមុនមកខ្ញុំទម្លាប់អ៊ីចឹងទៅហើយឬមួយនាងខ្លាចរំខានរៀនមិនកើត ?

- ចាស មិនមែនអ៊ីចឹងទេលោក ខ្ញុំមិនដែលនឹកនាទៅដល់ការនឿយហត់អ្វីទាំងអស់ ផ្ទុយទៅវិញខ្ញុំបារម្ភក្រែងរំខានដល់លោកតែប៉ុណ្ណោះ !

- ខ្ញុំមិនទើសទាល់ទេ ឲ្យតែនាងព្រមចូលរៀនវិញ និងចេញធ្វើការនៅពេលខាងមុខនេះខ្ញុំរីតតែត្រេកអរ ព្រោះការដែលទទួលនាងមកគ្រប់គ្រងយ៉ាងនេះ វាងាយស្រួលតែក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះ ចំណែកថ្ងៃអនាគត គឺពេលដែលខ្ញុំរៀបចំឆាកជីវិតនោះ នាងពិតជាខ្វះសេចក្តីសុខច្រើន ទោះបីជាខ្ញុំប្រឹងប្រែងធានាជីវភាពក្នុងគ្រួសារយ៉ាងណាក៏ដោយ បញ្ហានេះនាងគួរតែយល់ហើយ !

ម៉ូលីយ៉ាងើបមុខសម្លឹងចំអ្នកប្រុសទាំងបន្តសម្តីមួយៗថា :

- ខ្ញុំពេញចិត្តបម្រើលោកនិងប្រពន្ធលោកគ្មានគិតពីការនឿយហត់ ទោះជាការរស់នៅខ្វះសេចក្តីសុខយ៉ាងណាក៏ដោយ !

- ខ្ញុំមិនចង់ឲ្យនាងដាក់ខ្លួនអ៊ីចឹងពេកទេ ណ្ហើយ... ឥឡូវបើនាងមិនហ៊ានសម្រេចចិត្តទេ ខ្ញុំសម្រេចចិត្តជំនួសនាងចុះ យ៉ាងយូរមួយអាទិត្យទៀតនាងបានចូលរៀនហើយ ចំណែកសម្ភារៈសម្លៀកបំពាក់សម្រាប់សិស្សនោះខ្ញុំនឹងគិតគូរមិនឲ្យខ្វះទេ !

ដល់ម៉ោងធ្វើការគេបញ្ជាម៉ូតូចេញទៅ ទាំងមិនរង់ចាំនូវការ

ឆ្លើយតបរបស់ម៉ូលីយ៉ាឡើយ ។ តូចតន់មិនអស់ចិត្តសោះចំពោះការយកចិត្តទុកដាក់របស់គេមកលើរូបនាង មិនដឹងជាមានគោលបំណងយ៉ាងណាខ្លះ ? តើនាងត្រូវនៅទីនេះរហូតឬក៏ត្រូវស្វែងរកបូរីឲ្យទាល់តែឃើញ ចិត្តនៅតែអល់អែកមិនដាច់ស្រេចសោះ ។

យប់ថ្ងៃ ថ្ងៃយប់ប្តូរវេនគ្នាជាបន្តបន្ទាប់ ម៉ូលីយ៉ាក៏បានចូលទៅបន្តវិជ្ជាទៀតនៅវិទ្យាល័យទួលគោក ។ រាល់ពេលដែលស្រីនាងចេញទៅសាលានិងរាល់ពេលដែលសុជាតិចេញពីធ្វើការ គេទាំងពីរតែងចូលចម្អិនម្ហូបអាហារទាំងពីរនាក់ ។

ម៉ូលីយ៉ាបានចេញមុនសុជាតិ១ម៉ោង នាងប្រញាប់ចូលទៅធ្វើអាហារនៅក្នុងផ្ទះបាយ កំពុងលាងអង្ករយ៉ាងញាប់ដៃ សុជាតិក៏មកដល់ល្មម អ្នកប្រុសមិនផ្លាស់សម្លៀកបំពាក់ចេញទេ ដើរបង្ហួសមកផ្ទះបាយតែម្តង ។

នរៈឈរច្រត់ចង្កេះសម្លឹងនាងស្រីមិនដាក់ភ្នែក !

- ម៉ូលីយ៉ា !

យុវកញ្ញាងាកមុខមកដោយភ្ញាក់ផ្អើល យល់ភ័ក្រ្តអ្នកកំលោះយ៉ាងចម្លែកធ្វើឲ្យនាងភ័យនៅក្នុងចិត្ត !

- អ្នកណាជូននាងមកផ្ទះ ? ( គេបន្តសំណួរទៅនាងទៀត )

- ចាស គឺមិត្តរួមថ្នាក់របស់ខ្ញុំ !

នរៈដើរទៅជិតនាងទាំងរក្សាទឹកមុខមាំដដែល !

- ក្នុងរយៈពេលតែមួយអាទិត្យសោះ ខ្ញុំមិននឹកស្មានថានាងអាចទាក់ទងស្គាល់មិត្តភក្តិប្រុសបានរហ័សយ៉ាងនេះសោះ !

ម៉ូលីយ៉ាបើកភ្នែកធំៗទាំងភ្ញាក់ ហេតុអីក៏គេប៉ិនដឹងម្ល៉េះ ? ( ស្រីឆ្ងល់នៅក្នុងចិត្ត )

- យ៉ាងម៉េច ! នាងភ្ញាក់ផ្អើលណាស់ទៅឬ ? ខ្ញុំគ្មានបំណងតាមដាននាងដល់ម្លឹងទេ តែវាចំពេលចៃដន្យដែលខ្ញុំមិនចង់ឃើញព្រឹត្តិការណ៍បែបនេះ ហើយវាជួបតែម្តងទៅ ! សេរីភាពនាងមានគ្រប់គ្រាន់ណាស់ចង់នាងរកមិត្តភក្តិបានប៉ុន្មានកញ្ចេ ក៏ខ្ញុំមិនថាអីដែរ តែនាងគួរតែយល់ថាមនុស្សម្នាក់ៗដែលទើបតែស្គាល់ដំបូង នាងមិនត្រូវមានការទុកចិត្តទាំងស្រុងពេកទេ ហើយបុរសនៅភ្នំពេញនេះសម្បូរជើងឆើតបន្តិចផង ខ្ញុំនិយាយនេះគ្មានបំណងអ្វីចង់ឲ្យនាងមានឆាកជីវិតមិនល្អនោះទេ !

- ជាកំហុសទី១របស់ខ្ញុំនៅចំពោះមុខលោក ខ្ញុំប្រកែកដែរគេនៅតែហៅដដែលៗ កុំឲ្យគេមានការអាម៉ាស់ដោយសារខ្ញុំនិងដើម្បីមកចម្អិនអាហារនោះ ខ្ញុំក៏ព្រមមកជាមួយគេថ្ងៃក្រោយខ្ញុំលែងធ្វើរបៀបនេះទៀតហើយ ! ហើយខ្ញុំក៏មិនទុកចិត្តអ្នកណាទាំងអស់ក្រៅពីរូបលោក គឺសុទ្ធតែមនុស្សស្ថិតនៅក្នុងសេចក្តីមន្ទិលសង្ស័យទាំងអស់ !

- ខ្ញុំមិនឲ្យនាងទុកចិត្តខ្ញុំទេ ព្រោះចរិតមនុស្សវារីកចម្រើនលូតលាស់មិនឈប់ ថ្ងៃនេះនាងថាខ្ញុំល្អនឹងនាង ចុះបើថ្ងៃក្រោយចិត្តខ្ញុំ

វាយ៉ាងណាទៅវិញនោះ ដូច្នេះនាងត្រូវតែប្រុងប្រយ័ត្នខ្លះដែរ !

- ទោះជាខ្ញុំត្រូវខាតអនាគតដោយសារតែរូបលោក ក៏ខ្ញុំមិនតូចចិត្តដែរ ផ្ទុយទៅវិញខ្ញុំរឹតតែពេញចិត្តនឹងអំពើគ្រប់បែបយ៉ាងរបស់លោក ដើម្បីឲ្យខ្ញុំបានបំពេញនូវកាតព្វកិច្ចមួយសមនឹងបំណងរបស់ខ្ញុំ !

- ឈប់និយាយទៅ គំនិតនាងថោកទាបណាស់ម៉ូលីយ៉ា !

ខឹងខ្លាំងសុជាតិក៏ដើរចេញទាំងមុខក្រហម ចំណែកម៉ូលីយ៉ាវិញបែរជាអស់សំណើចក្នុងពោះទៅវិញ ។

បាយឆ្អិនរួចរាល់ហើយ កញ្ញាគ្របទុកលើតុយ៉ាងមានរបៀបរង់ចាំអ្នកកំលោះចូលមកបរិភោគជុំគ្នាដូចសព្វដង តែយូរទៅរឹតតែស្ងាត់ តូចតន់ក៏ដើរសសៀរៗទៅជិតបន្ទប់របស់គេ បាត់សូន្យឈឹងមិនដឹងជាគេទៅឯណាទេ ! នាងដូចជាព្រួយចិត្តចម្លែកមករស់នៅជាមួយគេ គួរណាស់តែយកចិត្តថ្លើមគេ ហេតុអីក៏នាងធ្វើឲ្យគេខឹងអ៊ីចឹង ? ឥឡូវគេមិនមកញ៉ាំបាយទេនាងក៏មិនញ៉ាំដែរ ! សម្រេចចិត្តយ៉ាងនេះហើយ ម៉ូលីយ៉ាក៏ចេញមកអង្គុយលើបង់ក្រោមដើមរុក្ខាទាំងភក្ត្រាស្រីស្រពោនជាប់ ព្រោះទុក្ខព្រួយមិនអាចដកចេញពីខួរក្បាលរបស់នាងបានឡើយ ។

១ម៉ោង ២ម៉ោង ចេះតែកន្លងផុតទៅនៅមិនទាន់ឃើញអ្នកកំលោះត្រឡប់មកវិញទៀត ពោះនាងវាកញ្ជ្រោលទាមទារវត្ថុដែលតម្រូវការក្រពះធ្វើការណាស់ទៅហើយតែនាងស៊ូទ្រាំ ។ សំឡេងម៉ូតូ

តម្រង់ចូលមកដល់ នាងជឿជាក់ថា ជាសុជាតិហើយ តែនាងមិនខ្ជីងាកមើលទេ ទាល់តែស៊ីប្លេទីន១ យ៉ាងខ្លាំងទើបនាងងាកមកតម្រង់ប្រភពសំឡេងយ៉ាងខ្ញិលច្រអូស ! សុជាតិបែរជាសើចស្រស់ជាក់នាងព្រមទាំងសួរឡើងថា :

- ថ្ងៃនេះនាងមិនទៅរៀនទេឬ បានជាស្លៀកពាក់បែបនេះអ៊ីចឹងទៅវិញ ?

- ខ្ញុំនៅចាំលោកមកពិសាបាយ !

អ្នកប្រុសបើកភ្នែកធំៗ :

- នេះបានន័យថានាងមិនទាន់ញ៉ាំបាយទេឬ ?

- ចាស ! ( ស្រីឆ្លើយទាំងឈ្ងោកមុខចុះ )

- ស្លាប់ហើយ ចាំបាច់នៅចាំខ្ញុំធ្វើអីដែរទៅ ខ្ញុំមានការចាំបាច់ដែលត្រូវបំពេញ ឥឡូវនាងរហ័សទៅញ៉ាំទៅ ប្រយ័ត្នខ្យល់ចាប់ណាំ ម៉ោងច្រើនណាស់ទៅហើយ !

- ចុះលោកមិនពិសាទេឬ ?

- ខ្ញុំញ៉ាំរួចហើយ !

គេឆ្លើយទាំងកំបុតរួចដើរចូលទៅក្នុងបាត់ អាកប្បកិរិយាប្រែប្រួលរបស់លោកប្រុសនេះ ធ្វើឲ្យស្រស់ស្រីសែនក្តាញ់ លាយឡំទៅដោយការលំបាកចិត្តសាជាថ្មី ស្រីមិនចូលទៅញ៉ាំបាយទេ នាងនៅតែសំកុកលើបង់ដដែល ។

សុជាតិចូលទៅដេកធ្វើព្រងើយ មួយសន្ទុះធំទើបគេដើរចេញមកក្រៅយល់ម៉ូលីយ៉ាអង្គុយលើបង់ដដែល ធ្វើឲ្យគេភ្ញាក់ផ្អើលក្នុងអារម្មណ៍ខ្លះដែរ គេដើរចូលទៅជិតស្រីហើយសួរឡើង :

- នាងមិនញ៉ាំបាយទេឬម៉ូលីយ៉ា ? ប្រយ័ត្នឈឺណាំ សូមនាងកុំស្មានថាខ្ញុំពេញចិត្តនឹងព្យាបាលជំងឺរបស់នាងឲ្យសោះ !

- ខ្ញុំគ្មានគំនិតយ៉ាងនេះទេលោក ការពិតវាហួសម៉ោងញ៉ាំបាយទៅហើយ ខ្ញុំក៏លែងឃ្លានដែរ !

- បើអីចឹងម៉េចក៏នាងមិនប្រាប់ខ្ញុំផង ខ្ញុំខំអង្គុយចាំនាងរហូតដល់ហួសម៉ោងធ្វើការហើយ គ្មានបានលទ្ធផលអ្វីទាំងអស់ !

- ព្រោះតែលោកចង់ជូនខ្ញុំទៅសាលា ផលវិបាកទាំងនេះខ្ញុំមើលឃើញតាំងពីថ្ងៃនោះ តែលោកបង្ខំខ្ញុំទាំងមិនបានគិតឲ្យបានវែងឆ្ងាយ ឥឡូវជួបប្រទះនូវផលវិបាកយ៉ាងនេះ លោកមិនសមចងចិត្តកំហឹងអីសោះ !

- ហាស...ហាស...ហា...ខ្ញុំមានបំណងឲ្យនាងមានអនាគតល្អ តែផ្ទុយទៅវិញនាងជេរខ្ញុំថាគិតមិនបានវែងឆ្ងាយ តែប៉ុណ្ណឹងក៏ខ្ញុំមិនខឹងដែរ ខ្ញុំសុខចិត្តទទួលខុសទៅចុះ ហើយខ្ញុំក៏លែងខ្វល់ខ្វាយគិតគូរពីរឿងអនាគតរបស់នាងទៀតដែរ ព្រោះគំនិតខ្ញុំពុំបានស៊ីជម្រៅដូចជានាងទេ !

មួយល្ងាចនេះអ្នកប្រុសមិនបានទៅធ្វើការទេ ហើយម៉ូលីយ៉ា

អាចឲ្យខ្ញុំនិយាយការអ្វីបានទៀត ខ្ញុំលានាងសិនហើយ !

ស្រីនោះប្រុងនឹងងើបចេញ តែម៉ូលីយ៉ាមិនដឹងជានឹកឃើញយ៉ាងណាក៏ស្ទុះមកពាំងទ្វារជាប់ :

- ឈប់សិនបងស្រី ! អម្បាញ់មិញនេះបងស្រីចង់និយាយថាខ្ញុំជាស្រីរបស់លោកសុជាតិនោះ តែមិនពិតទេ !

- ចុះការពិតវាយ៉ាងម៉េចទៅវិញ នាងមិនដឹងទេឬ ?

- ខ្ញុំនឹងជម្រាបការពិតដល់បងស្រី តែសុំបងស្រីកុំប្រកាន់នឹងគំនិតដដែលនេះទៀត ផ្ទះនេះជាផ្ទះរបស់លោកសុជាតិមែន តែខ្ញុំមិនមែនជាស្រីឬសង្សាររបស់គាត់ទេ !

ស្រីនោះបើកភ្នែកធំៗសម្លឹងម៉ូលីយ៉ាទំនងជាភ្ញាក់ !

- អ៊ីចឹងនាងត្រូវការយ៉ាងណាដែរបានជាមកនៅទីនេះជាមួយនឹងគាត់ ?

- នាងជាប្រពន្ធរបស់ខ្ញុំដែលបានរៀបការរួចយ៉ាងត្រឹមត្រូវ !

ចប់ប្រយោគនេះសុជាតិបោះជំហានចូលទៅធ្វើឲ្យម៉ូលីយ៉ានិងស្ត្រីនោះភ្ញាក់ផ្អើលជាខ្លាំង !

នរៈយើងដាក់ខ្លួនអង្គុយក្បែរម៉ូលីយ៉ាយ៉ាងកៀកហើយសម្លឹងទៅនារីចំណូលថ្មីទើបតបទៅវិញ :

- យ៉ាងម៉េចបុប្ផា នាងត្រូវការជួបខ្ញុំមានការអីដែរ ?

- មានការអី ? ដូចជាអស្ចារ្យណាស់បងសុជាតិ បងចង់លេង

ប្អូនសន្ទឹកដាក់ខ្ញុំហើយមែនទេ ខ្ញុំជាគូដណ្ដឹងបងយ៉ាងពេញច្បាប់តាំងពីបងទៅសិក្សាឯស្រុកបារាំងម្ល៉េះ គឺម្ដាយបងទៅដណ្ដឹងខ្ញុំមានចាស់ទុំត្រឹមត្រូវ ដូច្នេះបងពិតជាគ្មានសិទ្ធិរៀបការជាមួយនឹងស្រីណាផ្សេងទៀតបានទេ !

- តែខ្ញុំមិនបានដឹងទាល់តែសោះ ក្នុងរឿងនេះ ចំណែកប្រពន្ធខ្ញុំនេះ ខ្ញុំបានស្រឡាញ់គ្នាតាំងពីយូរណាស់មកហើយ ដូច្នេះខ្ញុំអាចរៀបការបាន នាងគ្មានសិទ្ធិឯណាមករករឿងខ្ញុំនោះទេ !

- ពិតជាមានសិទ្ធិ ព្រោះខ្ញុំជាគូដណ្ដឹងរបស់បង បើបងនៅតែចង់ឈ្នះទៀត ខ្ញុំនឹងទៅហៅម៉ែបងពីសៀមរាបមករកខុសត្រូវឲ្យខ្ញុំក្នុងរឿងនេះ តើបងសុខចិត្តឲ្យមុខមាត់ម្ដាយបងធ្លាក់ចុះថោកទាបដោយសារតែរូបបងឬទេ ? ក្នុងនាមបងជាបញ្ញវ័ន្តសូមបងគិតមើលទៅ !

- មិនបាច់គិតច្រើនពេកទេ ព្រោះជារឿងខ្ញុំធ្លាប់គិតជាច្រើនដងរួចមកហើយ យកល្អនាងត្រឡប់ទៅផ្ទះវិញទៅ ព្រោះយប់កាន់តែជ្រៅណាស់ហើយ !

- ខ្ញុំមិនទៅបើបងនៅតែប្រកែកយ៉ាងនេះ ខ្ញុំសូមប្រាប់បងឲ្យដឹងថាបើកុំតែជាប់ពាក្យបង ខ្ញុំមិនខ្វះមនុស្សដែលត្រូវរៀបការនោះទេ តែបងជាមនុស្សដែលធ្វើឲ្យខ្ញុំឈឺចាប់ខ្មាសគេមួយភូមិ ព្រោះតែដល់ថ្ងៃកំណត់រៀបការហើយ គ្មានរូបបងអញ្ជើញទៅ អាពាហ៍ពិពាហ៍ត្រូវអាក់ខានយ៉ាងអាម៉ាស់ ។ ម្ដាយបងត្រូវពិបាកចិត្តដោយសារតែរូបបង

សព្វថ្ងៃគាត់ឈឺនៅនឹងកន្ទេល បើសិនជាគ្មានការជួយជ្រោមជ្រែងពីគ្រួសាររបស់ខ្ញុំទេ គាត់ពុំដឹងជាយ៉ាងណាទេ សមបងជាកូនប្រុសតែមួយហើយផ្ដល់ការឈឺចាប់ទៅឲ្យម្ដាយយ៉ាងនេះសោះ ! ហើយបងកុំស្មានថាបុប្ផាពេញចិត្តនឹងអង្វរបងឲ្យទៅរៀបការនោះ ខ្ញុំព្រមទទួលបងដោយសារតែការទុកដាក់របស់ឪពុកម្ដាយខ្ញុំ ដែលយល់ថាបងជាមនុស្សត្រឹមត្រូវ មានសមត្ថភាពគ្រប់គ្រាន់ក្នុងឋានៈជាវេជ្ជបណ្ឌិតមួយរូបដែលអាចរកសុភមង្គលឲ្យខ្ញុំបាន កុំអីបុប្ផាក៏ពុំព្រមទទួលបងដែរ ខ្វះអីមនុស្សដែលចង់បានរូបខ្ញុំនោះ !

- ហ្នឹងហើយ ខ្ញុំក៏ជឿថាអ៊ីចឹងដែរព្រោះបុប្ផាមានរូបសម្ផស្សស្អាតពិតជាមានគេចង់បានច្រើនហើយ វណ្ណៈនិងត្រកូលរបស់នាងក៏ខ្ពង់ខ្ពស់មិនសមនឹងទទួលរូបខ្ញុំដែលជាមនុស្សក្រីក្រធ្វើជាប្ដីទេ ដូច្នេះហើយបានជាខ្ញុំកាត់ចិត្តមិនទៅរៀបការជាមួយនាងនោះ ទោះជាខ្ញុំមានការពេញចិត្តដល់កម្រិតណាក៏ដោយ ដើម្បីឲ្យនារីម្នាក់គឺរូបបុប្ផាមានវាសនាខ្ពង់ខ្ពស់លើសពីនារីទាំងពួង ព្រោះរូបខ្ញុំជឿជាក់ថា គ្មានសមត្ថភាពរកសុភមង្គលជូននាងបានគ្រប់គ្រាន់នោះទេ ! ទោះបីជាខ្ញុំក្លាយទៅជាវេជ្ជបណ្ឌិតក៏ដោយ ក៏ខ្ញុំគ្មានគំនិតរកស៊ីក្រៅនោះដែរ ដូចជានាងបានឃើញពីជីវភាពរបស់ខ្ញុំនឹងភ្នែកស្រាប់ហើយ !

ឆ្លើយនឹងសម្ដីអ្នកកំលោះមិនរួច កញ្ញាបុប្ផាបានត្រឹមតែឈរសម្លក់ទាំងក្នាញ់ ។

- ស្រេចតែបងយល់ឃើញទេ តែបើបងហ៊ានធ្វើឲ្យខ្ញុំខ្មាសគេយ៉ាងនេះ ខ្ញុំក៏ហ៊ានធ្វើឲ្យម្ដាយបងអាម៉ាស់វិញដែរ !

ចប់សម្ដីនាងរត់ចេញទៅក្រៅមួយរំពេច រកតែសុជាតិឃាត់ក៏មិនទាន់ដែរ ! អ្នកកំលោះដើរទៅបិទទ្វារ ហើយដើរមកក្បែរបន្ទប់ស្រីតូចម៉ូលីយ៉ាវិញ តែគេមិនចូលទៅទេ អ្នកស្រែកហៅនាងតិចៗ :

- ម៉ូលីយ៉ា នាងចេញមកណេះមួយភ្លែត ខ្ញុំចង់ជួបនាងមានកិច្ចការបន្តិច !

ស្រីល្អនាំខ្លួនដ៏សោភា ដែលស្រោបទៅដោយសម្លៀកបំពាក់រាត្រីចេញមកជួបប្រុសកំលោះនៅបន្ទប់ទទួលភ្ញៀវខាងមុខ ក្រោយពីបានអង្គុយស្រួលបួលហើយ សុជាតិក៏ផ្ដើមសួរទៅនាងថា :

- ម៉ូលីយ៉ា ខ្ញុំសូមអភ័យទោសទៅចុះចំពោះអាកប្បកិរិយានិងពាក្យសម្ដីដែលពុំសមរម្យរបស់ខ្ញុំក្នុងពេលអម្បាញ់មិញនេះ នាងប្រហែលជាអន់ចិត្តនឹងខ្ញុំខ្លាំងណាស់មែនទេ ?

មាណវីគ្រវីក្បាលញាប់ស្អេកព្រមទាំងរាដៃបដិសេធ :

- ខ្ញុំមិនខឹងនឹងលោកទេ តែ... អឺ...

នាងត្រូវអាក់ទៅវិញឈ្ងោកមុខសម្លឹងឥដ្ឋការ៉ូ !

- តែ យ៉ាងម៉េច ? នាងនិយាយមកកុំក្រែងរអែងចិត្តខ្ញុំអី !

- មិនយ៉ាងម៉េចទេតែលោកមិនសមណាកុហកតួដណ្ដឹងលោកថាខ្ញុំជាប្រពន្ធរបស់លោកសោះ !

នាងបញ្ចប់ឃ្លាទាំងក្តីអឹមអៀន ក្រហមមុខដូចជាផ្លែបាសទុំ... ធ្វើឲ្យសុជាតិស្ទើរភ្លឹកនឹងសម្រស់ដ៏ស្រស់ស្អាតរបស់ស្រីនារាត្រីនេះ។

អ្នកប្រុសសួរទៅនាងដូចធម្មតាវិញ :

- ចុះនាងយល់យ៉ាងណាដែរចំពោះពាក្យភូតកុហករបស់ខ្ញុំ ?

- ខ្ញុំយល់ថាលោកឆ្លើយយករួចខ្លួនតែប៉ុណ្ណោះមែនទេ ដោយមិនបានគិតទៅដល់ផលវិបាកអ្វីទាំងអស់ នៅពេលថ្ងៃក្រោយតទៅមុខទៀតនោះ !

- មិនមែនថាមិនគិតនោះទេម៉ូលីយ៉ា នាងប្រហែលស្មានថាចម្លើយដែលទើបនឹងកើតមុនក្នុងពេលដ៏ខ្លីនេះហើយ ការពិតចម្លើយនេះខ្ញុំត្រៀមតាំងពីយូរណាស់មកហើយ គឺថ្ងៃដែលទទួលនាងឲ្យមករស់នៅទីនេះម្ល៉េះ ព្រោះខ្ញុំបានសន្និដ្ឋានថាបុប្ផាគូដណ្តឹងខ្ញុំពិតជាមករករឿងខ្ញុំ និងមកចោទប្រកាន់ចំពោះនាងទៀត !

- អីចឹងបានសេចក្តីថាលោកបានដឹងវត្តមានចំពោះបងស្រីនេះជាគូដណ្តឹងរបស់លោករួចទៅហើយ ចុះហេតុអីក៏លោកឆ្លើយចំពោះមុខគាត់ថាលោកមិនបានដឹងទៅវិញ លោកមិនគួរធ្វើបែបនេះទេ ស្ត្រីដែលកាត់ចិត្តហ៊ានមកនិយាយជាមួយលោកក្នុងរឿងហ្នឹង ដូចជាបងស្រីបុប្ផានោះពិតជាពុះពារការអៀនខ្មាសមិនតិចទេ ព្រោះតែគាត់មានចិត្តស្រឡាញ់ហ្នឹងហើយ ដូច្នេះលោកមិនត្រូវផ្តល់ការឈឺចាប់ទៅឲ្យ

គាត់ឡើយ !

- វាជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំដែលខ្ញុំធ្លាប់ដោះស្រាយជាច្រើនដងណាស់មកហើយ ដូច្នេះនាងមិនបាច់ផ្ដល់យោបល់អ្វីទេ !

- តែវាជារឿងទាក់ទងដល់ខ្ញុំដែរ ព្រោះចម្លើយនិងការអះអាងរបស់លោកថាខ្ញុំជាប្រពន្ធលោកនៅចំពោះមុខបងស្រីបុប្ផា ពិតជាធ្វើឲ្យគាត់ក្ដៅក្រហាយខ្វល់ខ្វាយដេកមិនលក់ ហើយចោទប្រកាន់មកលើរូបខ្ញុំទាំងស្រុង !

- នាងខ្លាចមានគ្រោះថ្នាក់ឬទទួលការអាម៉ាស់ដោយសារតែបុប្ផាមែនទេ ? ប៉ុន្តែខ្ញុំធានាការពារនាងមិនឲ្យបុប្ផាឈ្លានពាននិងចោលសម្ដីលែបខាយឈ្លោះប្រកែកជាមួយនាងជាដាច់ខាត ឲ្យតែនាងជួយខ្ញុំនៅពេលនេះ ខ្ញុំសូមប្រាប់នាងឲ្យស្មោះបំផុតថា គឺខ្ញុំមិនពេញចិត្តនឹងបុប្ផាបន្តិចណាទេ ទោះបីជានាងមានទ្រព្យសម្បត្តិ និងរូបសម្ផស្សល្អស្រស់យ៉ាងនេះក៏ដោយ !

- តែធ្វើយ៉ាងម៉េចទៅវិញ បើគាត់ជាគូដណ្ដឹងរបស់លោកពេញច្បាប់យ៉ាងនេះទៅហើយ !

- រឿងនេះខ្ញុំរឹតតែគិតរឹតតែខ្វល់ខ្វាយបំផុត តែពេលដែលខ្ញុំបានរស់នៅជាមួយនាង ខ្ញុំមិនសូវជាគិតប៉ុន្មានឥឡូវមកដល់ទៀតហើយ

អ្នកប្រុសដកដង្ហើមធំហាក់ដូចជាតឹងតែងខ្លាំងណាស់ ម៉ូលីយ៉ា

លួចសម្លឹងមុខគេដែលស្រពោនខុសពីសព្វមួយដង លាយឡំដោយក្ដីអាណិតចំពោះអ្នកប្រុសយ៉ាងលើសលប់ ។

មាណវីដកដង្ហើមធំយ៉ាងវែង ហើយនិយាយមួយៗថា :

- ខ្ញុំហ៊ានពុះពារគ្រប់ការលំបាកទាំងអស់ឲ្យតែលោកបានសុខស្រួលក្នុងចិត្តទៅចុះ !

- ពិតមែនឬ ?

សុជាតិញញឹមត្រេកអរខ្លាំងណាស់ គេវាចាបន្តទៀត :

- កិច្ចការទាំងនេះមិនពិបាកដល់នាងពេកទេ គឺគ្រាន់តែនាងទទួលពាក្យថាប្រពន្ធរបស់ខ្ញុំតែប៉ុណ្ណោះបានហើយ ខ្ញុំនឹងនាំនាងទៅនៅកន្លែងផ្សេងពីនេះ ដើម្បីការពាររឿងហេតុផ្សេងៗដែលកើតមានឡើងដោយសារបុប្ផា ! ហើយនាងទៅរៀនធម្មតាចុះ ចំណែកខ្ញុំត្រូវទៅសៀមរាបជួបនឹងម្ដាយរបស់ខ្ញុំដើម្បីដោះស្រាយបញ្ហានេះ !

ម៉ូលីយ៉ាសញ្ជឹងគិតហាក់ត្រិះរិះចំពោះសម្ដីរបស់គេ នាងនៅមិនទាន់សម្រេចចិត្តថាយ៉ាងណានោះឡើយ នៅតែឆ្ងល់មិនអស់ពីដួងចិត្ត ហេតុអ្វីបានជាគេចាំបាច់ឲ្យនាងទទួលពាក្យថាជាប្រពន្ធរបស់គេ ? តើពាក្យមួយម៉ាត់នេះមានអត្ថន័យយ៉ាងណាដើម្បីក្នុងរឿងរបស់គេ ? តែនាងគិតថានាងជាមនុស្សបានសន្យាថាជួយគេទៅហើយ ទោះបីជាការទទួលខ្លួននេះបានជួបនឹងការលំបាកយ៉ាងណាក៏ដោយ ក៏នាងត្រូវ

តែទទួលដែរ ។

ស្រស់ស្រីងើបមុខឡើងសម្លឹងចំគេបន្តិច ទើបតបយ៉ាងស្ងប់ស្ងួតទៅវិញ :

- ខ្ញុំព្រមទទួលកិច្ចការនេះហើយលោក !

- ខ្ញុំអរគុណនាងហើយ នាងចូលសម្រាកចុះកុំគិតច្រើនអីក្រែងរំខានដល់សុខភាពរបស់នាង ខ្ញុំធានាមិនឲ្យនាងជួបប្រទះផលវិបាកដោយសារតែខ្ញុំនោះទេ !

ពោលចប់គេត្រឡប់ខ្លួនចូលទៅក្នុងបន្ទប់វិញ ម៉ូលីយ៉ាតាមមើលដំណើរអ្នកប្រុសយ៉ាងស្ងៀមស្ងាត់ ហើយចូលសម្រាកក្នុងបន្ទប់ទាំងពាំនាំនូវចម្ងល់មួយចំនួនទៅជាមួយផង ។

មួយរាត្រីបានកន្លងផុតទៅយ៉ាងយឺតបំផុតសម្រាប់សុជាតិ..... គេងើបពីព្រលឹមរៀបចំសម្លៀកបំពាក់ជាស្រេចដាក់ក្នុងវ៉ាលីស ហើយដើរតម្រង់មកបន្ទប់របស់ម៉ូលីយ៉ា គោះទ្វារតិចៗព្រោះនាងមិនទាន់ក្រោកនៅឡើយ !

- ម៉ូលីយ៉ា ម៉ូលីយ៉ា !

មាណវីស្ទុះងើបយ៉ាងប្រញាប់ ថ្ងៃនេះនាងគេងជ្រុលជាងរាល់ដងហាក់ដូចជាខ្មាសនឹងអ្នកកំលោះណាស់ កែវប្រញាប់បើកទ្វារបន្ទប់ហើយនិយាយឡើងថា :

- ម៉ូលីយ៉ា នាងរៀបចំអីវ៉ាន់ទៅ ខ្ញុំនឹងនាំនាងចេញពីផ្ទះនេះក្នុងពេលឥឡូវនេះ !

- ចាស សូមលោកចាំមួយភ្លែតសិន !

នៅតាមដងវិថីដែលមានពន្លឺស្រាងៗពីស្រមោលរាត្រីមិនទាន់រលុបបាត់នៅឡើយនោះ សុជាតិឱបស្រស់ស្រីតាមបណ្ដោយវិថី ព្រះស៊ីសុវត្ថិដោយមានទាំងវ៉ាលីសខ្មៅមួយផង គេបញ្ឈប់ហុងដានៅពីមុខផ្ទះវិសាលដែលជាមិត្តសម្លាញ់ចាស់របស់គេ ។

វិសាលដែលទើបនឹងភ្ញាក់ពីដំណេក ដើរទាំងទ្រេតទ្រោតមករកមិត្ត ព្រោះឆ្ងល់នឹងវត្តមានរបស់គេមកទាំងព្រលឹមអុរយ៉ាងនេះ... គេដើរមកទាំងសួរឡើងថា :

- ឯងមានការអីសម្លាញ់បានជាមកដល់ផ្ទះគ្នាទាំងព្រឹកបែបនេះ ឯងមានការអីសំខាន់ណាស់មែនទេ ?

- ថាសំខាន់ក៏បាន !

វិសាលងាកមកមើលស្រស់ស្រីហើយអញ្ជើញនាងចូលទៅក្នុងផ្ទះរបស់គេ រួចគេហួសទៅសម្អាតកាយឯបន្ទប់ទឹករួចស្រេចបាច់អស់ហើយ ទើបត្រឡប់មកបន្ទប់ទទួលភ្ញៀវវិញ !

- ឯងមានការអីឬសុជាតិ ?

- វិសាល គ្នាត្រូវទៅសៀមរាបហើយយកម៉ូលីយ៉ាមកផ្ញើឯង

ព្រោះម្ដាយគ្នាមានជំងឺផង ចុះប៉ាម៉ាក់របស់ឯងទៅណាអស់ហើយបាន ដូចជាស្ងាត់ម្ល៉េះ !

- ប៉ាម៉ាក់គ្នាទៅបុណ្យឯបាត់ដំបងអស់ទៅហើយ !

- ចុះគាត់អញ្ជើញមកវិញអង្កាល់ដែរ ?

- យ៉ាងឆាប់ក៏មួយអាទិត្យទៀតដែរ !

ចម្លើយនេះធ្វើឲ្យសុជាតិស្រងាកចិត្តចម្លែក ព្រោះអ្នកមិនសូវ ទុកចិត្តវិសាលទាល់តែសោះ គេធ្លាប់មានចរិតខិលខូចនឹងស្រីញីបន្តិច ណាមួយម៉ូលីយ៉ាមិនមែនជាប្អូនឬជាសង្សាររបស់អ្នកផង មិនដឹងជា វិសាលគេមានគំនិតបែបណាទេ !

អ្នកប្រុសសញ្ជឹងគិតមួយសន្ទុះទើបផ្ដើមនិយាយបន្តទៀត :

- ចុះមីងសនគាត់នៅដែរទេ ?

- មីក៏មិននៅ !

ឃើញពួកគេនិយាយការដូច្នេះ ម៉ូលីយ៉ាក៏ក្រោកដើរចេញពី សាឡុងទៅឈរនៅរានហាលខាងក្នុង សុជាតិចេះតែសម្លឹងមុខមិត្ត ហាក់ដូចជាមិនទុកចិត្ត :

- វិសាល គ្នាទុកចិត្តឯងយ៉ាងពិតប្រាកដហើយណា៎ !

- ហេតុអីក៏ឯងនិយាយយ៉ាងនេះទៅវិញ ? ធ្វើដូចជាមិនដែល ស្គាល់គ្នាអីចឹង មិនបាច់និយាយចេញមកក៏យើងយល់ដែរ ឯងមិនបាច់

បារម្ភទេ !

- គ្នាយល់ហើយ តែក្រែងលោឯងមិនចាត់ទុកថានាងជាញាតិរបស់គ្នា !

- គ្នាមិនផ្តេសផ្តាសទេសម្លាញ់ ឯងទុកចិត្តចុះ !

- ឥឡូវគ្នាលាសិនហើយ គ្នាជឿជាក់និងទុកចិត្តឯង យ៉ាងយូរ១អាទិត្យទៀតគ្នាត្រូវត្រឡប់មកវិញហើយ !

ក្រោយពីសុជាតិចេញផុតទៅ វិសាលក៏រៀបចំទទួលម៉ូលីយ៉ាដោយរាក់ទាក់តាមធម្មតា ព្រោះគេមិនមែនជាមនុស្សដែលចេះតែស៊ីពាសវាលពាសកាល មិនស្គាល់មិត្តឬសត្រូវនោះទេ ។

# វគ្គទី៤
## ចំណងអាពាហ៍ពិពាហ៍

ថ្ងៃលើកជំនូនរបស់បូរីក៏កាន់តែខិតជិតមកដល់ដែរ ក្រុមគ្រួ-សាររបស់អ្នកប្រុសត្រូវបានធ្វើដំណើរទៅកាន់ខេត្តសៀមរាប ដើម្បីងាយស្រួលនឹងរៀបចំពិធីផ្សេងៗសម្រាប់មង្គលការបូរី ។

គេទាំងអស់គ្នាពុំបានដឹងថា ម៉ូលីយ៉ាត្រូវបាត់ខ្លួនដោយពុំដឹងមូលហេតុនោះទេ ព្រោះលោកចំរើនពុំបានផ្តល់ព័ត៌មានពីរឿងនេះទៅឲ្យពួកគាត់ទេ ដោយសារតែមិនទាន់មានការអស់ចិត្តនឹងស្វែងរកកូនស្រីរបស់គាត់ ។

ថ្ងៃនេះនៅក្នុងគេហដ្ឋានរបស់លោកចំរើន យើងឃើញក្រុមគ្រួសារនេះមានទឹកមុខស្រងូតស្រងាត់រៀងៗខ្លួន ចំណែកលោកចំរើនមានទឹកមុខមាំអង្គុយនៅលើកៅអីបង្អួយខ្សែ្យ សម្លឹងមើលទៅភរិយាដែលកំពុងអង្គុយសញ្ជប់សញ្ជឹង ក្នុងភាពស្ងៀមស្ងាត់នេះបានកន្លងទៅយ៉ាងយូរ ទើបឮលោកចំរើននិយាយឡើងមួយៗថា :

- ថ្ងៃលើកជំនូនកាន់តែខិតជិតមកដល់ណាស់ទៅហើយ តើយើងត្រូវឆ្លើយយ៉ាងណាទៅចំពោះមុខគេ !

- ខ្ញុំមិនដឹងជាគិតយ៉ាងណាទេ បើវាកៀកថ្ងៃយ៉ាងនេះទៅហើយនោះ នេះមកពីបងឯងមិនជឿខ្ញុំ បើសិនជាបញ្ជូនដំណឹងនេះទៅឲ្យគេមុនតាំងពីថ្ងៃដំបូងនោះ ម្ល៉េះសមមិនពិបាកយ៉ាងនេះទេ !

- បងនៅតែមិនអស់ចិត្ត ម៉ូលីយ៉ាវាមិនសមមានគំនិតអ៊ីចឹងសោះ ឯងសម្រេចចិត្តឲ្យវាទៅបូរីនោះក៏បានសួរចិត្តសួរថ្លើមវាហើយដែរ មានរឿងអីដែលវារត់គេចខ្លួនយ៉ាងនេះ !

- ក្រែងវាឆ្លើយព្រមដោយខ្លាចបងហ្នឹងណាំ ព្រោះអីតាមវាវិញវាប្រាប់ខ្ញុំតាំងពីយូរណាស់មកហើយនោះ ម៉ូលីយ៉ាមានសង្សារបណ្ដើរតាំងពីឆ្នាំមុនម្ល៉េះ តែខ្ញុំមិនហ៊ាននិយាយជម្រាបបង !

- រឿងហ្នឹងវាជារឿងបន្ទាប់បន្សំរបស់យុវវ័យវាទេ ចំណែកអនាគតដ៏រុងរឿងនិងសុភមង្គលផ្ទាល់ខ្លួននោះ ម៉ូលីយ៉ាច្បាស់ជាចេះគិតវែងឆ្ងាយហើយ !

- បើវាចេះគិតវាមិនរត់ចោលផ្ទះទេ !

- តែថ្ងៃនោះបងមិននៅ បងមិនទាន់ហ៊ានសន្និដ្ឋានទេ !

- អ៊ីចឹងបងគិតយ៉ាងណាវិញ ថ្ងៃលើកជំនួនចូលរោងនោះនៅសល់តែជាង១អាទិត្យទៀតទេ បើតាមខ្ញុំស្មានក្រុមគ្រួសាររបស់ បូរីប្រហែលជាមកដល់នៅថ្ងៃស្អែកនេះហើយ ! រឿងនេះខ្ញុំមិនដឹងទេព្រោះម៉ូលីយ៉ាជាកូនរបស់បង បើខ្ញុំអាងកាត់ទៅក្រែងវាមិនសមរម្យ ។

លោកចំរើនហាក់ពុំបានយកចិត្តទុកដាក់ស្ដាប់សម្ដីភរិយាទេ... គាត់អង្គុយទ្រឹងទាំងអារម្មណ៍ហាក់មិននៅក្នុងខ្លួន ចំណែកអ្នកកំលោះបូរីបានមកដល់ខេត្តសៀមរាបដោយសុវត្ថិភាព ។ គេរីករាយណាស់ព្រោះថ្ងៃសុភមង្គលដ៏ត្រចះត្រចង់ ដែលគេប៉ងប្រាថ្នាជាយូរយារណាស់មកហើយ នឹងមកដល់ក្នុងពេលខាងមុខនេះ ។

ចិត្តអន្ទះសាចង់ជួបជាមួយនឹងម៉ូលីយ៉ាខុសធម្មតា អ្នកបន់ឲ្យតែមួយរាត្រីនេះកន្លងផុតទៅយ៉ាងឆាប់រហ័ស ដើម្បីថ្ងៃស្អែកគេនឹងបានជួបមុខនារីជាទីស្រឡាញ់របស់គេ ។

នៅក្នុងគេហដ្ឋានលោកសារិន ដែលជាឪពុកមាជីដូនមួយនេះ បូរីចេញមកឈរនៅមុខរានហាលគយគន់ទេសភាព នារាត្រី១៣កើតកំដរអារម្មណ៍រវើរវាយរបស់គេ ។ ស្រមោលស្គុំៗមកពីក្រោយ អ្នកងាកមកយ៉ាងស្ងំយប្រវត្តិ គឺជារូបកាយប្អូនស្រីជីទូតមួយរបស់អ្នក ។

មាណវីញញឹមយ៉ាងស្រស់ដើរមកក្បែរបងប្រុស បូរីសើចតបទៅប្អូនវិញទាំងសួរឡើង :

- ម៉ូលីយ៉ាប្រឡងជាប់ហើយមែនទេអូន ?

- ខ្ញុំឥតដឹងទេ តែឮបងស្រីរបស់ពួកម៉ាកខ្ញុំគាត់និយាយថាថ្ងៃប្រឡងនោះ គាត់ឈឺមិនបានមកប្រឡងទេ !

- ពិតមែនឬ ?

អ្នកប្រុសឧទានទាំងសម្ដែងទឹកមុខតក់ស្លុតនឹងដំណឹងនេះ ! នារីឃើញអាកប្បកិរិយាប្រែប្រួលរបស់បង នាងមានការស្ដាយក្រោយ មិនគួរណានាំពាក្យមិនល្អមកនិយាយប្រាប់គេសោះ ស្រីប្រញាប់ហាមាត់និយាយដោះសាវិញ :

- បងកុំទាន់អស់សង្ឃឹមអី ក្រែងបងស្រីមិត្តខ្ញុំគេដឹងរឿងមិនច្បាស់ណាំ !

- បងក៏មិនទាន់ជឿនៅឡើយដែរ តែបើអាយ៉ាធ្លាក់មែនគួរឲ្យស្ដាយណាស់ !

- អ៊ីចឹង បងគិតឲ្យគាត់ចូលធ្វើការឬ ?

- ទោះជាមិនធ្វើការក៏ត្រូវប្រឡងឲ្យជាប់ដែរទើបប្រសើរ តែអាយ៉ាខំរៀនណាស់បើមិនឈឺថ្ងៃប្រឡងនោះទេ ពិតជាប្រឡងជាប់មិនធ្លាក់ទេ មួយឆ្នាំកន្លងទៅហើយអាយ៉ាមិនដែលផ្ញើដំណឹងប្រាប់បងថា ចូលធ្វើការក្នុងក្រសួងអីសោះ សមតែធ្លាក់ដូចជាពាក្យដែលអូនថាមែនហើយក៏មិនដឹង !

- ណ្ហើយ កុំទាន់សន្និដ្ឋានអីបងថ្ងៃស្អែកនោះដឹងច្បាស់ហើយ

- ចុះអូនទៅទេថ្ងៃស្អែកនេះ ?

- ខ្ញុំដូចជាចង់ទៅដែរ ព្រោះខានឃើញបងយ៉ា១ឆ្នាំហើយ គាត់ប្រហែលជាស្អាតជាងមុនហើយមើលទៅ គិតទៅបងបូរីឯងពូកែ

រើសប្រពន្ធណាស់ បងដឹងទេកំលោះៗនៅសៀមរាបនេះ អ្នកណាក៏ជ្រួលច្របល់នឹងសម្រស់របស់បងយ៉ាងដែរ !

សម្ដីបន្ថែមបន្ថយរបស់ប្អូនស្រីរឹតតែធ្វើឲ្យបូរីពេញចិត្តនឹងនាងខ្លាំងឡើង គេញញឹមមិនដាក់សោះ នារីសម្លឹងទៅបងប្រុសយ៉ាងយូរទើបដើរទៅឈរឆ្ងាយពីនោះបន្តិច អ្នកប្រុសរហ័សដើរទៅតាមប្អូនហើយសួរថា :

- នារី អូនឯងចាំយករបស់នេះទៅឲ្យអាយ៉ាផងណា៎ !

- ហេតុអីក៏បងមិនយកខ្លួនឯងទៅ ?

- ក្រែងមិនសម ព្រោះសុទ្ធតែគ្រឿងក្នុងផង អាយ៉ាច្បាស់ជាខឹងបងស្លាប់ហើយ !

- បងប្រញាប់ចូលសម្រាន្តទៅ ធ្វើដំណើរផ្លូវឆ្ងាយផងច្បាស់ជាអស់កម្លាំងហើយប្រយ័ត្នឈឺ ស្អែកឡើងខានទៅជួបបងយ៉ាណា៎ !

អ្នកប្រុសទះស្មាប្អូនដោយក្ដាញ់ ហើយដើរចូលទៅក្នុងផ្ទះបាត់ ។ ព្រឹកឡើងគ្រួសាររបស់បូរីធ្វើដំណើរទៅកាន់គេហដ្ឋានរបស់លោកចំរើន ចិត្តជ្រួលច្របល់របស់អ្នកប្រុសក៏បានធូរស្រាលខ្លះ ។

រថយន្តបានមកដល់គេហដ្ឋានហើយ លោកចំរើននិងភរិយារហ័សចុះមកទទួលក្រុមគ្រួសារនេះ ក្នុងន័យរាក់ទាក់កក់ក្ដៅជាធម្មតា តែទឹកមុខរបស់លោកចំរើន ហាក់បញ្ជាក់នូវការសោកសៅក្នុងចិត្តជា

ហេតុធ្វើឲ្យបូរីសែនឆ្ងល់ណាស់ ណាមួយមិនឃើញម៉ូលីយ៉ាចេញមក ទទួលក្រុមគ្រួសារអ្នកយ៉ាងនេះផង ធ្វើឲ្យគេនឹកបារម្ភក្នុងចិត្តខ្លះដែរ ។

អ្នកប្រុសប្រថុយសួរគាត់ថា :

- លោកពូ ដូចជាមិនឃើញម៉ូលីយ៉ា ?

សំណួរនេះធ្វើឲ្យមាតាអ្នកនិងនារីអស់សំណើច អ្នកស្រីក៏ស្រដីឡើងថា :

- ចំរើនអើយ បូរីនឹកម៉ូលីយ៉ាណាស់ សឹងតែនៅមិនសុខទៅហើយ មួយថ្ងៃៗវាអង្គុយរាប់តែថ្ងៃនឹងរហ័សសុំច្បាប់គេឈប់ទេ !

សំណួររបស់លោកស្រីធ្វើឲ្យលោកចំរើនសែនរន្ធត់គាត់សឹងតែស្រែកយំ តែមិនដឹងជាឆ្លើយតបទៅគេវិញយ៉ាងណាទេ គាត់គ្រាន់តែញញឹមយ៉ាងស្ងួតប៉ុណ្ណោះ បូរីមិនទាន់អស់ក្តីសង្ស័យទេ តែជើងរបស់អ្នកបានឈានទៅលើកាំជណ្តើរមួយជាន់ទៅហើយ ចិត្តក្នុកក្តាក់ៗកាន់តែញាប់ញ័រឡើង អ្នកចេះតែភ័យអរៗយ៉ាងម៉េចមិនដឹងទេ ។

ក្រោយពីអង្គុយមួយស្របក់រួចមកហើយ នៅមិនទាន់ឃើញម៉ូលីយ៉ាចេញមកទៀត ឬមួយក៏នាងមិនហ៊ានចេញមកទទួល តែអ្នកមិនហ៊ានសួរលោកចំរើនម្តងទៀតសុខចិត្តតែពីនៅស្ងៀមទាំងចិត្តអន្ទះសា រំពេចនោះស្រាប់តែលេចវ៉ារីលើកថាសទឹកក្រូចចេញមក រឹតតែធ្វើឲ្យបូរីមានការសង្ស័យកាន់តែខ្លាំង អ្នកសឹងតែទ្រាំ ទប់ភាពចម្ងល់

សឹងមិនបានលោកសេដ្ឋាក៏មានចម្ងល់ខ្លះដែរ គាត់សួរទៅដន្លង :

- ចំរើន ដូចជាមិនឃើញម៉ូលីយ៉ា វាទៅធ្វើការឬ ?

លោកចំរើនសែនស្លុតនៅក្នុងចិត្ត តែគាត់ខំសម្រួលទឹកមុខបន្តិចទើបតបទៅវិញ :

- បងសេដ្ឋា អ្នកបងមន្ថា...សុំឲ្យបងទាំងពីរអនុគ្រោះផងចុះក្មួយបូរីក៏អ៊ីចឹងដែរ !

គាត់ងាកមកនិយាយជាមួយនឹងអ្នកកំលោះ ដែលកំពុងតែធ្វើភ្នែកស្លឹស្លើរបាត់ស្មារតី ! លោកសេដ្ឋាសែនឆ្ងល់រហ័សសួរកាត់ភ្លាម :

- មានរឿងអីកើតឡើងចំរើន បានជាម៉ូលីយ៉ាបាត់ខ្លួនពីផ្ទះអស់៧ខែហើយទាំងគ្មានមូលហេតុអីយ៉ាងហ្នឹង ?

អ្នកមន្ថាឧទានយ៉ាងភ្ញាក់ :

- ម៉េចបានជាអ៊ីចឹង ?

- ប្រហែលជាមិនពេញចិត្តបូរីទេដឹង ចំរើនឯងមានបានសួរចិត្តថ្លើមវាទេ !

- បានសួរបញ្ជាក់ច្បាស់លាស់ហើយមិនសមនឹងមានបាតុភាពនេះកើតឡើងសោះ ! ខ្ញុំពិបាកសន្និដ្ឋាន ព្រោះពីថ្ងៃដែលបាត់វានោះខ្ញុំមិនបាននៅផ្ទះទេ រវល់ទៅចម្ការឯស្រុកពួកឯណោះ !

អ្នកទាំងអស់គ្នាហាក់យល់សម្ដីលោកចំរើន គេចោលភ្នែក

តម្រង់អ្នកសំអឿនគ្រប់គ្នា ជាពិសេសបូរីសែនសង្ស័យទៅលើអ្នកស្រីសំអឿនជាងគេ ធ្វើឲ្យគាត់តក់ស្លុតណាស់ដែរ តែគាត់ខំញញឹមបន្តិចទើបតបទៅវិញ :

- បង អ្នកបង ព្រមទាំងបូរី ថ្ងៃនោះខ្ញុំមិនបានចាប់អារម្មណ៍ថាម៉ូលីយ៉ាបម្រុងរត់ចោលផ្ទះអីចឹងទេ ក្នុងយប់មួយដែលមានភ្លៀងធំនោះវាប្រាប់ខ្ញុំថាចុះទៅសាសំពត់ អាវ ស្រាប់តែបាត់មិនឃើញមកវិញ ខ្ញុំខំឲ្យវ៉ារីវាចុះទៅមើលក្រែងលោអាយ៉ាវាខ្យល់គ តែទៅមិនឃើញដដែល បើតាមខ្ញុំស្មានអាយ៉ាប្រហែលជាមិនសូវពេញចិត្តនឹងក្មួយបូរីទេមើលទៅនោះ !

- មិនមែនអីចឹងទេ ព្រោះបងបានសួរចិត្តវាច្បាស់ណាស់ !

លោកចំរើនឆ្លើយកាត់ប្រពន្ធទាំងមិនសូវពេញចិត្ត ចំណែកអ្នកប្រុសបូរីវិញមិនដឹងជាមានពាក្យអ្វីឆ្លើយតបទេ ព្រោះគេហាក់ស្រឡាំងកាំងភាំងស្មារតីខុសធម្មតា។ ការសន្ទនាវែកញែកពីមូលហេតុបាត់ម៉ូលីយ៉ាចេះតែបន្តប្រព្រឹត្តទៅជាហូរហែ តែការសន្និដ្ឋាននៅមិនទាន់ដាច់ស្រេចនៅឡើយ ។ ទីបំផុតក្រុមគ្រួសារបូរីក៏ត្រឡប់មកផ្ទះវិញ អ្នកស្រីនិងលោកប្រុសបានលួងលោមកូនយ៉ាងច្រើន ដើម្បីកុំឲ្យអ្នកមានការគិតរហូតដល់ខូចចិត្តឲ្យសោះ ។

---------------------------

យើងក្រឡេកមើលមកកំលោះសុជាតិវិញម្តង ពេលដែលគេបម្រុងទៅសៀមរាបនោះ អ្នកមិនទាន់ទៅផ្ទះម្តាយឯសៀមរាបទេ គេឆ្លៀតមកជួបនឹងបុប្ផាដើម្បីដោះស្រាយគ្នាបន្តិចសិន។ ពេលដែលចេញពីផ្ទះវិសាលមកវិញអ្នកហួសទៅសុំច្បាប់មន្ទីរពេទ្យ រួចទើបត្រឡប់មកអង្គុយសំកុកនៅមុខផ្ទះរង់ចាំជួបនឹងបុប្ផាសាជាថ្មី ។

ម៉ោងប្រហែលជា៨ រថយន្តតូចថ្មីមួយគ្រឿងបើកចូលតម្រង់មក គ្មានអ្នកណាក្រៅពីបុប្ផាឡើយ ព្រមជាមួយនោះគឺលោកវិបុលជាឪពុករបស់បុប្ផាតែម្តង ។ អ្នកប្រុសដូចជាភ័យតិចៗដែរនឹងវត្តមានរបស់លោកឪពុកស្រីម្នាក់នេះ តើគាត់គិតមករករឿងនឹងអ្នកឬមួយក៏យ៉ាងណាដែរ គេរហ័សស្ទុះទៅទទួលគាត់យ៉ាងរាក់ទាក់ !

- លោកអ៊ំអញ្ជើញចូលបាទ !

លោកវិបុលមានទឹកមុខមាំ ដើរតាមក្រោយតិចៗ សុជាតិចាក់ទឹកជូនគាត់ពិសា តែលោកវិបុល សម្លឹងមុខអ្នកយ៉ាងមុតជាមួយនឹងវាចាម៉ឺងម៉ាត់ :

- ប្រពន្ធឯងទៅណាហើយសុជាតិ ?

- បាទលោកអ៊ំ នាងទៅលេងផ្ទះម្តាយនាងឯកំពង់សោមបាត់ទៅហើយ !

- ហ៊ឹះ...( បុប្ផាគ្រហឹមដោយហួសចិត្ត ) ចេះខ្លាចគូដណ្តឹងគេ

មករករឿងដែរទេតើ បើពិតជាប្ដីប្រពន្ធពេញច្បាប់ចាំបាច់ខ្លាចធ្វើអី ថៅកទាបណាស់ !

- កុំទាន់ដៀលប្រពន្ធខ្ញុំអាក្រក់អាក្រីយ៉ាងហ្នឹងបុប្ផ យើងគួរតែនិយាយគ្នាឲ្យស្រួលស្ដាប់បន្តិចទៅ !

លោកវិបុល ដូចជាទើសត្រចៀកនឹងសម្ដីរបស់អ្នកប្រុសយើងខ្លាំងណាស់ គាត់រហ័សឆ្លើយទាំងទឹកមុខមាំដដែល :

- គ្មានរឿងអ្វីដែលត្រូវនិយាយសម្ដីល្អជាមួយនឹងឯងនោះទេ សុជាតិ ហើយឯងក៏គ្មានសិទ្ធិរៀបការប្រពន្ធបានដែរ ព្រោះឯងមានឈ្មោះជាគូដណ្ដឹងរបស់បុប្ផារួចទៅហើយ !

- តែលោកអ៊ំក៏មិនអាចបង្ខិតបង្ខំចិត្តខ្ញុំបានដែរ ហើយរូបខ្ញុំទៀតសោតក៏គ្មានសិទ្ធិលែងប្រពន្ធស្របច្បាប់របស់ខ្ញុំ ទៅរៀបការជាមួយបុប្ផាកើតដែរ ព្រោះខ្ញុំនិងប្រពន្ធខ្ញុំមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ បើលោកអ៊ំនិងបុប្ផាមិនទាន់ជឿច្បាស់ ខ្ញុំនឹងយកមកជូនលោកអ៊ំមើលបាន !

ចប់សម្ដីសុជាតិងើបតម្រង់បន្ទប់របស់គេ រួចទៅយកសំបុត្រអាពាហ៍ពិពាហ៍មកប្រគល់ឲ្យលោកវិបុល ធ្វើឲ្យលោកសក្ដិពានេះកាន់តែក្ដៅឆេវឡើងនឹងអាកប្បកិរិយាបញ្ឆោក់ពីសំបុត្រ ដែលអ្នកប្រុសយើងយកមកហុចឲ្យដោយសេចក្ដីគោរព កំហឹងរឹតតែពុះពោរគាត់ចាប់ហែក

សំបុត្រនោះចោលភ្លាម ដោយគ្មានស្តាយស្រណោះបន្តិចទេ។

ចំណែកសុជាតិក៏មិនសប្បាយចិត្ត នឹងចរិតឆេវឆាវនេះដែរ គេខាំមាត់សង្កត់ចិត្តទប់កំហឹង សម្លឹងទៅលោកវិបុលវិញដោយគ្មានចិត្តញញើតបន្តិចឡើយ រួចអ្នកបែរទៅបុប្ផាបន្តិច ទើបនិយាយទៅកាន់អ្នកទាំងពីរដោយសំឡេងដាច់ណាត់ថា :

- សូមលោកអ៊ំនិងបុប្ផាកុំប្រញាប់ឆេវឆាវពេក លោកអ៊ំគួរតែយល់ខ្លះៗហើយពីតម្លៃមនោសញ្ចេតនារបស់យុវវ័យ ខ្ញុំក៏មិនមែនស្អប់ខ្ពើមបុប្ផាដែរ ផ្ទុយទៅវិញខ្ញុំមានតែញញើតកោតខ្លាច និងគោរពព្រោះបុប្ផានិងលោកអ៊ំជាអ្នកមានគុណមកលើគ្រួសារខ្ញុំដែរ ហើយខ្ញុំក៏ចងចាំមិនភ្លេចដែរ តែខ្ញុំមិនអាចសងគុណដោយការរៀបការជាមួយនឹងបុប្ផាបានទេ !

សម្ដីនេះកាន់តែធ្វើឲ្យបុប្ផាក្ដៅឡើង នាងតបទាំងមុខកំហឹងទៅវិញ :

- រូបអ្នកឯងក៏មិនមែនជាវត្ថុសំខាន់មានតម្លៃឯណាសម្រាប់យកមកសងគុណម៉ាក់ប៉ាខ្ញុំបានដែរ តែម្ដាយអ្នកឯងទេដែលជាអ្នកពេញចិត្តរូបខ្ញុំ ហើយខ្ញុំក៏មិនមែនមកអង្វរលន់តួសុំឲ្យគាត់ចូលដណ្ដឹងខ្ញុំឯណា ! ហើយពេលនេះទៀតសោតខ្ញុំក៏មិនមែនមកអង្វរអ្នកឯងទេខ្ញុំមកនេះគឺមករករឿងអ្នកឯងព្រោះអ្នកឯងជាមនុស្សក្បត់ ជាមនុស្ស

មានកំហុស ទោះបីជាខ្ញុំប្ញឹងក្បាលអ្នកឯងក្នុងពេលនេះបញ្ចូលគុក ក៏បានដែរ !

- ខ្ញុំមិនទាន់ជឿថាខ្លួនខ្ញុំមានកំហុសរហូតដល់ទៅចូលគុកនោះទេ ព្រោះខ្ញុំនិងបុប្ផាគ្រាន់តែជាគូដណ្តឹងដែលមិនទាន់មានអ្នកណាគេទទួលដឹងឮហើយដែរ អាចចាត់ទុកជាសាក្សីបានដែរទេ ? ហើយខ្ញុំនិយាយនេះមិនមែនបានន័យថា ខ្ញុំមិនសូវពេញចិត្តនឹងនាងដែលមានរូបល្អទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយខ្វះប្តីមកចាប់គេដែលមិនស្រឡាញ់ទៅរៀបការនោះដែរ ខ្ញុំពិតជាស្រឡាញ់នាងដែរ តែខ្ញុំមិនអាចផ្តល់នូវក្តីឈឺចាប់ទៅឲ្យនារីម្នាក់ដែលជាកូនកំព្រាតែលតោល ហើយត្រូវទាមទារការគ្រប់គ្រងអំពីខ្ញុំ ដែលជាអតីតសង្សារធ្លាប់បានសន្យាជាមួយគ្នាថារៀបការពេលដែលខ្ញុំវិលពីប្រទេសបារាំងមកវិញ ដល់ពេលឥឡូវនេះនាងទាំងក្លាយទៅជាប្រពន្ធរបស់ខ្ញុំហើយដែរ ! មនោសញ្ចេតនាអាណិតអាសូរវាកាន់តែជ្រួតជ្រាបពេញក្នុងបេះដូងរបស់ខ្ញុំ ថែមមួយកម្រិតទៀត ។ ចំពោះបុប្ផានាងអាចមានលទ្ធភាពជ្រើសរើសអនាគតស្វាមីបាន តែប្រពន្ធខ្ញុំគ្មានលទ្ធភាពដូចជានាងទេ ព្រោះកាលបើខ្ញុំលះបង់នាងទៅហើយ នាងនឹងក្លាយទៅជាស្រីមេម៉ាយយ៉ាងកម្សត់ ! ខ្ញុំសូមប្រាប់អ្នកទាំងពីរថាក្នុងនាមខ្ញុំជាបញ្ញវ័ន្តម្នាក់ ខ្ញុំមិនអាចធ្វើយ៉ាងនេះបានចំពោះនារីដ៏កម្សត់ម្នាក់ ដោយគ្មានការពិចារណានោះទេ !

- សុជាតិ សម្ដីឯងគម្រក់ណាស់ ឯងកុំប៉ិនវោហារពាក្យប្រពន្ធឲ្យជាប់នឹងមាត់ពេក ឯងនិយាយថាប្រពន្ធរបស់ឯងទៅលេងផ្ទះម្ដាយនាង ឥឡូវបែរថាជាស្រីកំព្រាទៅវិញ បើតាមអញដឹងគឺជាល្បិចកលរបស់ឯងទាំងអស់ !

- ប្រាកដជាអ៊ីចឹងដែរលោកអ៊ំ នាងគ្មានឪពុកម្ដាយទេ គ្រាន់តែមានម្ដាយធម៌ដ៏ចំណាស់ម្នាក់ប៉ុណ្ណោះ !

- អញមិនជឿសម្ដីឯងជាដាច់ខាត ឯងនេះចង់លេងល្បែងដាក់អញហើយមើលទៅ មើលមុខអញឲ្យច្បាស់ណាំអញមិនត្រូវការចរិតក្រឡិចក្រឡុចរបៀបមនុស្សអាឯងនេះ មកធ្វើជាកូនប្រសាដែរតែអញមិនឲ្យឯងរួចខ្លួនជាដាច់ខាតអាកំហូច ព្រោះអាឯងបានផ្ដល់ការអាម៉ាស់ដល់អញ ឯងកុំភ្លេចថាម្ដាយឯងនៅសៀមរាបទេរ៉ឺយ !

- តើលោកអ៊ំចង់ធ្វើអីគាត់...ហ៊ឺះ ...

- បានហើយ ឈប់និយាយ អាឯងស្លាប់ទៅ ឯងនេះឲ្យអញអាម៉ាស់មុខមិនតិចទេ !

សម្រែករលត់ភ្លាម ខ្លួនរបស់សុជាតិក៏ដួលទៅលើសាឡុងជាមួយគ្នាដែរ ឈាមក្រហាមច្រាលហូរចេញពីដើមទ្រូងរបស់អ្នកកំលោះយើងឡើងទន់កល្បៀក !

- តោះ បុប្ផា យើងត្រឡប់ទៅវិញ ខ្លាចគេមកទាន់ណាំ !

គិតចំពោះសុខទុក្ខរបស់សុជាតិ ។

ម៉ោង១១ទៅហើយ នាងចេញមកឈរខាងក្រៅរង់ចាំវិសាល មកទទួលនាងតាមពាក្យរបស់គេ តែនៅមិនទាន់ឃើញរហូតគេចេញអស់ពីសាលា នាងសម្រេចចិត្តថា ហៅស៊ីក្លូជិះត្រឡប់មកផ្ទះវិញ !

- អេ៎ ម៉ូលីយ៉ា... នាងចាំអ្នកណាហ្នឹង ?

- អូ៎...ចាស សុផាន់ណា ខ្ញុំរង់ចាំបងប្រុសខ្ញុំមកទទួល តែក្រឡេកឃើញគាត់មកពេកខ្ញុំគិតហៅស៊ីក្លូជិះទៅ !

- មិនបាច់ទេម៉ូលីយ៉ា ខ្ញុំនឹងជូនឯងទៅ បងឯងប្រហែលជាជាប់រវល់ហើយមើល៍ទៅ !

- ចាស អរគុណសុផាន់ណាហើយ តែខ្ញុំមិនចង់ឲ្យរំខានដល់សុផាន់ណាឯងទេ ដូច្នេះខ្ញុំអាចជិះស៊ីក្លូបានហើយ !

- មិនអីទេម៉ូលីយ៉ា ឯងកុំគិតថាខ្ញុំទើសទាល់អី !

ដោយពិបាកនឹងប្រកែកពេក ណាមួយទីកន្លែងនេះស្ងាត់ជ្រងំរាំមិនសូវសមរម្យផង នាងក៏សម្រេចចិត្តជិះម៉ូតូជាមួយនឹងសុផាន់ណាម្តងទៀត !

គេនាំនាងមកដាក់ផ្ទះសុជាតិឯស្ពានអូឡាំពិកឯណោះវិញ តែនាងក៏មិនប្រកែកដែរព្រោះត្រូវយកសៀវភៅខ្លះទៀតផង ដែលភ្លេចពីក្បាលល្ងាច ណាមួយនាងមិនចង់ឲ្យវិសាលមិត្តរបស់សុជាតិដឹងថា

នាងត្រូវបានសុផាន់ណាជូនមកផ្ទះ ព្រោះខ្លាចគេប្រាប់រឿងនេះដល់សុជាតិ ហើយសុជាតិនឹងស្ដីបន្ទោសឲ្យនាងដូចកាលពីមុនទៀត ។

កញ្ញាចុះពីម៉ូតូតម្រង់ចូលទៅក្នុងផ្ទះ ដោយដកកូនសោតាមផ្លូវរួចជាស្រេច នាងគិតថានឹងយកសៀវភៅ ហើយជិះស៊ីក្លូត្រឡប់ទៅផ្ទះវិសាលវិញ ស្រីបោះជំហានមកដល់មាត់ទ្វារនាងភ្ញាក់កន្ត្រាក់ព្រោះទ្វារអត់មានចាក់សោទេ ស្រីប្រញាប់ច្រានទ្វារចូលរឹតតែភ្ញាក់ណាស់ទៅទៀត អ្នកប្រុសសុជាតិដែលដេកលើសាឡុងទាំងឈាមជោកអាវពណ៌ពងក្រសា ។ ស្រស់ស្រីនាងភ័យស្ទើរបាត់ស្មារតី ខ្លួននាងឡើងញ័រដូចជាកូនសត្វ ព្រមទាំងចាប់ភ្លឹកជាមួយនឹងក្រដាសអារាត់អារាយនៅទីនោះប្រញាប់ទៅរើសវាមកផ្គុំហើយអាន គឺជាសំបុត្រអាពាហ៍ពិពាហ៍រវាងនាងនិងសុជាតិ ស្រីកាន់តែស្រឡាំងកាំងខ្លាំងឡើង ជាពិសេសនាងភ័យនឹងគ្រោះថ្នាក់ដែលផ្ដល់ឲ្យសុជាតិ ស្រីប្រញាប់ទៅអង្រួនគេដែលសន្លប់បាត់ស្មារតីទាំងទឹកភ្នែកហូររហាម ។

- លោកសុជាតិ លោកសុជាតិ !

គ្មានអ្វីតបក្រៅពីសំឡេងរថយន្ត ដែលគ្រហឹមនៅទីថ្នល់តែប៉ុណ្ណោះ ទិដ្ឋភាពស្ងាត់ជ្រងំធ្វើឲ្យនាងព្រឺព្រួចដល់ឆ្អឹងខ្នង នាងចាប់អង្រួនគេម្ដងហើយម្ដងទៀតនៅតែស្ងៀមដដែល ដូចជាមិនអស់ចិត្តថាគេស្លាប់នាងដាក់ត្រចៀកលើដើមទ្រូងគេស្ដាប់ដង្ហើម គេនៅមាន

ដង្ហើមនៅឡើយ ស្រីដូចជាអរបន្តិចតែនៅពិបាកច្រើនយ៉ាងទៀត គឺមធ្យោបាយនាំគេទៅមន្ទីរពេទ្យ មិនដឹងជាជីវិតរបស់គេទៅជាយ៉ាងណាដែរហើយ ។

តូចតន់នៅតែយំមិនបាត់ នាងរត់ចូលទៅក្នុងបន្ទប់សុជាតិដែលបើកទ្វារចំហស្រេចហើយ លើកទូរស័ព្ទទៅកាន់មន្ទីរពេទ្យដែលគេធ្វើការជាបន្ទាន់ ។ មួយសន្ទុះធំទើបរថយន្តពេទ្យមកដល់ ហើយអ្នកជិតខាងនិងអ្នកដំណើរខ្លះផ្អើលមកមើលឈូឆរ តែគ្មានអ្នកណាម្នាក់ដឹងពីមូលហេតុនៃគ្រោះថ្នាក់នេះឡើយ ។

រថយន្តពេទ្យចេញទៅហើយ ដែលនៅលើរថយន្តម៉ូលីយ៉ានៅតែយំមិនបាត់ នាងភ័យក្រែងគេស្លាប់ ព្រោះគេជាអ្នកមានគុណលើរូបនាងមិនចង់ឃើញការឈឺចាប់និងទុក្ខសោករបស់គេទេ ។

ក្រោយពីការពិនិត្យរួចរាល់ហើយ គ្រូពេទ្យបាននិយាយថាត្រូវតែធ្វើការវះកាត់យកគ្រាប់ចេញទើបបាន ! ម៉ូលីយ៉ាកាន់តែភ័យនាងសួរទៅគ្រូពេទ្យវិញ :

- អត់ទោសលោក ការវះកាត់នេះអាចជួយជីវិតគាត់បានទេលោកគ្រូពេទ្យ ?

- ហ៊ឺ...ពិបាកណាស់អ្នកស្រី ពុំអាចសន្និដ្ឋានបានថាអ្នកជំងឺត្រូវតែជានោះទេ តែសូមអ្នកស្រីកុំអាលអស់សង្ឃឹមធ្វើអី ទោះជា

យ៉ាងណាក៏អាចសង្ឃឹមបាន៥០ភាគរយដែរ !

ការសន្ទនាត្រូវបានផ្អាក ព្រោះបុគ្គលិកពេទ្យរូបនោះបានរុញអ្នកកំលោះសុជាតិចូលទៅក្នុងបន្ទប់វះកាត់បាត់ទៅហើយ ! ម៉ូលីយ៉ានាងរង់ចាំរយៈពេលវះកាត់នេះយ៉ាងតក់ក្រហល់ជាទីបំផុត ស្រីបារម្ភគ្រប់យ៉ាង ណាមួយពុំបានឲ្យដំណឹងនេះទៅវិសាលទៀត ព្រោះនាងពុំបានស្គាល់លេខទូរស័ព្ទរបស់គេ ។

ប្រហែលជា៣ម៉ោងបានកន្លងផុតទៅ ទើបការវះកាត់នោះរួចរាល់ជាស្ថាពរ សុជាតិត្រូវបានបញ្ជូនទៅសាលកញ្ចក់មួយយ៉ាងស្អាត គេអនុញ្ញាតឲ្យម៉ូលីយ៉ាចូលទៅកំដរ ។ លោកវេជ្ជបណ្ឌិតឃើញស្រស់ស្រីដូចជាភិតភ័យ គាត់ក៏មានប្រសាសន៍ពន្យល់ថា :

- សូមអ្នកស្រីកុំភិតភ័យពេក លោកសុជាតិមិនអីទេ ព្រោះគ្រាប់កាំភ្លើង៣គ្រាប់ត្រូវបានវះយកចេញ និងត្រូវកាត់ពោះវៀនខ្លះ តែជំងឺនេះត្រូវការព្យាបាលរយៈពេលយូរបន្តិចហើយ !

- ចាស អរគុណលោកដុកទ័រណាស់ !

លោកគ្រូពេទ្យដើរចេញទៅបាត់ស្រស់ស្រីនាង នៅមើលប្លោកសេរ៉ូមដែលដាក់ព្យួរឲ្យគេ ។ ចំណែកវិសាលពេលដែលម៉ូលីយ៉ាចេញពីសាលាបាត់ ធ្វើឲ្យគេអស់សង្ឃឹមរលីង អ្នកដើររកនាងគ្រប់ទីកន្លែងនៅតែមិនឃើញទៀត គេក៏ត្រឡប់មកផ្ទះវិញទាំងមុខមិនសូវស្រួល

គ្រាន់តែមកដល់ផ្ទះមិនទាន់ឃើញនាងទៀត គេរឹតតែជ្រួលច្របល់ខ្លាំងឡើង ទឹកមុខគេចាប់ផ្ដើមប្រែប្រួលមិនឈប់ក៏សួរទៅមីងបម្រើដែលនៅផ្ទះបាយថា :

- មីង មានឃើញម៉ូលីយ៉ាដែរទេ ? អាពូកម៉ាកខ្ញុំវាយកមកផ្ញើកាលពីព្រឹកមិញនេះ តើមកពីរៀនហើយឬនៅ ?

- ចាស មិនទាន់ត្រឡប់មកវិញទេអ្នកប្រុស !

- ចំជារំខានមែន មីងមិនបាច់មើលផ្លូវខ្ញុំទេ ខ្ញុំទៅណោះមួយភ្លែតសិន !

- អ៊ីចឹងអ្នកប្រុសញ៉ាំបាយសិនទៅ ប្រយ័ត្នខ្យល់ចាប់ណា !

- បាទ មិនអីទេមីង !

និយាយចប់ អ្នកប្រុសបើករថយន្តសំដៅផ្ទះសុជាតិយ៉ាងលឿនគ្រាន់តែទៅដល់អ្នកជិតខាងរត់មកចោមរោមអ្នកជុំជិត !

សុជិនដែលនៅខាងជើងផ្ទះរបស់សុជាតិសួរអ្នកទាំងរហាន់ថា :

- បងប្រុស តើបងសុជាតិយ៉ាងម៉េចទៅហើយ ?

អ្នកប្រុសសួរដោយឆ្ងល់ទៅអ្នកទាំងអស់គ្នាវិញ :

- តើសុជាតិគេកើតអី ?

- គាត់ត្រូវគេលួចបាញ់កាលពីព្រឹកមិញ បងមិនដឹងទេឬ ?

ដំណឹងនេះធ្វើឲ្យវិសាលឡើងភាំងស្មារតីមួយរំពេច គេសួរទៅ

អ្នកទាំងនោះវិញយ៉ាងលឿន :

- តើសុជាតិមានគ្រោះថ្នាក់ពីរឿងអ្វីដែរទៅ ?

សំណួរនេះពុំបានសមតាមបំណងរបស់អ្នកទេ ព្រោះគេទាំងអស់គ្នាគ្មានអ្នកណាដឹងពីមូលហេតុនៃគ្រោះថ្នាក់នេះឡើយ វិសាលក៏រហ័សទៅមន្ទីរពេទ្យជាបន្ទាន់ នៅក្បែរនោះ គឺម៉ូលីយ៉ាអង្គុយបក់ផ្លិតឲ្យគេ នាងមិនទាន់ញុំាបាយទេ តែការភិតភ័យទាំងប៉ុន្មានបានធ្វើឲ្យឃ្លាតឆ្ងាយពីការស្រេកឃ្លានទៅហើយ ។

ជាមួយគ្នានោះដែរវិសាលចូលមកដល់ល្មម នាងក្រោកឈរដូចជាភ្ញាក់ តែមិនបាននិយាយអ្វីទេ គ្រាន់តែសម្ដែងទឹកមុខកោតខ្លាចចំពោះវិសាលតែប៉ុណ្ណោះ ។

វិសាលរហ័សសួរទៅនាងយ៉ាងលឿន :

- តើសុជាតិមានគ្រោះថ្នាក់ដោយសាររឿងអីដែរ មានដឹងទេម៉ូលីយ៉ា ?

ម៉ូលីយ៉ាគ្រវីក្បាលជំនួសចម្លើយ នរៈសួរបន្តទៀត :

- ចុះហេតុអីបានជានាងដឹងថាគេមានគ្រោះថ្នាក់ ?

- ខ្ញុំចាំលោករហូតគេចេញពីសាលាអស់ហើយ នៅមិនឃើញលោកមកទទួលទៀត ខ្ញុំក៏ជិះម៉ូតូជាមួយនឹងមិត្តភក្តិ គិតថាចូលមកយកសៀវភៅខ្លះដែលខ្ញុំភ្លេចយកទៅមិនអស់នោះ ស្រាប់តែមកដល់

ជួបនឹងព្រឹត្តិការណ៍នេះតែម្តង គឺលោកសុជាតិសន្លប់នៅលើសាឡុង !

វិសាលមិនទាន់បានតបទៅម៉ូលីយ៉ាវិញយ៉ាងម៉េចផង គេគ្រាន់តែគិតពីបញ្ហាគ្រោះថ្នាក់នេះ ស្រាប់តែក្រុមប៉ូលិស ដែលមានលោកវេជ្ជបណ្ឌិតជាប្រធានកាន់កាប់នៅក្នុងមន្ទីរពេទ្យជាអ្នកនាំ បានចូលមកដល់ ។ គេបានឲ្យម៉ូលីយ៉ាទៅធ្វើការបកស្រាយពីរឿងនោះនៅពេលដែលម៉ូលីយ៉ារៀបរាប់ វិសាលបាននិយាយប្រាប់នាងវិញថា :

- ម៉ូលីយ៉ា នាងឆ្លើយការពិតដែលបាននិយាយប្រាប់បងមុននេះហ្នឹងទៅណ៎ា !

ស្រស់ស្រីងក់ក្បាល ហើយដើរចេញទៅជាមួយក្រុមក្រសួងមានសមត្ថកិច្ច ។ លទ្ធផលនៃការស៊ើបសួរចម្លើយរបស់ក្រុមប៉ូលីសគ្មានបានប្រយោជន៍អ្វីទាំងអស់ ព្រោះម៉ូលីយ៉ានាងមិនបានដឹងពីមូលហេតុនេះទេ ដូច្នេះកិច្ចការទាំងនេះត្រូវស្ថិតនៅក្នុងការតាមដាននៅឡើយ ។ ម៉ូលីយ៉ាត្រូវបានត្រឡប់មកកាន់មន្ទីរពេទ្យវិញ ។

ពេលព្រលប់ៗទៅហើយ ស្រស់ស្រីនាងល្វិតល្វៃអស់កម្លាំងពីខ្លួនរលីង ក្បាលរបស់នាងឈឺខ្ទោកៗដើរតិចៗសឹងតែទៅមិនដល់បន្ទប់របស់សុជាតិ ពេលដែលនរៈដឹងខ្លួនឡើងគេមិនអាចនិយាយអ្វីបានទេព្រោះនរៈកំពុងដាក់ខ្យល់អុកស៊ីសែននៅឡើយ វិសាលឥតទាន់ទៅណាទេ គេនៅអង្គុយកំដរមិត្ត ព្រមទាំងបុគ្គលិកពេទ្យ២នាក់ទៀត

ដែលគេទាំងពីរនោះ លួចពេញចិត្តនឹងដុកទ័រកំលោះយើងតែរៀងៗខ្លួន ជាយូរណាស់មកហើយដែរ ។ ម៉ូលីយ៉ាដើរចូលមកដោយស្ងៀមស្ងាត់ ឃើញដូច្នោះវិសាលរហ័សមកទទួលនាង គេសួរទៅនាងតិចៗថា :

- យ៉ាងម៉េចដែរម៉ូលីយ៉ា ?

- ចាស គ្មានបានលទ្ធផលអ្វីទេលោក ព្រោះខ្ញុំពុំបានដឹងរឿងដើមនៃគ្រោះថ្នាក់របស់លោកសុជាតិទាល់តែសោះ !

- អឺ... នាងរួចពីការសួររបស់គេហើយមែនទេ ?

- ចាស មិនអាចចាត់ទុកថារួចខ្លួននោះទេលោក ព្រោះគេនិយាយថារឿងនេះស្ថិតនៅក្នុងការតាមដាននៅឡើយ !

- នាងប្រហែលជាភ័យណាស់មែនទេ បានជានាងមានមុខខ្មៅយ៉ាងនេះម៉ូលីយ៉ា !

- ចាស ភ័យមែនលោក ! តែមិនមែនភ័យរឿងជាប់ចោទនោះទេ គឺខ្ញុំព្រួយបារម្ភពីសុខភាពរបស់លោកសុជាតិ...ក្រែង...

ស្រីស្រដីបានតែប៉ុណ្ណេះ ដោយចោលភ្នែកទៅអ្នកកំលោះដែលកំពុងតែគេងស្តូកស្តឹង ហើយសម្លឹងមើលមកនាងវិញ ត្បិតតែគេមិនអាចហាមាត់និយាយបាន តែតាមក្រសែភ្នែកដ៏ស្រទន់មានទឹកដមនេះ នាងអាចដឹងថាគេយកចិត្តទុកដាក់នឹងវត្តមានរបស់នាងណាស់ ។

ស្រស់ស្រីមិនវាចាអ្វីទៀតទេ នាងបង្ហួសដំណើរតម្រង់គ្រែ

សុជាតិ អ្នកប្រុសនៅតែសម្លឹងនាងមិនដាក់ភ្នែកដដែល ។

ច្រើនថ្ងៃបានកន្លងផុតទៅក្រោមការយកចិត្តទុកដាក់របស់គ្រូពេទ្យទាំងអស់ ពិសេសគឺស្រស់ស្រីម៉ូលីយ៉ាផ្ទាល់ អ្នកកំលោះបានធូរស្រាលអាចញ៉ាំទឹកក្រូចនិងទឹកដោះគោបានខ្លះៗហើយ ។ ថ្ងៃនេះនៅពេលដែលម៉ូលីយ៉ាមកពីទិញក្រូចវិញ នាងញញឹមដាក់គេយ៉ាងស្រស់ហើយសួរទៅកាន់នរៈថា :

- ថ្ងៃនេះលោកបានធូរស្រាលជាងពីម្សិលមិញហើយមែនទេ?

- បានធូរច្រើនហើយម៉ូលីយ៉ា ថ្ងៃស្អែកនាងមិនបាច់មកកំដរខ្ញុំទៀតទេ ព្រោះនាងខានរៀនច្រើនថ្ងៃណាស់មកហើយ !

- តែលោកមិនទាន់ជាឯណា !

- បានប៉ុណ្ណេះចាត់ទុកថាជាហើយ ថ្ងៃស្អែកនាងទៅរៀនចុះមកអើតខ្ញុំតែពេលបាយព្រឹកបាយល្ងាចបានហើយ !

- ខ្ញុំមិនអាចធ្វើយ៉ាងនេះបានទេលោក ខ្ញុំនឹងកំដរលោករហូតបានជាសះស្បើយជាងនេះ !

- ខ្ញុំយល់ហើយ តែការប្រឡងរបស់នាងមានតម្លៃណាស់... ហើយបើសិនណាជានាងធ្លាក់ គឺមិនមែនតែរូបនាងទេដែលមានការសោកស្ដាយនោះ ជាពិសេសគឺរូបខ្ញុំព្រោះខ្ញុំជាអ្នកឧបត្ថម្ភនាង ដើម្បីឲ្យនាងប្រឡងជាប់ ហើយខ្ញុំនឹងរកការងារឲ្យនាងធ្វើគឺអ្វីៗទាំងអស់

ដើម្បីតែអនាគតរបស់នាង ។

សម្ដីគេមានន័យទូលំទូលាយណាស់ ក្នុងការយកចិត្តទុកដាក់ចំពោះអនាគតរបស់នាង ខុសប្លែកពីឪពុកនាងដែលមិនសូវខ្វល់ខ្វាយពីអនាគតរបស់កូន ។ ម៉ូលីយ៉ាទម្លាក់មុខចុះសម្លឹងឥដ្ឋការ៉ូធ្វើភ្នែកភ្លឹះៗជាមួយនឹងទឹកមុខស្រពាប់ស្រពោនស្រគត់ស្រគុំនេះ ត្រូវបាននេត្រាអ្នកកំលោះថតយកគ្មានសល់ គេហាក់ពេញចិត្តនាងចម្លែក អ្វីដែលកើតមាននៅក្នុងដួងចិត្តរបស់គេពេលនេះគឺសេចក្ដីស្នេហា។ តែវាជាស្នេហាចម្លែកបំផុត ព្រោះគេពុំនឹកនាដល់ពាក្យលួងលោមប្រលោមស្នេហ៍ចំពោះនាងទាល់តែសោះ សូម្បីតែអាកប្បកិរិយាទន់ភ្លន់ចំពោះនាងក៏គ្មានដែរ ឬក៏គេពុំអាចធ្វើយ៉ាងនេះបានដោយសារតែនាងមានគូដណ្ដឹងរួចទៅហើយ ចុះសំបុត្រអាពាហ៍ពិពាហ៍ដែលអ្នកបានចុះជាមួយនាងនោះ មិនបានន័យថាអ្នកបានរកមធ្យោបាយមួយ ដើម្បីទាក់ទាញចិត្តនាងឲ្យស្រឡាញ់អ្នកទេឬ ? នឹកដល់ត្រង់នេះសុជាតិសួរទៅម៉ូលីយ៉ាថា :

- ម៉ូលីយ៉ា...នាងមិនឆ្ងល់ថាខ្ញុំមានគ្រោះថ្នាក់នេះដោយសារអ្វីទេឬ ?

សំណួរនេះធ្វើឲ្យស្រស់ស្រីអស់សំណើចខឹកៗ ការពិតនាងឆ្ងល់ខ្វល់ខ្វាយរាល់ថ្ងៃ គេងមិនលក់បាយមិនបាន ក៏ដោយសារតែរកមូល

ហេតុនេះមិនឃើញហ្នឹងឯង !

ស្រីប្រញាប់ឆ្លើយទៅគេវិញភ្លាម :

- ចាស ខ្ញុំសែនឆ្ងល់ពីរឿងគ្រោះថ្នាក់របស់លោក តែលោកទើបនឹងជាពីរឬសខ្ញុំមិនហ៊ានសួរ !

- ចុះនៅពេលដែលនាងទៅដល់ហើយ ឃើញខ្ញុំសន្លប់នាងមិនប្រទះអ្វីដែលប្លែកសម្រាប់នាងទេឬ ?

- ឃើញរូបលោកពេលមានគ្រោះថ្នាក់នេះហើយ ដែលធ្វើឲ្យខ្ញុំសង្ស័យនិងសែនឆ្ងល់រកទីបំផុតគ្មាន !

- ខ្ញុំមិនចង់សួរអីចឹងទេ ម៉ូលីយ៉ាសម្តីនាងនិយាយដូចជានាងនៅតូចណាស់ មិនខុសពីក្មេងដែលទើបតែនឹងចូលសាលាមត្តេយ្យទេ ខ្ញុំចង់សួរនាងថាក្រៅពីរូបខ្ញុំដែលមានគ្រោះថ្នាក់ តើនាងជួបប្រទះនឹងអ្វីដែលប្លែកឲ្យនាងសម្រាប់សង្ស័យទេ ?

- ចាស គ្មានទេលោក !

- អីចឹងពេលដែលនាងទៅដល់ មានអ្នកណាដឹងក្រៅពីនាងទៀតដែរទេ ?

- មិនដឹងទេលោក អ្នកជិតខាងគ្មានអ្នកណាបានដឹងពីរឿងហេតុដែលកើតឡើងនោះឡើយ ! គឺខ្ញុំនេះជាអ្នកដែលបានដឹងមុនគេ ព្រោះខ្ញុំត្រូវចូលទៅយកសៀវភៅ ដែលខ្ញុំភ្លេចមិនបានយកកាលពី

ព្រលឹមនោះ !

- ខ្ញុំមិនជឿទេ បើសិនជានាងមកមុនគេនឹងឃើញក្រដាសគេហែកចោលអារាត់អារាយនៅទីនោះជាមិនខាន !

- តើក្រដាសនោះនិយាយពីអ្វីដែរទៅ ? ហើយលោកមិនគិតថាជនដែលផ្តល់គ្រោះថ្នាក់ដល់លោកបានរើសក្រដាសនោះទៅទេឬ ?

-ណ្ហើយ...ឥឡូវខ្ញុំសន្មតថានាងពុំបានឃើញទៅចុះ តែខ្ញុំគ្រាន់ប្រាប់នាងឲ្យដឹងថាក្រដាសដែលរហែកអារាត់អារាយនោះវាជាសំបុត្រអាពាហ៍ពិពាហ៍រវាងខ្ញុំហើយនិងនាង !

ពោលមកដល់ត្រង់នេះគេសម្លឹងមុខស្រីបន្តិចហាក់ដូចជាកំពុងស្ទាបស្ទង់ចិត្តរបស់នាងមានប្រតិកម្មយ៉ាងណាដែរ ពេលដែលបានស្តាប់សម្តីរបស់គេបែបនេះ ! ម៉ូលីយ៉ាមិននិយាយតបទៅវិញយ៉ាងណាទេ នាងគ្រាន់តែសម្លឹងអ្នកប្រុសវិញ ទាល់តែគេដាក់ភ្នែកចុះ ទើបនាងនិយាយដោយច្បាស់ៗថា :

- ព្រោះតែសំបុត្រនេះទើបលោកមានគ្រោះថ្នាក់មែនទេ ខ្ញុំហាក់យល់ពីហេតុការណ៍នេះហើយ ខ្ញុំនឹងរាយការណ៍ពីរឿងនេះទៅដល់ក្រសួងមានសមត្ថកិច្ច ដើម្បីកុំឲ្យគេសង្ស័យ និងចាប់កំហុសមកលើខ្ញុំទៀត ដែលបណ្តោយឲ្យលោកមានគ្រោះថ្នាក់បែបនេះ !

- បានហើយ មិនបាច់ធ្វើយ៉ាងនេះទេ នាងគ្មានកំហុសអ្វីទាំង

អស់ ម៉ូលីយ៉ា គឺរូបខ្ញុំទេដែលមានកំហុស ហើយត្រូវតែទទួលទោ
ដោយគ្រោះថ្នាក់របៀបនេះ ទី១ខ្ញុំក្បត់គូដណ្ដឹងមិនព្រមទៅរៀបកា
ទី២គឺកំហុសដ៏ធ្ងន់ធ្ងរ ដោយលួចគូដណ្ដឹងរបស់គេមកចុះសំបុត្រដោយ
ខុសច្បាប់ មិនមានការអនុញ្ញាតពីសាមីខ្លួនខាងស្រីទាល់តែសោះ !

- ខ្ញុំក៏មិនឲ្យលោកមានកំហុសដែរ ! ខ្ញុំនៅតែចាត់ទុកលោក ថាជាអ្នកមានគុណមួយរូបដដែល !

- អ៊ីចឹងនាងមិនខឹងខ្ញុំដែលលួចចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនាងទេឬ ?

- ចាស មិនខឹងទេលោក !

- ចុះបើសិនជាការពិត តើនាងអាចរៀបការជាមួយខ្ញុំបានទេ សូមនាងនិយាយមកមើល៍ ?

- ចាសបាន ខ្ញុំអាចបំពេញបំណងលោកបានទាំងអស់ តែលោកត្រូវតែយល់ថា គ្រាន់តែលោកចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយខ្ញុំប៉ុណ្ណេះ លោកអាចមានគ្រោះថ្នាក់ដល់ម្លឹងទៅហើយ ចុះទម្រាំទៅរៀបការជាមួយនឹងខ្ញុំទៀត តើរូបលោកនឹងក្លាយទៅជាយ៉ាងណាទៅវិញទៅ ? ដើម្បីការពារគ្រោះថ្នាក់លោកផ្ទាល់ ខ្ញុំក៏មិនត្រូវការបំពេញបំណងលោកដែរ បើក្រៅពីនេះ ទោះជាលោកឲ្យខ្ញុំធ្វើយ៉ាងនេះដើម្បីតែសុភមង្គលរបស់លោកតែប៉ុណ្ណោះ ចំណែករូបខ្ញុំគឺខ្ញុំមិនគិតទេ !

- ចុះបើខ្ញុំធានាសន្តិសុខចំពោះនាងបាន នៅពេលដែលខ្ញុំរៀបការជាមួយនាងហើយ នាងសុខចិត្តរៀបការជាមួយខ្ញុំដែរទេ នាងឆ្លើយឲ្យត្រង់ណា កុំបង្ខំចិត្តបញ្ឆាគំនិតកុហកលើខ្លួនឯងឲ្យសោះ !

- ចាស ប្រាកដជាបាន ហើយខ្ញុំពេញចិត្តនឹងរៀបការជាមួយលោក ដោយគ្មានបង្ខំចិត្តរបស់ខ្ញុំបន្តិចទាល់តែសោះ !

- អ៊ីចឹងបានន័យថានាងក្បត់ចិត្តនឹងបងប្រុសបូរីដើម្បីតបស្នងសងគុណចំពោះខ្ញុំហើយ ខ្ញុំជឿជាក់ថាប្រសិនបើថ្ងៃណាមួយនាងជំពាក់បុណ្យអ្នកណាម្នាក់ទៀត នាងនឹងក្បត់ចិត្តពីខ្ញុំដើម្បីសងគុណចំពោះគេដទៃណាម្នាក់ទៀត គិតទៅគំនិតនាងគ្មានថ្លៃថ្នូរដូចពាក្យសម្តីនាងទាល់តែសោះ គឺថោកទាបមួយចប់ !

សម្តីមួយឃ្លាមិនបានធ្វើឲ្យនាងចង់សើច ដូចកាលដែលគេបានជេរនាងថាថោកទាបពីលើកមុននោះទេ ព្រោះអត្តចរិតពេលនេះខុសឆ្ងាយពីថ្ងៃមុន គឺពិតជាពូថៅយ៉ាងធំកំពុងសំពងចំកណ្តាលក្បាលរបស់នាងហើយ ។ ពេលនេះសុជាតិឃើញនាងស្រក់ទឹកភ្នែកច្រោកៗដូចបាក់ទំនប់កំពីងពួយ នាងយំខ្សឹកខ្សួលអួលអាក់តែម្នាក់ឯង ។

ព្រលប់ឈានមកដល់ទៀតសុជាតិមិនរវល់ជួយលួងលោមនាងទេ ស្រស់ស្រីនៅតែយំមិនបាត់ដដែល ទ្រាំស្ងៀមមិនបានគេក៏និយាយគំហកឲ្យនាងថា :

ចេះតែនឹកឃើញវែងឆ្ងាយ នាងខ្លាចគ្រោះថ្នាក់ដែលមើលមិនឃើញក្នុងវេលាយប់ ណាមួយសុជាតិមិនទាន់ញ៉ាំអ្វីទៀត តើមានអ្នកណាច្របាច់ក្រូចនិងឆុងទឹកដោះគោឲ្យគេ បើនាងមិននៅយប់ព្រលប់បើគេមិនស្រួលឬយ៉ាងណា ធ្វើម្ដេចនឹងបានដឹងដល់គ្រូពេទ្យជាប្រញាប់ អ្នកជំងឺធ្ងន់យ៉ាងនេះមិនអាចនៅម្នាក់ឯងបានទេ ទោះជាបុគ្គលិកពេទ្យទាំងអស់និងលោកដុកទ័រយកចិត្តទុកដាក់នឹងគេ ដោយសារខ្លួនគេធ្វើការនៅទីនេះដែរក៏ដោយ ។

គំនិតនេះបានធ្វើឲ្យម៉ូលីយ៉ាត្រូវតែកាត់ចិត្តទទួលការអាម៉ាស់ម្ដងទៀត ដើម្បីកុំឲ្យផុតថ្ងៃស្អែកបានទៅមុខ នាងនឹងមានការស្ដាយក្រោយដែលខ្លួនធ្វើដោយពុំបានគិតគូរនូវអ្វី១ល្អិតល្អន់ ។

ស្រស់ស្រីនាងប្រញាប់ត្រឡប់ទៅវិញ រៀបនឹងបើកទ្វារចូលទៅហើយ តែឃើញគិលានុបដ្ឋាយិកាម្នាក់កំពុងតែចាក់ថ្នាំឲ្យសុជាតិ នាងផ្អាកដំណើរទៅវិញហើយឈរកៀនទ្វារចាំលបមើល នាងគ្រាន់តែចង់ដឹងថាសុជាតិដេញនាងឲ្យត្រឡប់ទៅវិញដោយសារតែគេខ្លាចរំខានដល់ការជួយកំដររបស់នារីពេទ្យទាំងនោះឬមួយយ៉ាងណា ? នារីនោះចាក់ថ្នាំហើយក៏បិទប្រដាប់ប្រដាហើយក្រោកដើរទៅវិញ ម៉ូលីយ៉ាដើរចូលទៅ ស្ត្រីពេទ្យក៏សួរមកនាងវិញ :

- បងស្រីទើបតែអញ្ជើញមកទេឬ ?

- ចាស !

- អ្នាំ ម៉ូលីយ៉ា នាងមកធ្វើអីទៀត !

- យប់ងងឹតយ៉ាងនេះខ្ញុំមិនហ៊ានត្រឡប់ទៅវិញទេលោក !

- ខ្ញុំយល់ដូច្នោះដែរ ទើបមិនហ៊ានឃាត់ដំណើរនាង តែនាងជជែកនឹងខ្ញុំដោយមិនគិតថាត្រូវត្រឡប់ទៅវិញនៅថ្មើរណា ដើម្បីឲ្យវាទាន់ពេលវេលានោះ !

- បើសិនជាលោកនិយាយអ៊ីចឹងតាំងពីនៅភ្លឺម្ល៉េះ តែនេះលោកនិយាយថា លែងត្រូវការខ្ញុំមកកំដរនៅថ្ងៃស្អែកទេតើ !

ចប់សម្តីម៉ូលីយ៉ាដាក់កន្ត្រកអីវ៉ាន់ទុក ហើយចាប់ផ្តើមជូតឥដ្ឋការ៉ូដើម្បីសម្រាកក្នុងយប់នេះ !

- ម៉ូលីយ៉ា នាងគិតគេងនៅលើឥដ្ឋហ្នឹងមែនទេ ?

- ចាស !

នាងឆ្លើយដោយបន្តការជូតទៅទៀត អ្នកប្រុសក៏ស្រដី :

- មិនសមរម្យទេម៉ូលីយ៉ា នាងធ្វើយ៉ាងនេះពិតជាគេវាយតម្លៃដល់ខ្ញុំទៀតហើយ នាងគេងនៅលើគ្រែជាមួយខ្ញុំមក ! គ្រែនេះទូលាយអាចឲ្យនាងគេងបានហើយនាងក៏មិនត្រូវគិតពីការមិនសមរម្យអ្វីទាំងអស់ចំពោះភ្នែកអ្នកដទៃ ព្រោះការរស់នៅរបស់នាងក្នុងផ្ទះខ្ញុំរាល់ថ្ងៃនេះវាជាការមិនសមរម្យណាស់ទៅហើយ ចំពោះមនុស្សដែល

គេដឹងថានាងមិនមែនជាសាច់ឈាមរបស់ខ្ញុំហើយខ្ញុំជាអ្នកជំងឺសូមនាងកុំបារម្ភក្រែងការភ្លើតភ្លើនវាអូសទាញឲ្យសោះ !

ស្តាប់សម្តីប្រុសកំលោះបណ្តើរ នាងនៅតែបន្តការជូតសម្អាតបណ្តើរ សុជាតិសែនក្នាញ់នឹងអាកប្បកិរិយាដ៏មានះរបស់នាង គេសម្លឹងនាងសឹងធ្លុះទើបបន្តសម្តីទៀត :

- យ៉ាងម៉េចម៉ូលីយ៉ា នាងស្តាប់មិនបានទេអ្ហេ៎ នាងធ្វើឲ្យខ្ញុំតឹងទ្រូងណាស់ !

តូចតន់ភ្ញាក់ក្រញាងនឹងប្រយោគចុងក្រោយនេះ នាងបញ្ឈប់សកម្មភាពជាបន្ទាន់ ហើយយកក្រណាត់ទៅរលាស់ហាល ដោយហួសទៅសម្អាតដៃជើងក្នុងបន្ទប់ទឹក ទើបចូលមកចិតក្រូចច្របាច់ដាក់កែវហើយជាស្រេច នាងកាន់មកជិតសុជាតិហើយសួរថា :

- លោកពិសាក្រូចទេ ?

អ្នកកំលោះមិនឆ្លើយ គេងក់ក្បាលមួយៗ ស្រស់ស្រីនាងទាញកៅអីមកអង្គុយក្បែរគេ ហើយយកស្លាបព្រាដួសទឹកក្រូចបញ្ចុកអ្នកប្រុសដោយផ្ចិតផ្ចង់ ។ សុជាតិសម្លឹងម្រាមដៃនាងដោយការពេញចិត្តកាយវិការដ៏ទន់ភ្លន់ ទឹកមុខធម្មតាបង្ហាញពីភាពស្រគត់ស្រគំនេះ អ្នកពេញចិត្តតាំងពីថ្ងៃដែលជួបនាងដំបូងម្ល៉េះ ។ ទឹកក្រូចប្រហែលជាអស់កន្លះកែវតូចហើយ ទើបអ្នកកំលោះប្រាប់ទៅនាង :

វិញសម្លឹងជញ្ជាំងមិនដាក់ភ្នែកដែរ យូរៗព្រួសួរជង្ហើមរបស់អ្នកកំលោះ ដកចេញមកវែងៗ... យូរណាស់ទើបគេនឹកឃើញសួរទៅនាងថា :

- ម៉ូលីយ៉ា នៅពេលដែលនាងប្រឡងជាប់នាងចេញធ្វើការ ឬចង់បន្តវិជ្ជានៅមហាវិទ្យាល័យទៀត !

- ចាស ខ្ញុំចង់ធ្វើការលោក !

- បើអ៊ីចឹង នាងចង់ទៅធ្វើនៅក្រសួងណាដែរ ?

- បើតាមចំណង់និងបំណងរបស់ខ្ញុំចង់ក្លាយជាអ្នកកាសែត តែខ្ញុំគ្មានលទ្ធភាពព្រោះខ្ញុំនៅខ្លាចច្រើន ភ័យច្រើន និងតក់ស្លុតចំពោះព្រឹត្តិការណ៍ណាដែលអស្ចារ្យ !

- បើនាងមានបំណងយ៉ាងនេះ នាងប្រាកដជាអាចក្លាយទៅជាអ្នកកាសែតបានហើយ ស្រេចតែចិត្តនាងទៅចុះ ! ខ្ញុំបានត្រឹមតែជួយផ្តល់ថវិកាឲ្យនាងរៀនសូត្រប៉ុណ្ណោះ ចំណែកការសម្រេចចិត្តគឺវាស្ថិតនៅលើរូបនាងទេ !

- តែវាជាការស្មុគស្មាញខ្ញុំគិតថាមិនបាច់ធ្វើការនៅតាមបណ្តាក្រុមហ៊ុនក៏បានដែរ !

- បើអ៊ីចឹងនាងគិតធ្វើការអីវិញទៅ ?

- ចាស ខ្ញុំគិតថាចូលធ្វើការនៅក្រសួងការបរទេស !

- តែទាមទារ ឲ្យនាងច្បាស់លាស់ខាងភាសាអន្តរជាតិច្រើន

ណាស់ណា !

- ចុះតាមចិត្តគំនិតរបស់លោកវិញ តើលោកចង់ឲ្យខ្ញុំធ្វើការនៅខាងណាដែរ ?

- ខ្ញុំចង់ឲ្យនាងក្លាយជាអ្នកគ្រូមួយរូប ដែលមាននាទីជាអ្នកផ្តល់ការអប់រំ គំនិតល្អ ដល់យុវជនគ្រប់រូប តែបើនាងគ្មានសម្បទាស្រឡាញ់មុខក្រសួងនេះទេ ខ្ញុំក៏មិនបង្ខំនាងដែរ !

- ខ្ញុំក៏មិនស្អប់មុខរបរនេះដែរលោក ហើយក៏ជាមុខរបរទីពដែលខ្ញុំពេញចិត្ត និងបានគិតទុកតាំងពីខ្ញុំនៅរៀនថ្នាក់ទាបម្ល៉េះ បើសិនណាជាលោកពេញចិត្ត ខ្ញុំសម្រេចយកមុខវិជ្ជាហ្នឹងតែម្តងទៅ !

- នាងគិតឲ្យបានស្រួលបួលណា កុំសម្រេចចិត្តរហ័សពេក... ចំណែកខ្ញុំមិនអន់ចិត្តទេ ទោះជានាងចូលចិត្តខាងក្រសួងណាក៏ដោយ តែបើត្រូវចិត្តខ្ញុំយ៉ាងនេះ ខ្ញុំសប្បាយចិត្តណាស់ !

គេទាំងពីរជជែកគ្នាទាល់តែលង់លក់ទៅ ក្នុងរាត្រីដ៏សែនរីករាយនេះជាទីបំផុត ។

# វគ្គទី៥
# សំណាងដួងចិត្ត

មួយរាត្រីបានកន្លងផុតទៅ...! ព្រឹកនេះម៉ូលីយ៉ានាងត្រូវបានចូលទៅសាលារៀនវិញ ព្រោះក្នុងការកំដរអ្នកកំលោះយើងនាងត្រូវអវត្តមានអស់៩ថ្ងៃ សិស្សទាំងអស់គ្នាអ្នកណាក៏រង់ចាំមើលផ្លូវរបស់នាងដែរ ជាពិសេសគឺមិត្តប្រុសសុផាន់ណារបស់នាង ដែលនាងសែនធុញថប់ជាទីបំផុត ។

ក្នុងរយៈពេលដែលម៉ូលីយ៉ាមិនបានទៅរៀន សុផាន់ណាក៏គេមិនបានទៅរៀនដែរ ទាំងនេះជាហេតុធ្វើឲ្យលោកគ្រូអ្នកគ្រូ និងសិស្សទាំងអស់ក្នុងថ្នាក់សន្និដ្ឋានបានពីរឿងរបស់គេទាំងពីរ ។ ដូច្នេះនៅក្នុងពេលព្រឹកនេះគ្រាន់តែចូលមកដល់ក្នុងថ្នាក់ភ្លាម ម្នាក់ៗនាំគ្នារត់មកគក់សុផាន់ណាគ្រប់គ្នា ហើយនិយាយថា :

- នែ៎...អាខ្នា កុំតុកស៊ិកពេករ៉ឺយ ព្រឹកនេះមេឃស្រឡះល្អហើយណាំ !

ចំណែកមិត្តនារីទាំងអស់វិញ ទះដៃហោរត់មកឱបស្រស់ស្រីយើងគ្រប់ៗគ្នា !

- ប្លែកម្ល៉េះពូកឯងថ្ងៃនេះ ?

- មិនប្លែកទេម៉ូលីយ៉ា គឺគេនឹករលឹកឯងហ្នឹងណាំ !

- ឯងនេះជ្រួលជ្រើមណាស់ កុំលេងអ៊ីចឹងនាំតែបានចិត្តទេ !

ម៉ូលីយ៉ាមើលមុខគេគ្រប់គ្នាហើយសួរទៅវិញ :

- ឆ្កួត ពួកឯងចង់និយាយពីស្អីហ្នឹង ?

- ម៉ូលីយ៉ា ឯងកុំស្មានថា ពួកយើងមិនដឹងណាំ !

- លោកគ្រូមកដល់ហើយវ៉ឺយ...ស្ងៀមទៅ !

ប្រធានថ្នាក់នារីស្រែកឡើង !

សិស្សទាំងអស់គ្នាចូលអង្គុយតាមកន្លែងដោយស្ងៀមស្ងាត់... លោកគ្រូហៅម៉ូលីយ៉ាឲ្យក្រោកឡើង ហើយក៏ស្រដី :

- ម៉ូលីយ៉ា បងប្រុសនាងបានជាហើយមែនទេ ?

- ចាស មិនទាន់ជាស្រួលបួលទេលោកគ្រូ គាត់ក្រែងខ្ញុំរៀនមិនទាន់គេ ទើបឲ្យខ្ញុំមករៀនមិនបាច់នៅកំដរទៀតទេ !

សូលីនជើងកំប្លែងហើយខិលជាងគេក្រាបមុខលើតុតបថា :

- លោកគ្រូអនុញ្ញាតឲ្យម៉ូលីយ៉ាឈប់រៀនទៅ ព្រោះអីកូនសិស្សលោកគ្រូម្នាក់គឺសុផាន់ណាគេរៀនពូកែណាស់ គេប្រាកដជាអាចពន្យល់ម៉ូលីយ៉ាបានហើយ !

លោកគ្រូមិនបន្ទោសសម្ដីកំប្លែងរបស់សូលីនទេ លោកសើចញឹម១ទាំងសម្លឹងម៉ូលីយ៉ា គាត់ងាកទៅសុផាន់ណាសិស្សសម្លាញ់គាត់

យ៉ាងមានន័យ ។ ម៉ូលីយ៉ាសែនពិបាកចិត្តនាងអង្គុយចុះទាំងមុខមិនស្រស់ ការសិក្សាក៏ចាប់ផ្ដើមដំណើរការជាធម្មតា។

ពេលចេញពីសាលា ម៉ូលីយ៉ាត្រូវរង់ចាំវិសាលមកទទួលនាងទៀត ក៏ឃើតពេលដូចជារាល់ដងដែរ ដូច្នេះនាងត្រូវសំកុកចាំគេនៅក្រោមដើមក្ទោកដូចជាពីពេលមុន ។ សិស្សានុសិស្សចេញស្ទាត់អស់ពីសាលាហើយ នៅមិនឃើញវិសាលមកដល់ទៀត សុផាន់ណាដឹកម៉ូតូដើរចេញមកសំដៅរូបនាង !

- ម៉ូលីយ៉ា នាងចាំបងប្រុសមែនទេ ?

- ចាស ! ( នាងឆ្លើយយ៉ាងកំបុត )

- ខ្ញុំសុំជូននាងទៅផ្ទះម្ដងទៀតបានដែរទេ ?

- ចាស អរគុណសុផាន់ណាហើយ បងប្រុសខ្ញុំឲ្យខ្ញុំនៅចាំគាត់មិនឲ្យខ្ញុំជិះជាមួយនឹងអ្នកណាទេ ព្រោះគាត់មានការសំខាន់ដែលទាក់ទងដល់រូបខ្ញុំ !

- អ៊ូ...និយាយអីចឹងបងប្រុសម៉ូលីយ៉ាដែលគេលួចបាញ់នោះយ៉ាងម៉េចទៅហើយ ?

- ចាសមិនទាន់ជាទេ ត្រូវសម្រាន្តពេទ្យរាល់ថ្ងៃ សុផាន់ណាឯងទៅមុនចុះកុំឈរវេរាយ៉ាងនេះមិនសមទេ ដូចសុផាន់ណាឯងដឹងស្រាប់ហើយកាលពីព្រឹក ពួកគេមានអាកប្បកិរិយាបែបណាចំពោះខ្ញុំ

ហើយនិងសុផាន់ណាឯងនោះ ? សូម្បីតែលោកគ្រូក៏យល់ឃើញដូចជាពួកគេដែរ ខ្ញុំខ្មាសគេណាស់សូមសុផាន់ណាឯងកុំអន់ចិត្តនឹងខ្ញុំអី ខ្ញុំរាប់អានសុផាន់ណាឯង ក្នុងនាមជាមិត្តម្នាក់ដោយស្មោះតែប៉ុណ្ណោះ !

- តែខ្ញុំចង់ឲ្យការយល់ឃើញរបស់លោកគ្រូនិងពួកគេទាំងនេះវាក្លាយទៅជាការពិត តើម៉ូលីយ៉ាយល់ឃើញបែបណាដែរ ?

- គ្មានយល់យ៉ាងណាទេ តែខ្ញុំគ្រាន់ប្រាប់សុផាន់ណាឯងថាខ្ញុំរាប់អានអ្នកក្នុងនាមជាមិត្តតែប៉ុណ្ណោះ !

- ខ្ញុំក៏យល់ព្រមដែរ សូមឲ្យមិត្តភាពរបស់យើងនេះទៅជាមិត្តរួមជីវិតតែមួយ គឺមិត្ត១០០ ឆ្នាំ រវាងខ្ញុំនិងម៉ូលីយ៉ាឯងណា៎ !

- ហួសពេលទៅហើយ ព្រោះខ្ញុំជាមនុស្សដែលមានបេះដូងបានប្រគល់ជូនគេរួចទៅហើយ សូមផ្អាកគំនិតនេះវិញទៅ !

- ម៉ូលីយ៉ា ខ្ញុំជាកូនប្រុសតែម្នាក់គត់ រាល់បំណងរបស់ខ្ញុំទាំងអស់តែងតែបានសម្រេច ដូច្នេះសម្រេចចិត្តទៅ បើនាងយល់ព្រមខ្ញុំនឹងចូលដណ្តឹងនាងតាមច្បាប់ ខ្ញុំបានសម្រេចចិត្តហើយមិនបណ្តោយឲ្យបំណងរបស់ខ្ញុំខកខានបាននោះទេ នាងគិតឲ្យស្រួលបួលសិនទៅ ខ្ញុំលាសិនហើយ !

មួយប្រយោគចុងក្រោយនេះគួរសមដែរ ម៉ូលីយ៉ាភិតភ័យជាអនេកព្រោះសុផាន់ណាជាមនុស្សចិត្តឆេវឆាវ ធ្វើអ្វី១មិនសូវគិតវែង

ឆ្ងាយទេ គេជាកូនអ្នកមានទ្រព្យសម្បត្តិ នាយរៀនពូកែមែនតែស្រី មិនចូលចិត្តកំលោះម្នាក់នេះទាល់តែសោះ ។

មនុស្សដែលនាងមានចំណាប់អារម្មណ៍ជាងគេគឺបូរី នាងបន់ស្រន់រាល់រាត្រីឲ្យជួបគេ តែមនុស្សដែលធ្វើឲ្យនាងរួមចំណែកពេញចិត្តខ្លាំងដែរ ហើយនិងធ្វើឲ្យនាងពិបាកយល់នោះគឺសុជាតិ ។

កំពុងតែរវើរវាយ ម៉ូលីយ៉ាឥតបានឮសំឡេងរបស់វិសាលទេ គេឃើញអាកប្បកិរិយាស្រីធ្វើឲ្យអ្នកអស់សំណើចតែម្នាក់ឯង គិតទៅម៉ូលីយ៉ាពូកែបណ្ដែតអារម្មណ៍ណាស់ គេបញ្ឈប់រថយន្តនៅក្បែរនាងធ្វើឲ្យនាងភ្ញាក់ ហើយក្រោកឈរ ៖

- នាងចាំខ្ញុំយូរហើយមែនទេ ?

- ចាស យូរគ្រាន់ដែរ !

- ខ្ញុំជាប់រវល់បង្ហើយការងារបន្តិចទើបយូរ !

គេនិយាយព្រមទាំងបើកទ្វាររថយន្តឲ្យនាងចូល ចេញពីសាលាបន្តិច វិសាលសួរនាងថា :

- ម៉ូលីយ៉ា នាងមានដឹងថា សុជាតិវាមានគ្រោះថ្នាក់ដោយសាររឿងអីទេ ?

- ខ្ញុំមិនបានដឹងទេ !

- ម៉េចនាង មិនសាកសួរគេលមើល៍ !

- ចំណែកគាត់ក៏មិនដឹងថា គាត់មានរបួសដោយសាររឿងអី ដែរទេ ?

- ពិតមែនឬ ?

- ចាស តែមានអ្នកកាសែតមួយរូបកំពុងតាមដានរឿងនេះជាមួយភ្នាក់ងារស៊ើបអង្កេតពីររូបទៀត !

វិសាលក៏លែងសួរនាំពីរឿងអីទៀត ព្រោះរថយន្តបានមកដល់ផ្ទះទៅហើយ ។ ក្រោយពីផ្លាស់សម្លៀកបំពាក់រួចហើយ ម៉ូលីយ៉ារហ័សបរិភោគបាយរួចស្រេច ទើបរៀបចំខ្លួនទៅមន្ទីរពេទ្យ ។

វិសាលមិនបានជូនទៅទេ ព្រោះគេរវល់មកដល់មន្ទីរពេទ្យនៅក្នុងបន្ទប់ដែលសុជាតិសម្រាក បែរជាមានមនុស្សអ៊ូអរសន្ធឹកសន្ធាប់ នាងរន្ធត់ក្នុងចិត្តជាខ្លាំងនឹកថាតិចគេស្លាប់ទេដឹង ! ទន្ទឹមនឹងចម្ងល់នេះខ្លួននាងបានមកសណ្ឋិតក្នុងបន្ទប់ទាំងមូល គឺជាមនុស្សផ្សេងប្រហែលទើបនឹងធ្វើការវះកាត់ហើយថ្មីៗ ដែលនៅសន្លប់មិនទាន់ដឹងខ្លួនកំពុងបញ្ចូលអុកស៊ីសែននៅឡើយ ។

ម៉ូលីយ៉ារហ័សសួរទៅមីងម្នាក់ដែលមកកំដរអ្នកជំងឺនោះថា :

- សុំទោសអ្នកមីង អ្នកជំងឺដែលសម្រាកនៅទីនេះ តើត្រូវផ្លាស់ទៅណាហើយ ?

ស្រីនោះគ្រវីក្បាល :

- មីងមិនដឹងដែរក្មួយ !

អ្នកគ្រូពេទ្យម្នាក់បន្ថឹឡើង :

- ចាស សុជាតិគាត់អញ្ជើញទៅផ្ទះកាលពីព្រឹកមិញហើយ !

- តើមានអ្នកណាជូនទៅអ្នកគ្រូពេទ្យ !

- គឺម្តាយគាត់អញ្ជើញមក ហើយឡានក្រសួងជូនទៅតែម្តង !

- ចាស អរគុណអ្នកគ្រូពេទ្យហើយ !

ម៉ូលីយ៉ារហ័សត្រឡប់មកវិញ នាងនឹកដូចជាក្តុកក្តួលក្នុងចិត្តជាអនេក តើម្តាយរបស់គេនឹងយល់យ៉ាងណានៅពេលដែលដឹងថារូបនាងរស់នៅក្នុងផ្ទះមួយតែពីរនាក់ជាមួយនឹងកូនគាត់ ? ហើយដោយសារតែរូបនាងនេះហើយទើបគេត្រូវរបួស ។

បញ្ហាច្រើនជំពូក បានចោទឡើងក្នុងខួរក្បាលរបស់ស្រស់ស្រីបានចូលមកអុកឡុកក្នុងដួងចិត្តនាងមិនតិចទេ ទីបញ្ចប់នាងបានទាញសេចក្តីសម្រេចមួយថា :

- ត្រូវតែចូល បើមានបាតុភាពអ្វីកើតឡើងរវាងម្តាយសុជាតិនិងនាង គឺស្រីត្រូវតែចេញពីទីនេះ ។ មកដល់ផ្ទះនាងដើរលបៗស្ទើរមិនហ៊ានចូល ទ្វារចំហស្រាប់ តែផ្ទះស្ងាត់ឈឹងហាក់គ្មានមនុស្សសោះនាងអើតទៅបន្ទប់របស់សុជាតិឃើញគេគេងលក់ ម៉ូលីយ៉ាចេញទៅក្រោយនៅតែមិនឃើញម្តាយសុជាតិទៀត នាងដូចជាធូរស្រាល នៅ

ក្នុងខ្លួនបន្តិច ។

នៅពេលដែលនាងត្រឡប់មកកាន់បន្ទប់របស់សុជាតិវិញ គេបើកភ្នែកសម្លឹងមកនាង ស្រីប្រញាប់ដើរចូលទៅព្រមទាំងសួរថា :

- ហេតុអីក៏លោករហ័សចេញម្ល៉េះ ?

- ព្រោះជំងឺបានធូរស្រាលហើយ នាងទើបនឹងត្រឡប់មកពីមន្ទីរពេទ្យអម្បាញ់មិញមែនទេ ?

- ចុះអ្នកណាជាអ្នកជូនលោកត្រឡប់មកផ្ទះវិញ ?

- បាទ គឺឡានពេទ្យ !

គេឆ្លើយទាំងញ៉ឹម១ផង ម៉ូលីយ៉ាសញ្ជឹងគិតទើបបន្តទៀតថា:

- នារីពេទ្យម្នាក់បានប្រាប់ខ្ញុំថា គឺម្តាយលោកបានទៅយកលោកត្រឡប់មកវិញ !

- តើនាងជឿដែរទេ ?

- ខ្ញុំមិនទាន់ជឿទាំងស្រុងទេ ហើយក៏មិនមែនមិនជឿទាំងស្រុងដែរ !

- ម្តាយខ្ញុំមិនដឹងថាខ្ញុំមានគ្រោះថ្នាក់ទេកាលពីថ្ងៃដែលខ្ញុំទើបដឹងខ្លួនពីសន្លប់ភ្លាមនោះ ខ្ញុំបានឲ្យគេទូរស័ព្ទប្រាប់ម្តាយខ្ញុំថាឲ្យគាត់អញ្ជើញទៅផ្ទះម្តាយមីងខ្ញុំឯកំពង់ធំ ហើយមិនបាច់ត្រឡប់មកវិញទេ ព្រោះខ្ញុំបានដំណឹងថាមានមនុស្សប្រុងឃាឃីធ្វើបាបគាត់ទេ !

- ចុះមានអញ្ជើញទៅផ្ទះហើយឬនៅ ?

- ប្រហែលជាទៅហើយ និយាយអីចឹងខ្ញុំភ្លេចប្រាប់នាងត្រូវលាក់ពីមូលហេតុនៃគ្រោះថ្នាក់របស់ខ្ញុំកុំឲ្យគេដឹង ព្រោះខ្ញុំមិនទាន់ឲ្យគេតាមដានក្នុងរឿងនេះទេ !

- ខ្ញុំមិននិយាយឲ្យអ្នកណាដឹងទេ សូមលោកទុកចិត្តចុះ តែខ្ញុំចង់ថាពាក្យសម្ដីដែលនារីពេទ្យបានប្រាប់ខ្ញុំថា ម្ដាយលោកមកនាំយកលោកត្រឡប់ទៅវិញនោះមិនមែនជាការពិតទេឬ ?

- មិនពិតទេ នារីពេទ្យនោះប្រហែលសួជាហើយ ព្រោះកាលពីព្រឹក ខ្ញុំបានកុហកគេថាម្ដាយខ្ញុំមកយកខ្ញុំត្រឡប់ទៅផ្ទះវិញ ការពិតគឺម្ដាយវិសាលគាត់ទៅសួរសុខទុក្ខខ្ញុំទេ ចាំខ្ញុំទូរស័ព្ទទៅប្រាប់វិសាលឲ្យវាយកសម្លៀកបំពាក់នាងនិងសៀវភៅមកឲ្យនាងវិញ !

- លោកមិនបន្ដោងសេរ៉ូមទៀតទេឬ ?

- ឈប់ហើយ !

យប់នេះសុជាតិឃាត់ឲ្យម៉ូលីយ៉ាគេងនៅបន្ទប់គេ តែនាងបានយកប៉ៅអ៊ីបត់មកដាក់ជំនួសវិញ ! អ្នកប្រុសបាញ់ថ្នាំមូសកុំឲ្យវាចូលមកទន្ទ្រានទើបគេនាំគ្នាចូលសម្រាក ។ គេទាំងពីរមើលមុខគ្នារៀងៗខ្លួនក្រៅពីច្របាច់ទឹកក្រូច និងឆុងទឹកដោះគោឲ្យគេរួចហើយ ម៉ូលីយ៉ាចេញមករៀបបន្ទប់វិញ នាងមិនហ៊ានធ្វើអ្វីឲ្យរំខានដល់ដំណេកគេទេ

ស្រីដើរយ៉ាងស្រាលជើង តែសុជាតិមកទាន់គេមានគេងលក់ឯណាសួរទៅនាងថា :

- ម៉ូលីយ៉ា នាងនៅអីដល់យប់ជ្រៅម្ល៉េះ ប្រយ័ត្នឈឺណាំថ្នាក់ប្រឡងផងនាងមិនត្រូវបង្ខំខ្លាំងពេកទេ តែត្រឹមម៉ោង១១ ឬ១២ គេចូលគេងបាត់ហើយ !

- ខ្ញុំស្មានតែម៉ោងទើបតែ ១០ ទេ មើលទៅដូចជាមិនទាន់ងងុយសោះ !

- ខ្ញុំនឹងទិញនាឡិកាមកព្យួរនៅកណ្ដាលផ្ទះ ដើម្បីកុំឲ្យនាងរៀនជ្រុលម៉ោងទៀត ហើយនិងទិញនាឡិកាដៃមួយសម្រាប់ឲ្យនាងពាក់គ្រាន់មើលម៉ោងពេលប្រឡងនិងពេលធ្វើការ !

កញ្ញារាដៃបដិសេធ :

- មិនបាច់ទេលោក !

- នាងមិនត្រូវប្រកែកទេ ព្រោះបន្តិចទៀតនេះខ្ញុំមិនបានជូននាងទៅរៀនទេ នាងត្រូវទៅដោយខ្លួនឯងព្រោះវានាំឲ្យតែខាត រវល់តែឌុបនាងទៅរៀនរាល់ថ្ងៃយ៉ាងនេះ រកសង្សារ១បណ្ដើរមិនបានទេ ព្រោះគេរវល់តែច្រឡំ !

ម៉ូលីយ៉ាមិនមាត់តបទៅវិញទេ នាងនៅតែអន់ចិត្តខ្លះដែរសម្ដីគេដូចជាទើសទាល់នាងខ្លាំងណាស់ នាងមិនគួរមករស់នៅទីនេះសោះ

ពេលគេជានាងនឹងសុំទៅនៅសាលាហើយទម្រាំដល់ប្រឡងរួច ស្រីលួច មើលទៅសុជាតិម្ដងៗ ឃើញគេបែរខ្លួនទៅជញ្ជាំង នាងប្រះខ្លួនគេង លើប៉ោអ៊ីដែរ នឹកឃើញយ៉ាងណាកញ្ញាក្រោកទៅបិទភ្លើងស ហើយ បើកភ្លើងពណិបៃតងព្រិលៗ ឃើញដូច្នោះសុជាតិក៏ស្រែកឡើង

- ហេតុអីបើកភ្លើងនេះទៅវិញម៉ូលីយ៉ា ?

- កាលពីលើកមុនខ្ញុំតែងសង្កេតឃើញ នៅពេលគេងលោក តែងប្រើភ្លើងពណិនេះ !

- តែតាំងពីពេលដែលមានរបួសមក ខ្ញុំពុំដែលទម្លាប់គេងបិទ ភ្លើងទេ !

ស្រស់ស្រីលែងមាត់ នាងបើកភ្លើងសមួយរំពេច ចំណែកអ្នក កំលោះវិញគេងមិនលក់ទេ ព្រោះពេលថ្ងៃគេគេងវាស់ល្ងាចទៅហើយ ពេលដែលមាណវីត្រឡប់ខ្លួនបែរមករកគេទាំងមិនដឹងខ្លួន ដោយសារ តែប្រុសកំហូចនេះចង់បើកភ្លើង ដើម្បីគយគន់មើលសម្រស់របស់នាង នេះបើសិនណាជាគេគ្មានរបួសទេ ពិតជាមិនអាចទ្រាំនៅស្ងៀមបាន ឡើយ ទម្រាំអ្នកភ្ញាក់ខ្លួនពីការឆាបឆួលនៃតណ្ហានេះ គឺពិតជាមានន សេចក្ដីរំជើបរំជួលមែន ។

ឱ ! ឲ្យតែគេរស់របៀបនេះច្បាស់ជាជួបប្រទះការសោកស្ដាយ ក្រោយជាមិនខាន អ្នកយកដៃញីក្បាលហើយធ្វើចិញ្ចើមស្មើរដល់គ្នា

ហើយប្រែខ្លួនទៅម្ខាងសម្ងំស្ងៀម ។

ការប្រឡងយកសញ្ញាបត្របាក់ឌុប ក៏ខិតចូលមកជិតណាស់ទៅហើយ សុជាតិក៏បានជាសះស្បើយដែរ តែអ្នកមិនទាន់ចូលធ្វើការភ្លាមទេ ច្បាប់សម្រាករបស់គេនៅបន្តបាន១អាទិត្យទៀត ។ ចំណែកសកម្មភាពតាមដានក្នុងរឿងគ្រោះថ្នាក់របស់គេក៏ស្ងាត់ស្ងៀម ព្រោះសមត្ថកិច្ចគ្មានលទ្ធភាពនឹងធ្វើការស្រាវជ្រាវរឿងនេះបានទេ ។ រីឯម្តាយរបស់សុជាតិវិញ តែងផ្ញើសំបុត្រពីកំពង់ធំមកសួរអ្នកជារឿយៗ តែអ្នកបានតបទៅគាត់វិញថាមិនឲ្យគាត់មកភ្នំពេញទេ អ្នកនឹងទៅយកគាត់ពេលដែលបានជាស្រួលបួល ។

លិខិតចុងក្រោយរបស់ម្តាយគេបានបញ្ជាក់ថា លោកវិបុលនិងកូនស្រីមានគ្រោះថ្នាក់ក្នុងការធ្វើដំណើរតាមផ្លូវពីភ្នំពេញទៅកាន់ខេត្តសៀមរាបហើយបានត្រូវកាត់ដៃមួយចំហៀង ! គាត់សួរមកអ្នកថាតើគាត់ត្រូវត្រឡប់ទៅសៀមរាបវិញ ដើម្បីសួរសុខទុក្ខលោកវិបុលដែរឬយ៉ាងណា ? សុជាតិបានហាមផ្តាច់មិនឲ្យម្តាយអ្នកទាក់ទងទេ ព្រោះលោកវិបុលមានទំនាក់ទំនងជាមួយនឹងគ្រោះថ្នាក់របស់អ្នកដែរ ។

នៅពេលដែលអ្នកកំលោះអង្គុយនៅលើបង់មុខផ្ទះមានអ្នករត់សំបុត្រម្នាក់ដើរចូលមករកប្រគល់សំបុត្រឲ្យអ្នក រួចក៏ត្រឡប់ទៅវិញ លិខិតមានកាខ្ទងពី បូរី ភូមិស្លក្រោម ស្រុកសៀមរាប ខេត្តសៀមរាប

បុរសរាងភ្ញាក់ក្រញាងដូចធ្លាក់ពីលើមេឃ អ្នកដែលទទួលគឺរូបគេតែម្តងជាមួយនឹងម៉ូលីយ៉ា ! អ្នកប្រុសប្រញាប់ហែកសំបុត្រអានភ្លាម :

......................

*សុជាតិ ខ្ញុំបានទទួលដំណឹងថាឯងនិងម៉ូលីយ៉ាបានក្លាយទៅជាប្តីប្រពន្ធនឹងគ្នា ព័ត៌មាននេះត្រូវបាននសាលាសង្កាត់ផ្តល់មកឲ្យខ្ញុំយ៉ាងច្បាស់ណាស់ ព្រោះមានហត្ថលេខាក្នុងកិច្ចសន្យារបស់ឯងស្រាប់ ។*

*តើឯងស្គាល់ខ្ញុំដែរឬទេ កាលពីនៅរៀនខ្ញុំឈ្មោះរតនា ខ្ញុំដឹងថាឯងរៀនក្រោមខ្ញុំ២ថ្នាក់ បច្ចុប្បន្នឯងជាវេជ្ជបណ្ឌិត១រូប ខ្ញុំសូមអញ្ជើញឯងជាមួយនឹងភរិយាចូលរួមក្នុងពិធីមង្គលការរបស់ខ្ញុំ ។*

..................................

អានចប់សុជាតិពិនិត្យនៅលើស្រោមសំបុត្រ ឃើញសំបុត្រអាពាហ៍ពិពាហ៍ កូនប្រុសនាម សេដ្ឋ រតនា កូនស្រីនាម យូរ៉ាវី ។

ខ្លួនអ្នកប្រុសញ៉ូរចំប្រប់ចំពោះវត្តមាននេះ គេគិតថាបើសិនជាម៉ូលីយ៉ាយល់ពីដំណឹងនេះតើនាងពិបាកចិត្តយ៉ាងណាទៅ? គេគួរតែលាក់រឿងនេះឲ្យជិត ដោយសារតែអ្នកលួចចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនឹងនាងទើបបូរីនិងនាងមិនបានជួបគ្នា គិតទៅគេពិតជាសាងបាបកម្មមែន អ្នកប្រុសសញ្ជឹងគិតបន្តិចគេពោលតែម្នាក់ឯងថា !

- ម៉ូលីយ៉ា ខ្ញុំជាអ្នកបំផ្លាញសុភមង្គលរបស់នាង ខ្ញុំមិនអាច

បណ្ដោយឲ្យជីវិតនាងក្លាយជាឥតន័យបានទេ !

រថយន្តវិសាលបានមកដល់ផ្ទះសុជាតិយ៉ាងរហ័ស អ្នកដាក់សំបុត្រចូលក្នុងហោប៉ៅ គេក្រោកឈរទទួលមិត្តដោយរីករាយ !

- បាយនៅផ្ទះគ្នានេះហើយវិសាល !

- ចាំថ្ងៃក្រោយចុះ គ្នាលាសិនហើយសម្លាញ់ ព្រោះមានការបន្តិចផង !

វិសាលចេញផុត ម៉ូលីយ៉ាដើរចូលមកមានទឹកមុខស្រពោនចម្លែកគួរឲ្យសង្ស័យ សុជាតិគិតថាតើនាងដឹងរឿងនេះទេដឹង ? ស្រស់ស្រីដើរចូលទៅក្នុងផ្ទះបាយ បុរសក៏ដើរតាមពីក្រោយនាងទាំងស្រដីទៅរកស្រីថា :

- ម៉ូលីយ៉ា...ម្ហូបបាយខ្ញុំដាំឆ្អិនហើយនាងឃ្លានយើងញ៉ាំឥឡូវនេះតែម្ដងទៅ !

- លោកឃ្លានហើយមែនទេ ?

- នៅទេ !

- បើអ៊ីចឹងខ្ញុំមានការបន្តិចចង់និយាយជាមួយនឹងលោក !

- នាងមានការអីចង់និយាយ ថ្ងៃនេះនាងដូចជាប្លែកណាស់ !

អ្នកប្រុសដាក់ខ្លួនអង្គុយលើកៅអីតុបាយ ចាំដំណឹងរបស់ស្រស់ស្រីដែលប្រុងនិយាយមកកាន់អ្នក ។ តែម៉ូលីយ៉ា បែរជាដើរចូលទៅ

ខាងក្នុងហើយត្រឡប់មកវិញ មានកាន់កាសែត១ច្បាប់ហុចមកឲ្យអ្នកប្រុសយើង ចង្អុលត្រង់កន្លែងពិសេសឲ្យគេអាន នរៈអានចប់កាន់តែស្រឡាំងកាំង រកមើលថ្ងៃខែកាសែតនេះចេញផ្សាយកន្លង១ខែមកហើយ គឺរយៈពេលដែលអ្នកទទួលគ្រោះថ្នាក់ ។ បុរសងើបមុខសម្លឹងចំភ័ក្ត្រស្រីដែលស្រពោនខុសធម្មតាហើយចង្អុលថា :

- កាសែតនេះនាងទិញឬ ?

- ចាស គឺមិត្តភក្តិរបស់ខ្ញុំយកមកឲ្យ ពេលដែលមើលឃើញឈ្មោះរបស់ខ្ញុំនិងភិនភាគដែលគេបានសរសេរនៅក្នុងនោះ !

- ចុះនាងគិតយ៉ាងម៉េចហ្នឹង ?

- គិតសុំលោកទៅបង្ហាញខ្លួននៅកន្លែងដែលគេចុះកាសែត !

- ខ្ញុំមិនលាក់ទេ តែចង់ធ្វើសំណូមពរដល់នាងមួយគឺចាំពេលប្រឡងហើយ ខ្ញុំនឹងនាំនាងទៅទីនោះ ថ្ងៃប្រឡងរបស់នាងនៅតែជាង១ខែទៀតទេ ! រយៈពេលនេះនាងមិនទាន់ហួសពេលកំណត់ឯណា ខ្ញុំធានាជូននាងទៅជួបបូរីផ្ទាល់ ហើយជួយសម្រួលរឿងនេះវិញ លៃយ៉ាងណាឲ្យនាងនិងបូរីជួបគ្នាទាល់តែបាន ចុះមិត្តរបស់នាងមិនឆ្ងល់ទេឬ ?

- ចាស គេឆ្ងល់គ្រប់ៗគ្នាខ្ញុំគិតថាមិនចូលរៀនវិញទេ !

- ហេតុអីទៅ ?

- ខ្ញុំខ្មាសគេ !

- តែបើនាងមិនប្រឡង នាងនឹងស្ដាយយ៉ាងច្រើនទៅថ្ងៃក្រោយ ឥឡូវនាងមិនបាច់ទៅរៀនឯសាលាទេ រៀននៅផ្ទះបានហើយ ខ្ញុំអាចជួយពន្យល់នាងទៀត ចាំពេលប្រឡងនាងទៅប្រឡងតែម្ដងទៅ មិនថាអីចឹងឬ ? ឯពាក្យសុំនិងសំណុំលិខិតរបស់នាងចាំខ្ញុំយកទៅដាក់ឲ្យ នាងឈប់គិតទៀតទៅ បងបូរីពិតជាបានជួបជុំគ្នា ហើយពេលនោះខ្ញុំនឹងទៅលុបសំបុត្រអាពាហ៍ពិពាហ៍ចេញ !

គេនិយាយទាំងញញឹមហាក់សប្បាយចិត្តណាស់ !

- មកញ៉ាំបាយទៅកុំយូរពេកក្រែងលោខ្យល់ចាប់ !

ម៉ូលីយ៉ាចូលមកញ៉ាំបាយជាមួយគេ អ្នកប្រុសលួចសម្លឹងមុខនាងដែលនៅតែស្រពោនមិនទាន់អស់បារម្ភនៅឡើយ ។

- នាងនៅតែគិតថាខ្លាចមិនបានរួបបងបូរីទៀតមែនទេ ?

- ចាស ទោះបីជាជួបទៀតក៏ពិបាកដែរ ព្រោះរឿងនេះវាមានការទាក់ទងដល់ម្ដាយចុងរបស់ខ្ញុំ ពេលនោះតើខ្ញុំត្រូវប្រាប់ពីមូលហេតុដែលខ្លួនខ្ញុំត្រូវឃ្លាតពីផ្ទះនោះរបៀបម៉េចទៅ !

- អឺ...បើពិបាកនាងមិនបាច់ត្រឡប់ទៅវិញទេនៅទីនេះរហូតទៅក៏បានដែរ ឬមួយនាងមិនដាច់ចិត្តពីបងបូរី ខ្ញុំដូចជាឆ្ងល់ណាស់ មើលទៅនាងហាក់ដូចជាពេញចិត្តចំពោះគាត់ណាស់ !

- វាជាស្នេហាដំបូងដែលខ្ញុំបានជួបជាលើកដំបូងនៅក្នុងចិត្តរបស់ខ្ញុំ គាត់ជាមនុស្សគួរឲ្យគោរពណាស់ !

- ចុះមនុស្សខ្ញុំមិនគួរឲ្យគោរពទេឬ ?

ស្រស់ស្រីទម្លាក់ស្លាបព្រាចុះងើបសម្លឹងចំមុខសុជាតិ :

- មនុស្សដូចលោកមិនត្រឹមតែគោរពទេ គួរឲ្យសរសើរទៀតលោកជាមនុស្សមានចិត្តរឹងប៉ឹង មិនធ្វើអ្វីផ្ដេសផ្ដាសនោះទេ !

- នាងជឿថារឹងប៉ឹងហើយឬ ?

- ចាស ! ជិត១ឆ្នាំដែលខ្ញុំរស់នៅទីនេះ ខ្ញុំតែងសង្កេតឃើញពីទឹកចិត្តរបស់លោកពិតជាអ៊ីចឹងមែន ខ្ញុំមិនមែននិយាយសរសើរនៅចំ-ពោះមុខលោកទេ តែនេះដោយសារខ្ញុំត្រូវឃ្លាតពីទីនេះទើបខ្ញុំនិយាយដោយមិនចង់ឃ្លាតសោះ !

- នាងសម្រេចចិត្តថាទៅពិតប្រាកដមែនហើយឬ ?

- ចាស បើលោកអនុញ្ញាតខ្ញុំសម្រេចថាត្រូវតែទៅ !

- អ៊ីចឹងបញ្ហាដែលធ្វើឲ្យនាងមិនសប្បាយចិត្តនោះ តើត្រូវដោះស្រាយយ៉ាងណា ?

- រឿងនេះខ្ញុំត្រូវតែនិយាយការពិតប្រាប់បងបូរីហើយឲ្យគាត់ជួយដោះស្រាយឲ្យខ្ញុំដោយមិនឲ្យប៉ះពាល់ដល់ម្ដាយចុងខ្ញុំដែរ !

គេទាំងពីរក៏ឈប់សន្ទនា ហើយរៀបចំបរិភោគតែរៀងៗខ្លួន ។

ពេលព្រលប់ក៏មកដល់ សុជាតិបបួលម៉ូលីយ៉ាទៅអង្គុយលេងលើវាល ស្មៅវិមានឯករាជ្យ ទាល់តែម៉ោងជិត ៩ ទើបត្រឡប់មកផ្ទះវិញ ។

ក្រោយពីផ្លាស់សម្លៀកបំពាក់រួចហើយ សុជាតិចាក់ម៉ាញ៉េ ឡើងទ្រហឹងរកតែម៉ូលីយ៉ារៀនសូត្រមិនកើត នាងធ្វើមុខក្រញូវហើយ ទាញសម្លៀកបំពាក់រាត្រីមកពាក់ប្រះគេងទាំងមួម៉ៅតែម្នាក់ឯង ។

- ចង់ឲ្យគេប្រឡង តែចាក់ម៉ាញេឲ្យទ្រហឹង រកតែរៀនសូត្រ មិនកើត បែរជាសរសើរបន្តិចមានគំនិតផ្ដេសផ្ដាសតែម្ដង !

នាងទើបតែធ្មេចបានបន្តិចស្នូរគោះទ្វារក៏លាន់ឡើង !

- ម៉ូលីយ៉ាបើកទ្វារ ខ្ញុំមានការចង់និយាយជាមួយនាង !

ស្រស់ស្រីទាញកន្សែងពោះគោមកដណ្ដប់ព្រោះអាវនាងស្ដើង ពេក ស្រីបើកទ្វារឲ្យគេចូល តែគេបក់ដៃឲ្យនាងចេញទៅក្រៅវិញ !

- ពេលនាងប្រឡងជាប់ខ្ញុំបើកពិធីបង់គេមួយ ដើម្បីអបអរ សាទរនាង ពេលនោះនាងត្រូវតែឡើងរាំព្រោះនាងមាននាទីជាម្ចាស់ ពិធីនេះ !

- តែខ្ញុំមិនចេះរាំទេ ហើយការប្រឡងនេះខ្ញុំមិនសង្ឃឹមទាំង ស្រុងថាប្រឡងជាប់ដែរ !

- ខ្ញុំជឿថានាងប្រឡងមិនធ្លាក់ទេ ហើយខ្ញុំនឹងបង្ហាត់នាងរាំ ក្នុងពេលឥឡូវនេះ !

អ្នកប្រុសទាញដៃនាង ស្រីប្រញាប់ឆ្លើយទាំងគ្រវីក្បាល :

- ទេ !

- នាងនឹងឃ្លាតទៅរហូត គួរណាស់តែបំពេញបំណងខ្ញុំមុនទៅ ខ្ញុំយល់ថាមិនរំខានដល់ការសិក្សារបស់នាងទេ !

ម៉ូលីយ៉ាសម្លឹងមុខអ្នកប្រុស តែសុជាតិបន្ថែម :

- នាងត្រូវតែរាំ វាជាកិត្តិយសរបស់នាង នៅពេលដែលមានពិធីអ្វីម្តងម្កាលនោះ !

ចប់សម្តីគេទាញដៃស្រី តែនាងមិនប្រកែកទៀតដែរដើរតាមពីក្រោយចូលទៅក្នុងបន្ទប់ នរះបើកចង្វាក់ស្លូវដែលគេត្រូវបង្ហាត់នាងមួយបទនេះ ម៉ូលីយ៉ាមិនដឹងថាចង្វាក់នេះគេត្រូវរាំបែបណាទេ នាងខំតែនៅស្ងៀមចាំមើលការបង្ហាត់របស់អ្នកប្រុស គេដើរមកទល់មុខនាងហើយនិយាយថា :

- នាងដាក់ដៃទាំងពីរលើស្មាខ្ញុំមក !

ស្រីនៅច្រិមច្រុមហាក់មិនដាច់ចិត្ត បុរសក៏បន្ថែម :

- បទនេះត្រូវរាំអ៊ីចឹងណាំ កុំបារម្ភពេកវាមិនសមរម្យឬ ?

វាចាចប់គេលើកដៃសទាំងពីរឲ្យដាក់លើស្មាអ្នក ហើយដៃគេទាំងពីរឱបចង្កេះនាងម្តង ស្រស់ស្រីព្រឺព្រួចក្នុងចិត្តចម្លែក ចំណែកទ្រូងនាងញ័រស្ទើរតែខ្ទាតបេះដូងចេញមកក្រៅទៅហើយ ។ ចំណែក

នរៈវិញក៏ដូច្នោះដែរ ចិត្តគេជ្រួលច្របល់លើសពីនាងទៅទៀត បេះដូងរបស់គេស្ទើរតែទប់មិនជាប់ គេឱបនាងមិនឲ្យរបេះទេបង្អួសទៅតាមបទភ្លេងយប់ ១២ កើត ។

ម៉ូលីយ៉ានាងមិនចេះរាំទេ តែដល់រាំទៅពិតជាសមគ្នាខ្លោះសុជាតិញញឹមមិនដាច់ គេនិយាយតិចៗក្បែរត្រចៀកស្រីថា :

- ម៉ូលីយ៉ា នេះមិនមែនអបអរសាទរថ្ងៃសញ្ញាបត្រអូនទេ គឺសម្រាប់ថ្ងៃនៃ....អឺ...រៀបអាពាហ៍ពិពាហ៍របស់យើង អូនកុំចង់រត់ចោលបងឲ្យសោះ បងមិនឲ្យអូនទៅណាទេ !

- ម៉េចអីចឹង !

នាងបម្រះចេញតែអ្នកប្រុសចាប់ជាប់ !

- ចងរើទៅណា ទៅមិនរួចទេ បន្ទប់នេះបងដាក់គន្លឹះជាប់អស់ហើយ បងក៏មិនធ្វើផ្តេសផ្តាស បងសុខចិត្តចាំជានិច្ចរហូតដល់ថ្ងៃដែលយើងរៀបការពេញមុខ !

គេឈរស្ងៀមឈប់រាំតទៅទៀត តែនៅពុំព្រមលែងនាងទេ !

ម៉ូលីយ៉ាសម្លឹងមុខគេយ៉ាងមុត នាងពោលដោយសម្តីដាច់ៗធ្ងន់ៗថា :

- លោកនិយាយត្រឡប់ត្រឡិនម្ល៉េះ ឬ មួយក៏លោកយល់សប្តិទេដឹង ?

- គឺជាការពិតណាស់អូន បងគឺសុជាតិ ចំណែកអូនគឺម៉ូលីយ៉ា មិនច្រឡំទេ !

- តែពីព្រឹកមិញលោកមានប្រសាសន៍ថា ជូនខ្ញុំទៅរកបងបូរី ដឹងអីលោកបែរជាឲ្យខ្ញុំមករៀបការជាមួយនឹងលោកទៅវិញ ! ខ្ញុំខំតែសរសើរចិត្តលោកយ៉ាងពេញមាត់នៅចំពោះមុខលោក ដូច្នេះលោកមិនត្រូវធ្វើឲ្យការសរសើរនេះ ក្លាយទៅជាការវាយតម្លៃពីចរិតរបស់លោកយ៉ាងថោកទាបនោះទេ !

- តែអូននិយាយថានឹងបំពេញបំណងរបស់បងបានគ្រប់ពេលវេលាទាំងអស់ ឥឡូវបងមិនឲ្យអូនទៅណាទេ ហើយយើងនឹងរៀបការជាមួយគ្នានៅពេលដែលអូនប្រឡងហើយនោះ ថាជាប់ក៏ដោយធ្លាក់ក៏ដោយ បងនឹងអាចចិញ្ចឹមអូនបានរស់ដោយស្រួល គឺមិនបាច់ចេញធ្វើការទេ !

- ខ្ញុំអាចបំពេញបំណងរបស់លោកបានមែន តែលោកត្រូវដឹងថាពេលដែលខ្ញុំរៀបការជាមួយលោក គឺពេលនោះហើយខ្ញុំកំពុងក្បត់នឹងបងបូរី ព្រោះគាត់មិនទាន់លះបង់ខ្ញុំនៅឡើយ គាត់នៅតែតាមរកខ្ញុំជានិច្ច ហើយថែមទាំងចុះកាសែតទៀតផង ! ខ្ញុំក្បត់គាត់ដើម្បីតបស្នងសងគុណលោកនៅពេលដែលខ្ញុំជំពាក់គុណលោក ខ្ញុំពិតជាហ៊ានលះបង់រូបកាយដើម្បីសងគុណគេនោះ លោកត្រូវតែគិតទៅ ខ្ញុំសុំ

ចៀសវាងក្នុងរឿងមួយនេះបានដែរទេ ?

សុជាតិហើបមាត់មិនរួចនូវសម្ដីស្រីដែលបកមកឲ្យ តែអ្នកចង់យកសំបុត្របូរីមកបង្ហាញនាងទៀត តើគេស្វែងរកនាងដើម្បីអ្វីទៀតទៅ បើគេរៀបការនៅថ្ងៃខានស្អែកនេះទៅហើយនោះ តាមអ្នកស្មានកាសែតនោះបានបោះផ្សាយមុនការផ្ដើមអាពាហ៍ពិពាហ៍នេះ ឯចំណែកដំណឹងដែលបានមកពីសាលាសង្កាត់ ក៏ដោយសារតែកាសែតនេះដែរ សុជាតិខាំមាត់សង្កត់ចិត្ត សុខចិត្តឲ្យនាងជៀលគេចុះពេលក្រោយនាងគង់តែដឹងទេ ព្រោះអ្នកមិនឲ្យនាងដឹងការពិតបានទេ នាងនឹងឈឺចាប់យ៉ាងខ្លាំង នៅពេលដែលដឹងថាបូរីត្រូវរៀបការជាមួយនឹងនារីផ្សេង បុរសសម្លឹងមុខនាងដោយក្ដីអាណិត !

- យើងនឹងបន្តការរាំតទៅទៀត !

- ខ្ញុំមិនរាំទេ !

- ចុះឯណាសន្យាបំពេញបំណងឲ្យខ្ញុំនោះ លើកលែងតែរឿងរៀបការ ?

ម៉ូលីយ៉ាសែនក្ដាញ់នឹងសម្ដីគេណាស់ " អាគាត់នេះចង់កេងចំណេញច្រើនណាស់ ស្អែករត់ចោលហើយ " ស្រីចូលរាំជាមួយគេទាំងមុខក្រញូវ ។ បទចម្រៀងបានបញ្ចប់ទៅចូលមកដល់បទថ្មីម៉ូលីយ៉ាធូរទ្រូងបន្តិចព្រោះសុជាតិព្រមព្រលែងនាងចេញ ហើយរាំឲ្យនាងធ្វើតាម

ចង្វាក់បូឡេរ៉ូ គេធ្វើមុខស្រស់ញញឹមនឹងឃើញសកម្មភាពដ៏ទន់ភ្លន់របស់នាង មួយបទនេះបានកន្លងផុតទៅចូលដល់បទអណ្តែតអណ្តូងទៀតហើយ នាងតឹងទ្រូងស្ទើរប្រេះ ។ សុជាតិ លែងបើកភ្លើងសទៀតហើយ គេបើកភ្លើងក្រហមព្រិល១ដើម្បីឲ្យសមនឹងបទ បាត់អូនម៉ូលីយ៉ាចេះតែមិនចង់រាំ !

- ចង្វាក់ស្អីគេទៀតហើយស្អិតមើលតែតុកកែនោះ !

សុជាតិមិនតបនៅតែបន្តការរាំធ្វើមិនដឹង មិនពើនឹងសម្តីស្រីទ្រាំមិនបាននាងខាំស្មាគេយ៉ាងខ្លាំង សុជាតិក៏មិនស្រែកដែរ គេឱនថើបនាងមួយខ្សឹតយ៉ាងវែង ម៉ូលីយ៉ាខឹងណាស់លើកដៃទះគេអស់មួយទំហឹង សុជាតិទប់ដៃនាងទាំងពីរជាប់ ម៉ូលីយ៉ាភ័យណាស់ ខ្លួននាងញ័រដូចកូនសត្វ ដៃនាងត្រជាក់ដូចទឹកកក បុរសទាញស្រីឲ្យផ្អែកនឹងជញ្ជាំងទប់ស្មាទាំងពីរជាប់ គេសម្លឹងទឹកភ្នែកនាងដែលហូរធ្លាក់មកដោយក្តីឈឺចាប់ អ្នកធ្លាប់ឃើញទឹកភ្នែកនេះពាដងហើយ គឺជាទឹកភ្នែកដែលគួរឲ្យអាណិត អ្នកឱនស្រូបផ្លិតទឹកភ្នែកនេះឲ្យជ្រះ កញ្ញារើបម្រះយ៉ាងខ្លាំង សុជាតិមិនបណ្តោយទេគេគ្រញ្ជិចនាងជាប់ ។

- កាលមុនលោកជៀលថាខ្ញុំមានគំនិតថោកទាបសមតែលោកថ្លៃថ្នូរ មិនសមថោកទាបដែរសោះ !

- ម៉េចក៏ថាថោកទាប ! បើបងមានគំនិតបំផ្លាញអនាគតអូន

មិនបាច់ចាំមកដល់ពេលនេះទេ ម្ល៉េះអូននឹងត្រូវស្គាល់ទឹកភ្នែកតាំងពីនៅក្នុងបារនោះម្ល៉េះ !

- តែលោកធ្វើនេះដើម្បីឲ្យខ្ញុំជឿស្អុង រួចក៏តាំងបំផ្លាញអត្តចរិតរបស់លោកនៅពេលនេះ !

- ឥឡូវបងសុខចិត្តទទួលថាថោកទាបនៅពេលនេះចុះ តែកាលពីមុនបងក៏បានវាយតម្លៃអូនថាមានគំនិតថោកទាបដែរ ដូច្នេះអូនមិនត្រូវរកអនាគតជាមួយនឹងអ្នកថ្លៃថ្នូរដូចបងបូរីទេ ! ត្រូវតែយកបងដែលជាអ្នកថោកទាបដូចគ្នាទើបសម !

- ឥឡូវលោកចង់យ៉ាងម៉េចហ្នឹង ?

- បងរាំជាមួយអូន តែអូនរករឿងបង រកតែរាំមិនកើតទាល់តែគ្រញិចអីចឹង ឥឡូវបើចង់រួចខ្លួនជូតទឹកភ្នែកឲ្យស្អាតហើយរាំទៀតបទនេះបងស្រឡាញ់ជាងគេ អូនត្រូវតែរាំឲ្យចប់មួយបទនេះ បងឲ្យចូលគេងហើយ !

មិនអាចប្រកែកបានម៉ូលីយ៉ាក៏រាំបន្តទៀតទាំងមុខក្រញូវជាងពីមុនទៅទៀត តែសុជាតិមិនបានមើលនាងទេ យូរណាស់បទនេះនៅតែមិនចប់ ហើយចេះតែសាឡើងវិញ ម៉ូលីយ៉ាក៏សួរទាំងមិនពេញចិត្ត :

- កាលណាទើបចប់ លោកឯងនេះប៉ិនយកចំណេញពីខ្ញុំណាស់មិនដឹងជាខាកាស្សែតអីចឹងសោះ !

- គ្មាននរណាគេរកស៊ីខាតដើមនោះទេ ម៉ូលីយ៉ា អូនដឹងទេ ដើម្បីតែអូនបងចំណាយអស់ប្រាក់ប៉ុន្មានហើយថែមទាំងជិតស្លាប់ទាំងខ្លួនថែមទៀតផង អូនគិតទៅមើល តើមានអ្នកណាស៊ូប្ដូរដូចបងទេ ! ឥឡូវអូនជិតឃ្លាតពីបងហើយ មិនឲ្យបងស្រង់ដើមខ្លះម្ដេចបានកុំខឹងអីទាំងនេះដើម្បីទុកជាងនុស្សាវរីយ៍គ្រាក្រោយបង្ហស់ដែរ ! ហើយបងនឹងចងចាំជាងគេមួយកំផ្លៀងទុកជាអនុស្សាវរីយ៍របស់អូនចំពោះបង !

គេនិយាយព្រមទាំងឱនមើលមុខនាង !

- ញញឹមបន្ដិចទៅកុំក្រញូវអីចឹងពេក អពមង្គលផ្ទះបងអស់ហើយអូន !

អស់ពីគិត ម៉ូលីយ៉ាចង់អស់សំណើចនឹងសម្ដីមិនដឹងខ្យល់របស់គេ តែគំនិតគាត់នេះគឺចង់តែបំផ្លាញនាងទាំងស្រុង គិតចុះគិតឡើងនាងដូចជាមូហ្មងរាំសឹងមិនចង់កើត ។ ឃើញស្រីដូចជាបណ្ដែតចិត្តជិតអារម្មណ៍បន្ដិច សុជាតិនីកអរមិនតិចទេ អ្នកដឹងច្បាស់ថាម៉ូលីយ៉ាក៏មិនទៅរឹងប៉ឹងជាមួយអ្នកដែរ ណាមួយនាងនៅស្ងៀមឲ្យអ្នកឱបបន្ដទៅទៀត ក្នុងចិត្តយ៉ាងនេះអ្នកមិនហ៊ានធ្វើបាបនាងទេ អ្នកត្រូវតែសាងសុភមង្គលជូននាងធ្វើយ៉ាងនេះដើម្បីឲ្យនាងបាក់ចិត្តមកលើគេខ្លះហើយខិតខំបំភ្លេចបូរី ។

បទភ្លេងបានចប់ទៅហើយ តែទម្រាំចប់សាចុះសាឡើង អ្នក

ទាញសោមកចាក់ទ្វាររួចប្រាប់ថា :

- យប់នេះអូនគេងនៅទីនេះហើយ អូនត្រូវគេងនៅលើពូក ជាមួយបង ទោះជាអូនមិនព្រមក៏បងបង្ខំឲ្យអូនគេងដែរ !

- ឆាប់បើកសោទៅ ខ្ញុំនឹងចេញពីទីនេះទាំងយប់ភ្លាម !

- ទៅនៅក្នុងបារជាមួយនឹងអ្នកស្រីគន្ធាវិញមែនទេ ?

- ទៅណាស្រេចតែខ្ញុំ លោកលែងមានសិទ្ធិអ្វីទៀតហើយ ព្រោះខ្ញុំលែងគោរពលោក ដោយសារតែលោកគ្មានចរិតណាមួយ គួរឲ្យខ្ញុំនឹងគោរពទៀតសោះ !

- សម្ដីអូនឥឡូវថ្លោសៗណាស់ បើមិនទៅណាទេឡើងទៅគេងភ្លាមទៅ កុំភ័យថាបងធ្វើអីផ្ដេសផ្ដាសនោះ បងចង់គេងជិតអូនម្ដងប៉ុណ្ណោះ យ៉ាងម៉េចបានជាលែងនិយាយស្ដីហើយ បងសូមរំលឹកអូនបន្តិច កាលពីដំបូងបងប្រាប់អូនហើយតើ មិនឲ្យអូនទុកចិត្តបងពេកទេ តែចិត្តបងទប់មិនបានដូចពេលនេះអីចឹង ឥឡូវនេះវាហួសពេលហើយ ទោះជាអូនមិនចង់គេងជាមួយបង ក៏បងមិនបណ្ដោយដែរ ។

ស្រស់ស្រីនាងគិតថា ពេលនេះទោះជានាងគេចទៅណាក៏មិនរួចដែរ នាងគិតថាបើសិនណាជាគេធ្វើផ្ដេសផ្ដាស នាងនឹងធ្វើអត្តឃាតខ្លួនឯងភ្លាម ! កញ្ញាសម្លក់គេបន្តិចទើបដើរទៅគេងលើគ្រែ ខ្លួននាង

ឡើងបែកញើសជោក សុជាតិបើកទ្វារចេញទៅក្រៅមួយស្របក់ គេកាន់សម្លៀកបំពាក់១កុំប្លេមកឲ្យនាង ។

- ផ្លាស់ខោអាវនេះទៅ !

- បានហើយ មិនបាច់ទេ !

- គេងជិតបងត្រូវមានអនាម័យបន្តិច !

- តើឲ្យខ្ញុំផ្លាស់កន្លែងណាទៅ ?

- ចុះបន្ទប់នេះមិនអាចឲ្យអូនផ្លាស់បានទេឬ ? មិនបាច់អៀនខ្មាសនឹងបងទេ បងមិនខ្ចីមើលដែរស្មានតែអាវស្តើងរបស់អូននោះ វាអាចបិទបាំងខ្លួនបានប៉ុន្មាន បើពិបាកណាស់បងចេញពីទីនេះក៏បានដែរ

ថាហើយគេដើរចេញទៅក្រៅមួយស្របក់ ទើបត្រឡប់ចូលមកវិញ ។ ម៉ូលីយ៉ាសម្ងំលក់ចាំស្តាប់សភាពចម្លកតរបស់គេ សុជាតិបើកកង្ហារឲ្យវិលហើយឡើងទៅគេងដែរ រដូវនេះជារដូវក្តៅតែម៉ូលីយ៉ាដណ្តប់ភួយត្រឹមក អ្នកកំលោះឃើញបែបនេះចង់តែសើច អ្នកថានាងមិនទាន់គេងលក់ទេ តែធ្វើពុតជាលក់ គិតទៅម៉ូលីយ៉ាគ្រាន់បើអាចទប់ចិត្តភ្លើតភ្លើនរបស់អ្នកបាន តែពេលនេះនាងសម្ងំឈឹងបែរមុខមករកគេ បុរសអាចមើលមុខនាងបានតាមចិត្ត នាងស្អាតណាស់បើយ៉ាងនេះទាល់តែតួអង្គព្រះសម្មាសម្ពុទ្ធទើបអាចទ្រាំស្ងៀមបាន តែនេះសុជាតិជាមនុស្សមានសាច់មានឈាម គេពិតជាមិនអាចទ្រាំបានទេ តែ

មនុស្សមានឆន្ទៈ គេត្រូវសម្រេចបំណងរបស់គេទៅតាមឧត្តមគតិរបស់គេ ។

មិនអាចទ្រាំគេងជាមួយនឹងនាងបាន គេក៏ក្រោកឡើងហើយនិយាយថា :

- ម៉ូលីយ៉ាដណ្តប់ភួយយ៉ាងនេះក្តៅស្លាប់ហើយ !

ស្រស់ស្រីធ្វើមិនឮទៀត តែសុជាតិដឹងណាស់ទៅហើយ ភ្នែកនរណាដេកលក់ឬមិនលក់នោះ គេទាញភួយនាងគ្រវាត់ចោលទៅម្ខាង ម៉ូលីយ៉ាបើកភ្នែកសម្លក់អ្នកគ្មានព្រិច :

- បើលោករំខានខ្ញុំបែបនេះ តើឲ្យខ្ញុំគេងម៉េចនឹងកើតទៅ !

- បងមិនរំខានទេ បងដឹងថាអូនមិនទាន់គេងលក់ ទើបធ្វើយ៉ាងនេះ អូនបែកញើសជោកទៅហើយមិនឲ្យបងបកភួយម្តេចនឹងកើត ឥឡូវគេងទៅបងមិនរំខានទេ !

ថាហើយគេដើរទៅបើកបង្អួចបង្ហើរអារម្មណ៍ធ្វើមិនដឹង !

ម៉ូលីយ៉ានឹកថា " អាគាត់នេះធ្វើឫកណាស់ យប់នេះតែហ៊ានផ្តេសផ្តាសអញត្រញិចទាល់តែជាច់មុខតែម្តង " ម៉ូលីយ៉ា គិតពីនេះពីនោះហើយនាងមិនបើកភ្នែកទេ ក្រែងឃើញសុជាតិនាំគ្នាកើតការក្តៅក្រហាយ ។ មួយសន្ទុះទើបគេបិទបង្អួចសិន នាងលួចបើកមើលឃើញគេដើរមកដល់គ្រែនាង ចិត្តអ្នកក្តុកក្តួលភ័យព្រួយមិនបាត់ អ្នកប្រុស

ឡើងគេងម្តងទៀតឃើញរូបរាងជ្រងោ សាច់សភ្លឹងដូចសំឡី កាលពីដំបូងគ្រាន់តែស្អាតធម្មតាទេ ឥឡូវកាន់តែស្អាតឡើងសាច់ឲ្យម៉ដ្ឋខៃដូចពងមាន់ ដើម្បីកុំឲ្យភ្នែកអ្នកឃើញរូបនាងច្បាស់ពេក អ្នកងើបទៅបិទភ្លើង ហើយក៏តាំងអុជចង្កៀងអាល់កុលឲ្យភ្លឺផ្លុងៗគេឡើងប្រះគេងវិញ ម្តងនេះលែងហ៊ានបើកភ្នែកទៀតហើយ ទាញខ្នើយឱបមកដាក់កណ្តាល យប់កាន់តែជ្រៅដូចជារងាបន្តិចវិញ អ្នកងើបមកបិទបង្អួច ម៉ូលីយ៉ាបើកភ្នែកក្រឡង់ នាងគេងមិនលក់សោះ តែដល់ឃើញសុជាតិក្រោកឈរនាងបិទភ្នែកទៅវិញ តែមិនបានរំលងពីក្រសែភ្នែករបស់គេទេ កាយវិការនេះសុជាតិឃើញទាំងអស់ អ្នកអស់សំណើចតែក្នុងពោះ អ្នកប្រុសសម្លឹងមុខនាងយ៉ាងយូរ ថ្វីត្បិតតែចង្កៀងដ៏តូចមានពន្លឺតិចៗមែន តែសម្រស់ស្រីបានប្រឆាំងភពងងឹតចូលក្នុងកែវភ្នែកជានិច្ច អ្នកបារម្ភណាស់ តែចិត្តចម្លូតរបស់អ្នកវាលែងស្តាប់បង្គាប់គំនិតអ្នកហើយ គេគិតថាទៅគេងនៅខាងក្រៅវិញ គេសម្លឹងមុខនាងជាចុងក្រោយ ហើយឱនថើបមួយខ្សឹតយ៉ាងវែង ស្រីនៅស្ងៀមតែដូចជាព្រឺខ្លាក អ្នកអត់ទ្រាំពុំបានក៏អស់សំណើច ហើយប្រមូលភួយរត់ចេញមកក្រៅព្រោះភាពត្រជាក់នាពេលរាត្រីបានធ្លាក់មកបន្តិចម្តងៗ ។

ព្រឹកឡើង អ្នកកំលោះបើកទ្វារបន្ទប់ឲ្យនាងចេញសម្អាតខ្លួន តែគេមិនបើកទ្វារផ្ទះទេ ម៉ូលីយ៉ាហាក់ដូចជាសីៗយ៉ាងម៉េចមិនដឹង

ទេ នាងដើរទៅដូចជាបះជើង នាងតិតច្រើនពេកដោយមិនបានគេង ស្រីទប់ខ្លួនដើរទៅកាន់បន្ទប់ទឹក នៅតែមិនបាត់ភាពធីងធោង ស្រាប់តែវិលមុខកាន់តែខ្លាំងឡើងដើរទៅទៀតមិនកើត នាងដាក់ខ្លួនអង្គុយចុះដកសក់ខ្លួនឯងតិចៗ សុជាតិក្រឡេកឃើញដូច្នោះក៏រហ័សស្ទុះមករកនាង គេចាប់នាងឲ្យក្រោកឈរ ស្រីក្រោកតាមគេដោយសម្រួល !

នរៈសួរទៅនាងតិចៗ :

- អូនកើតអីហ្នឹង ?

មាណវីមិនតបទេ នាងគ្រាន់តែបើកភ្នែកសម្លឹងមើលគេ អ្នកប្រុសដឹងថានាងមិនស្រួលខ្លាំង គេចាប់បីនាងចូលបន្ទប់របស់គេ ហើយដាក់ស្រីទៅលើពូកព្រមទាំងនិយាយថា :

- ប្រហែលពីយប់មិញនេះអូនមិនបានគេងហើយ បានជាមានជំងឺបែបនេះ !

នរៈយកប្រេងខ្យល់មកលាបឲ្យនាងបន្តិច ហើយនិងទឹកក្ដៅហុចទៅឲ្យនាង គេគ្រាហ៏ស្រីឲ្យអង្គុយញ៉ាំថ្នាំរួចផ្ដេកទៅវិញ !

- អូនគួរតែចាក់ថ្នាំមួយម្ជុលហើយ បានរហ័សជា !

- បានហើយ មិនបាច់ទេ !

គេមិនស្ដាប់សម្ដីនាងឡើយ បុរសបូមថ្នាំកន្លះស៊ីរ៉ាំងរួចដើរតម្រង់មករកនាងវិញ :

- អូនគេងផ្ទៀងទៅ បងចាក់ថ្នាំឲ្យ !

ស្រស់ស្រីមិនព្រម រួចងើបស្ទុះក្រោកតែត្រូវបុរសចាប់ជាប់ :

- ចង់ទៅណា អូនដើរមិនរួចទេ កុំរវៀនចិត្តខ្លាំងពេក នៅខឹងមិនទាន់បាត់ដល់ណាទៀត បើបងមានចិត្តអាក្រក់ធ្វើបាបអូនយប់មិញនេះ អូនក៏មិនរួចខ្លួនដែរ ចាំពេលជាបងនឹងជូនអូនទៅបង្ហាញខ្លួនហើយប្រឡងចប់បងជូនអូនទៅជួបជាមួយនឹងបងប្ដូវិញ !

- ខ្ញុំមិនទៅទេ មានន័យអីទៀត បើខ្ញុំជួបនឹងបងប្ដូវខ្ញុំឈឺចាប់ណាស់មិនបាច់លោកសួរខ្ញុំទេ អ្វីដែលលោកធ្វើលោកអាចវិនិច្ឆ័យដោយខ្លួនឯងបានហើយ តើលោកពេញចិត្តទេ បើសិនជាគូដណ្ដឹងរបស់លោកត្រូវគេម្នាក់ផ្សេងឱបតាមអំពើចិត្តរួចទៅហើយនោះ !

- គំនិតអូនប្រពៃហើយ តែអូនមិនបានដឹងការពិតទេបានចេះតែខឹងនឹងបង ដល់ពេលអូនដឹងប្រាកដជាអាណិតស្រឡាញ់បងវិញជាមិនខាន !

- រឿងពិតស្អីទៀត ហួសពេលហើយល្បិចពន្យល់ខ្ញុំនេះ ខ្ញុំស្ដាប់សម្ដីលោកមិនចូលទេ !

ស្រស់ស្រីនាងខឹងណាស់រហូតដល់ស្រក់ទឹកភ្នែក អ្នកប្រុសអាណិតនាងណាស់ តែគេមិនដឹងលួងលោមនាងតាមវិធីណា បើគេនិយាយនាងរឹតតែខឹង បើថើបនាងរឹតតែឆាបឆេះឡើង ក្រៅពីឈរ

សម្លឹងនាងធ្វើភ្នែកម៉ក់ៗ អ្នកមិនដឹងនិយាយយ៉ាងណាជាមួយនឹងនាងទេ គេចង់តែប្រាប់ការពិត តែខ្លាចនាងខូចចិត្តខ្លាំង ប្រឡងមិនកើតពិតជាខកចំហើយ បណ្តោយតាមចិត្តរបស់នាងមួយខ្យល់សិនចុះ អស់ពីយ៉ាំម៉ូលីយ៉ាលួចមើលមុខប្រុសម្តង ភ័ក្ត្រស្រពាប់ស្រពោនដែលនាងមិនដែលយល់នោះក្នុងរយៈពេលមួយឆ្នាំនេះ ធ្វើឲ្យចិត្តស្រីអាណិតគេខ្លះៗដែរ តែនាងគិតថាមិនត្រូវទន់ខ្សោយពេកទេ ទោះបីជាយ៉ាងណា ក៏គេជាមនុស្សដែលត្រូវចាត់ទុកជាមនុស្សមិនល្អជាមួយនាងទៀតដែរ ។

អ្នកប្រុសដើរទៅបើកម៉ាញ៉េតិចៗ នូវបទចម្រៀងកាលពីយប់មិញ " បាត់អូន " ចំណែកគេឈរនៅមាត់បង្អួចបង្ហើរអារម្មណ៍ធ្វើមិនដឹង ។ ម៉ូលីយ៉ាលួចមើលគេបន្តិចនាងក៏ស្ទុះក្រោក តែត្រូវដួលមកវិញសុជាតិរហ័សស្ទុះមករកនាងដោយស្វ័យប្រវត្តិ !

- អូនក្រោកទៅណាទៀត មិនទាន់បានទេ គេដាក់បង្គុយជិតនាង ហើយវែកសក់នាងឲ្យមានរបៀប !

- បើអូនមិនចាក់ថ្នាំមិនងាយជាទេ !

- ខ្ញុំមិនចាក់ទេ កុំបង្ខំខ្ញុំអី !

អ្នកប្រុសមិននិយាយច្រើនទៀតទេ គេដើរចេញមកក្រៅតីថ្ងៃនេះអ្នកត្រូវទទួលអ្នកជំងឺចូលមកថ្មី២នាក់ទៀត ។ អ្នកប្រុសបាន

ផ្ដាំឲ្យស្រស់ស្រីម៉ូលីយ៉ាជួយមើលជំនួសគេផង ចំណែកស្រស់ស្រីវិញ ពេលដែលគេចេញទៅបាត់ហើយ នាងរៀបចំវ៉ាលីសចេញពីផ្ទះដោយ នាងប្រាប់មីងម្នាក់ដែលមកកំដរកូនគាត់ថា :

- មីង បើប្ដីខ្ញុំត្រឡប់មកវិញជម្រាបគាត់ថា ខ្ញុំទៅផ្ទះប៉ាមីង ប្រាប់តែប៉ុណ្ណេះបានហើយ !

និយាយចប់នាងក៏ហៅស៊ីក្លូជិះចេញទៅបាត់ ពេលដែលសុជាតិ ត្រឡប់មកវិញ មីងដែលនាងបានផ្ដាំក៏ប្រាប់នរៈតាមដែលស្រីបានផ្ដាំ។

- ជម្រាបប្រសាសន៍លោក អ្នកស្រីបានផ្ដាំខ្ញុំថាគាត់អញ្ជើញ ទៅផ្ទះប៉ា !

ដំណឹងនេះធ្វើឲ្យគេស្រឡាំងកាំងស្ទើរលត់ស្មារតី តែខំទប់ចិត្តឲ្យនឹង ហើយសួរទៅស្រីចំណាស់នោះវិញថា :

- មីងមានឃើញប្រពន្ធខ្ញុំទៅជាមួយនឹងអ្នកណាដែរទេហើយ ឃើញមានយកស្អីទៅខ្លះដែរទេ ?

- ចាស អ្នកស្រីយួរវ៉ាលីសនិងកាបូបធំមួយហើយបានហៅស៊ីក្លូជិះចេញទៅ !

ស្ដាប់ការរ៉ាយរ៉ាប់ហើយ អ្នកប្រុសប្រញាប់ចូលទៅក្នុងបន្ទប់របស់ម៉ូលីយ៉ា ដែលទ្វារគ្រាន់តែផ្ទឹប បើកទ្វារចូលទៅ នាងយកខោអាវពាក់តែបន្ដិចបន្តួចទេ តែបែរជាបាត់សៀវភៅអស់រលីង នរៈដើរ

មកជិតតុឃើញកូនក្រដាសមួយសន្លឹកដែលសង្កត់ថូផ្កាពីលើ គេទាញវា យកមកអានដោយមានន័យយ៉ាងសង្ខេប : .

*" មនុស្សមិនអាចរស់នៅបានទេក្នុងការគាបសង្កត់ផ្លូវចិត្ត តែខ្ញុំនៅជំពាក់គុណលោកដដែល ពេលណាមួយខ្ញុំនឹងសងគុណលោកវិញ បើខ្ញុំមានភ័ព្វសំណាងវាសនា មានជីវិតរស់នៅតទៅទៀត "*

លិខិតមានន័យកំបុតកំបុយ សុជាតិត្រឡប់វាមកម្ខាងទៀត អក្សរសរសេរដោយប៊ិចក្រហមថា :

*" គ្រឿងអលង្ការក្នុងទូដែលខ្ញុំបានទុក ចំណែកសម្លៀកបំពាក់ដែលទើបនឹងទិញពេលចុងក្រោយនេះ ខ្ញុំសូមជូនលោកវិញដែរ "* ។

គ្រាន់តែអានចប់ភ្លាមគេហែកចោល អង្គុយធ្មឹងដូចជារូបគ្មានវិញ្ញាណហាក់រកគិតអ្វីមិនកើត យូរបន្តិចទើបគេបើកទូឡើងរើកកាយមើលឃើញគ្រឿងអលង្ការ ដែលអ្នកបានប្រគល់ឲ្យនាងតុបតែងខ្លួននោះនៅទាំងអស់វិញ គេហូតប្រអប់តូចមកមើលបុរសចាប់នាឡិកាដៃនៅក្នុងនោះមកផ្ទៀងផ្ទងទាំងនិយាយថា :

- ឯងអភ័ព្វណាស់ ម្ចាស់ឯងគេរត់ចោលឯងហើយ !

ពោលចប់គេដាក់នាឡិកាដៃធុនអូមេហ្គា ចូលទៅក្នុងប្រអប់យកទៅដាក់បន្ទប់គេរួចអង្គុយសំកុក ទាល់តែងងឹតទើបបើកភ្លើងបំភ្លឺផ្ទះ ។ អ្នកប្រុសឈរសម្លឹងបន្ទប់ម៉ូលីយ៉ាទាំងទឹកមុខស្រងូតស្រងាត់

ពីដើមបន្ទប់នេះធ្លាប់មាននារីសោភាមួយរូបចេញចូល ហើយនាងបែរមកញញឹមយ៉ាងស្រស់ដាក់អ្នក បន្ទាប់មកនាងសម្លក់អ្នក... រឿងទាំងឡាយបានចាក់ស្រេះនៅក្នុងខួរក្បាលរបស់អ្នក គេដកអារម្មណ៍ចេញពីពិភពស្រមើស្រមៃ រួចដើរចូលទៅក្នុងផ្ទះបាយ សម្លឹងមើលម្ហូបអាហារពាសពេញតុ អ្នកហាក់មិនឃ្លានអ្វីទាំងអស់ ពេលនេះអ្នកដូចជាទន់ខ្សោយណាស់ កំសាកណាស់ ម៉ូលីយ៉ាជាអ្នកដទៃពិតៗ ហើយរយៈពេលដែលនាងមករស់នៅជាមួយអ្នកនេះ ក៏គ្មានរីកចម្រើនសម្រេចអ្វីដែរក្រៅពីធ្វើឲ្យខួរក្បាលវិលក្បុង តែចិត្តមួយនៅមិនដាច់អាល័យខ្លាចនាងជួបនឹងគ្រោះថ្នាក់ ខ្លាចនាងមិនមានលុយចាយ ខ្លាចនាងមិនបានសុខ គិតចុះគិតឡើងគេគ្របបាយចោលនៅលើតុ ហើយដើរចូលទៅក្នុងបន្ទប់វិញ ចាក់ម៉ាញ៉េបទ " បាត់អូន " ដដែល ។

ពីមុនអ្នករាំជាមួយនឹងនាងដោយសារតែបទនេះ ហើយឥឡូវបទនេះធ្វើឲ្យអ្នកក្រៀមក្រំមិនស្បើយ ទីបំផុតគេស្រែកតិចៗតាមបទដែលច្រៀងដែរ !

- បាត់អូន បាត់គ្មានដំណឹង តើអូននៅទីណា ? ម៉ូលីយ៉ាវិលវិញមកអូន ! បងរង់ចាំអូនជានិច្ច !

សំឡេងថ្ងូររបស់កំលោះហាក់មិនរសាយពីខួរក្បាលសោះ គឺនេះហើយជាជីវិតដែលត្រូវស្គាល់ថា រសជាតិវាយ៉ាងណានោះ ។

# វគ្គទី៦
# រស្មីឆ្លងចិត្ត

យើងក្រឡេកមើលមកស្រស់ស្រីម៉ូលីយ៉ាវិញម្តង ! នាងបានមកសំណាក់នៅផ្ទះមិត្តភក្តិជិតស្និទ្ធរបស់នាងម្នាក់ឈ្មោះចិន្តា មាណវីត្រូវបានមិត្តភក្តិហាមឃាត់ឲ្យនៅទីនោះ រង់ចាំថ្ងៃប្រឡងសញ្ញាបត្រ ចិន្តាបានជម្រាបម្តាយនាងថា នាងពឹងម៉ូលីយ៉ាឲ្យមកគេងនៅទីនេះដើម្បីជួយបង្ហាត់លំហាត់នាង ព្រោះជិតដល់ពេលប្រឡងហើយ ណាមួយនាងជាសិស្សពូកែទៀត លោកស្រីក៏ពុំជំទាស់អ្វីដែរព្រោះគាត់ស្រឡាញ់កូនគាត់ណាស់ ចង់ឲ្យនាងប្រឡងជាប់ជាស្ថាពរ ។

ជារៀងរាល់ថ្ងៃ ចិន្តាតែងតែដេញដោលសួរម៉ូលីយ៉ា ពីរឿងដែលនាងចុះចេញពីផ្ទះ និងឈ្មោះនាងដែលចុះកាសែត ព្រោះចិន្តានឹកថាសុជាតិជាបងប្រុសនាងពិតប្រាកដ ។ តែម៉ូលីយ៉ាពុំបាននិយាយរឿងនេះប្រាប់មិត្តនាងទេ ស្រីច្រើនតែសម្តែងនូវការធុញទ្រាន់ ម៉្លោះហើយទើបចិន្តាលែងហ៊ានសួរនាំតទៅទៀត ។

ចំណែកលោកប្រុសលោកស្រីជាឪពុកម្តាយរបស់ចិន្តា តាំងពីបានស្រស់ស្រីនាងមកស្នាក់នៅជាមួយនឹងកូនស្រីហើយ គាត់ទៅគេង

លេងនៅកំពង់សោមមិនទាន់មកវិញដែរ ម៉្លោះហើយការដែលស្រីមិនបានទៅសាលារៀន គ្មាននរណាសង្ស័យឡើយ ។

៣ថ្ងៃកន្លងផុតទៅសុជាតិបានស៊ើបរកម៉ូលីយ៉ារាល់ថ្ងៃ អ្នកមិនសូវនៅផ្ទះទេគេដើរបាត់ៗ មួយពេលៗអ្នកគ្រាន់តែមកអើត និងចាក់ថ្នាំឲ្យអ្នកជំងឺប៉ុណ្ណោះ ទោះជាខំស្វែងរកយ៉ាងណាក៏គេមិនអាចរកម៉ូលីយ៉ាឃើញដែរ អ្នកប្រុសអស់សង្ឃឹមទាំងស្រុងព្រោះម៉ូលីយ៉ាបានយកសៀវភៅរបស់នាងទាំងអស់ទៅ បានសេចក្តីថា គឺនាងពិតប្រាកដជាមកប្រឡងមិនខានឡើយ ។ អ្នករង់ចាំតែថ្ងៃប្រឡងរបស់ស្រីប៉ុណ្ណោះ ដែលគេអាចបានជួបជាមួយនឹងនាង ។

ថ្ងៃអាទិត្យមួយដែលចិន្តាទៅផ្សារបាត់ ម៉ូលីយ៉ាអង្គុយចាក់កូនកន្សែងក្នុងបន្ទប់ទទួលភ្ញៀវ នាងមានអារម្មណ៍ច្រើនណាស់គិតមិនចេះចប់ហាក់មានការស្តាយក្រោយ ពីរឿងនាងដែលចុះចោលសុជាតិស្រីនឹកអាណិតគេយ៉ាងចម្លែក ថ្វីត្បិតតែគេប្រព្រឹត្តអំពើមិនសមរម្យចំពោះនាងមែន តែក្នុងន័យគេជាមនុស្សមួយរូបដែលចេះគិតវែងឆ្ងាយដែរ នាងនឹកថាធម្មតាការរស់នៅជាមួយគ្នារវាងប្រុសហើយនិងស្រីតែងតែមានអារម្មណ៍ទោរទន់យ៉ាងនេះឯង បើសិនជាគេមិនចេះគិតនាងប្រាកដជាឈឺចាប់ជាងនេះទៀត តែនាងត្រូវអរគុណវិញតែមិនដឹងចិត្តនាងយ៉ាងម៉េច ចេះតែចង់ចុះចោលឲ្យផុតពីមុខគេ ។

គំនិតចេះតែគិតវែងឆ្ងាយ ឈរចាក់កូនកន្សែងយូរពេករោយ កនាងងាកមុខម្តង យុវជនសង្ហាច្រត់ដៃញញឹមមករកនាង ស្រីសែន ភ័យញ័រមាត់តតាត់ :

- សុផាន់ណាមករកអីនៅទីនេះ មករកចិន្តាមែនទេ ?

- ខ្ញុំមករកចិន្តាមែន តែបែរជាជួបនឹងម៉ូលីយ៉ាទៅវិញ ប៉ុន្មានថ្ងៃនេះនាងកើតអីបានជាមិនឃើញទៅរៀន ?

- ខ្ញុំអត់កើតអីទេ តែខ្ញុំមិនចង់ទៅ ! សុផាន់ណាឯងមករកចិន្តាវាមិននៅទេ !

- បើចិន្តាមិននៅជួបជាមួយនឹងម៉ូលីយ៉ាឯងក៏បានដែរ យើងនិយាយគ្នាពីរឿងលើកមុនសិន !

- ជិតប្រឡងហើយ មិនគួរណាសុផាន់ណាឯងលើកយករឿងនេះមកនិយាយសោះ !

- ចុះមានរំខានដល់ការរៀនសូត្រអីរបស់ម៉ូលីយ៉ាឯង ខ្ញុំមាននិយាយពេលដែលម៉ូលីយ៉ាឯងរៀនឯណា !

- ខ្ញុំគ្មានពេលនិយាយជាមួយទេ !

- តែមានពេលមកលេងផ្ទះចិន្តា !

គេនិយាយទាំងគោះជើងតិចៗសម្លឹងមុខស្រី មាណវីមិនហ៊ានមើលមុខគេចំទេ នាងគិតតែពីចាក់កូនកន្សែងបុរសដើរចូលមកអង្គុយ

លើកៅអីទល់មុខនាង ដោយសម្លឹងដៃនាងចាក់កូនកន្សែងព្រមទាំងនិយាយថា :

- ឈប់ចាក់សិនទៅ ខ្ញុំចង់និយាយជាមួយនាងម្តងទៀត !

- ចុះបើគ្រាន់តែនិយាយ រឿងអីមកហាមឃាត់ខ្ញុំមិនឲ្យចាក់នោះ យកល្អយើងនាំគ្នានិយាយនៅពេលប្រឡងហើយវិញបើនិយាយយ៉ាងនេះ ហើយនៅទីនេះមិនសមរម្យទេ បើម៉ាក់ចិន្តាមកទាន់គាត់នឹងជេរខ្ញុំថាយ៉ាងម៉េចទៅ !

- ប៉ាម៉ាក់ចិន្តាគាត់ទៅកំពង់សោមជាមួយនឹងប៉ាម៉ាក់ខ្ញុំអស់ហើយ ផ្ទះនេះក៏ដូចជាផ្ទះរបស់ខ្ញុំដែរ ព្រោះខ្ញុំនិងចិន្តាជាបងប្អូនជីដូនមួយនឹងគ្នា !

- ចាស ទោះជាយ៉ាងណាក៏វាមិនសមរម្យដែរ !

ស្រីនិយាយដាច់ៗដើម្បីកម្ចាចិត្តបុរសកុំឲ្យបង្ខំចិត្តនាងបាន !

- ម៉ូលីយ៉ា ខ្ញុំធ្វើការសម្រេចចិត្តសុទ្ធតែមានបំណងត្រឹមត្រូវហេតុនេះខ្ញុំមិនធ្វើឲ្យបំណងខ្ញុំខកខានបានទេ !

- សុផាន់ណាឯងចង់និយាយពីរឿងស្អីទៀតហើយ ?

- ពីរឿងថ្ងៃមុនហ្នឹងណា៎ !

- រឿងនោះវាដាច់ស្រេចហើយ ព្រោះខ្ញុំមានគូដណ្តឹងរួចទៅហើយ ខ្ញុំរៀបការនៅពេលដែលខ្ញុំប្រឡងរួច ហេតុនេះនារីម្នាក់មិន

អាចប្រគល់ស្នេហាទៅបុរសណាផ្សេង ក្រៅពីបុរសដែលគេពេញចិត្ត នោះឡើយ ! សូមសុផាន់ណាឯងបំបាត់សតិអារម្មណ៍មិនជឿនលឿន នេះចោលទៅ ខ្ញុំអីនារីស្អាតៗមួយគរគោក ហើយរូបខ្ញុំក៏គ្មានអ្វីគួរ ឲ្យអស្ចារ្យដែរ !

- ខ្ញុំបានប្រាប់ម៉ូលីយ៉ាហើយថាអ្វីដែលខ្ញុំចង់បានគឺខ្ញុំត្រូវតែរក ឲ្យបានសម្រេច ! គ្មានអ្វីដែលមករារាំងខ្ញុំបានទេ !

- សុផាន់ណាឯងកំណត់បំណងបែបនេះមានបានគិតហើយឬ នៅដែលមុននឹងហាមាត់និយាយបែបនេះ ?

- កំណត់រួចហើយគឺបានគិតច្បាស់ណាស់ មិនដែលធ្វើអ្វីមិន គិតនោះទេ !

- តែគិតមិនត្រូវ ចង់បានរបស់ដែលមានម្ចាស់រួចហើយ វា មិនងាយបានដោយស្រួលនោះទេ បើសិនជាបានគឺបានដោយថោកទាប បំផុត សុផាន់ណាឯងជាមនុស្សថ្លៃថ្នូរ ខ្ញុំជឿជាក់ថាមិនប្រព្រឹត្តអ្វីដែល នាំឲ្យថោកទាបនោះទេ !

សម្តីនាងមានន័យជ្រៅគួរឲ្យពិចារណាដែរ តែសុផាន់ណាបែរ ជាមិនសូវយកចិត្តទុកដាក់នឹងស្តាប់ទៅវិញ គេសម្លឹងនាងយ៉ាងមុតធ្វើ ឲ្យតូចតន់តក់ស្លុតជាខ្លាំង នាងតូចចិត្តណាស់ហេតុអីក៏គេរាល់គ្នាតាម ផ្តន្ទានាងម្ល៉េះ ? គិតទៅនាងដូចជាខឹងនឹងធម្មជាតិដែលតាក់តែងនាង

ឲ្យមានរូបសម្រស់លើសគេ ហើយតម្រូវឲ្យវាសនាអភ័ព្វលើសគេទៅវិញ នាងសម្លឹងទៅសុផាន់ណាដោយក្រសែភ្នែកគួរឲ្យខ្លាច មនុស្សនេះពិតជាកម្រោលផទិសហើយ ។ ម្តងនេះនាងពិតជាធូន់ហើយបន់ឲ្យតែចិន្តារហ័សមកពីផ្សារវិញ មើលទៅសុផាន់ណានាងដូចជាមិនទុកចិត្តសោះ គឺមិនទុកចិត្តថា គេនឹងប្រព្រឹត្តអំពើព្រៃផ្សៃមកលើរូបនាងកញ្ញាក្រោកដើរតែត្រូវសុផាន់ណាចាប់ជាប់ !

- កុំទាន់ទៅណានិយាយគ្នាមិនទាន់ដាច់ស្រេចទេ !

- កុំផ្តេសផ្តាសណាំ សុផាន់ណា ប្រយ័ត្នខ្ញុំស្រែកផ្ទើលគេឥឡូវហ្នឹង !

- ទោះជាស្រែកដាច់សរសៃក គ្មាននរណាគេឮដែរ !

- ចិន្តាមកហើយលែងខ្ញុំ !

សុផាន់ណាខកចិត្ត គេត្រូវព្រលែងម៉ូលីយ៉ាទាំងសោកស្តាយ ! ចិន្តាយល់ការណ៍មិនស្រួលហើយដែរ នាងសម្លឹងមុខម៉ូលីយ៉ាហើយសម្លឹងមុខបងប្រុស តែនាងមិនសង្ស័យថាបងប្រុសចង់ប្រព្រឹត្តអំពើផ្តេសផ្តាសនោះទេ បែរជាថាអ្នកទាំងពីរត្រូវគ្នាទៅវិញ ហើយឃើញនាងមកទាន់ក៏ព្រលែងដៃចេញ ដោយខ្លាចអន់ចិត្តនិងអៀនខ្មាសនាង ! ចិន្តាសួរទៅសុផាន់ណាថា :

- បងមកយូរហើយមែនទេ ? បងនៅអង្គុយលេងជាមួយនឹង

ម៉ូលីយ៉ាសិនទៅ ខ្ញុំមានការទៅណោះមួយភ្លែត !

ពូជូថ្មោះម៉ូលីយ៉ាប្រញាប់ឃាត់ :

- ឯងគិតទៅណាទៀតហើយចិន្តា ខ្ញុំមានការទៅណោះជាប្រញាប់ផង !

- អឺ...បើឯងមានការដែរទៅចុះ !

បានឱកាស ស្រស់ស្រីដើរចូលទៅក្នុងផ្ទះនាងយកកាបូបនិងវ៉ាលីសចេញទៅបាត់ ចំណែកអ្នកទាំងពីររវល់តែជជែកគ្នាមិនដឹងថាស្រីស្រស់នាងលួចរត់ចេញទេ ។ មាណវីហៅស៊ីក្លូជិះដោយគ្មានគោលដៅ នាងប្រាប់ឲ្យគេឈប់នៅមុំពេទ្យលោកសង្ឃ គ្រាន់តែស៊ីក្លូឈប់ង៉ក់ភ្លាម នាងឲ្យថ្លៃស៊ីក្លូបម្រុងឈានជើងចុះ ស្រាប់តែរថយន្តរ៉ូយ៉ូតាមួយគ្រឿងមកឈប់ង៉ក់ទន្ទឹមនឹងនាងដែរ គឺជាបូរីទាំងសាច់ទាំងឈាមអង្គុយអែបជាមួយគេ គឺជាប្អូនជីដូនមួយរបស់បូរី ។

បូរីឧទានឡើង :

- ម៉ូលីយ៉ា !

មួយម៉ាត់ប៉ុណ្ណោះក៏ស្ងាត់ឈឹងទៅវិញ គ្មានអ្វីខ្លោចផ្សាលើសនេះទៀតទេ ម៉ូលីយ៉ាយំឥតខ្លាសអាកប្បកិរិយាសោះអង្អើយរបស់គេធ្វើឲ្យនាងសែនសង្ស័យ បូរីពិនិត្យតំណក់ទឹកភ្នែកស្រីទើបនិយាយ :

- ហួសពេលកម្សត់ហើយម៉ូលីយ៉ា ព្រោះយើងទាំងពីរបែកផ្លូវ

គ្នាដើររួចទៅហើយ អូនក៏មានប្ដី បងក៏មានប្រពន្ធ ដូច្នេះរឿងអីក៏ត្រូវចប់ដោយគ្មានសន្ទតទៅចុះ ហើយយើងរាប់អានគ្នាដូចដើមវិញទៅណាអូន !

សម្ដីនេះធ្វើឲ្យម៉ូលីយ៉ារីតតែយំខ្លាំងឡើង ទាល់តែគេមើលមុខនាង បូរីនីកខ្មាសគេពេកក៏បបួលនាងឡើងរថយន្តសិនចាំរកពាក្យនិយាយគ្នាជាក្រោយ នារីអូសដៃបូរីឲ្យឡើងឡាន ហើយនាងជួយយូរកាបូបសៀវភៅនិងវ៉ាលីសដាក់លើឡាន បើកផុតពីទីប្រជុំជនបន្តិចបូរីក៏ផ្ដើមសួរនាង :

- ម៉ូលីយ៉ាបងឆ្ងល់ណាស់ពីការកែប្រែគំនិតដ៏ឆាប់រហ័សរបស់អូន !

ស្រស់ស្រីនាងកម្លាចិត្តនាងឲ្យក្លាហានបន្តិច ដើម្បីសម្រួលសម្ដីតបទៅវិញ :

- អូនមិនទាន់មានប្ដីឯណាទេ !

- ប្រាប់បងតាមត្រង់មក បងមិនជឿទេ ព្រោះអ្វីៗបានកន្លងហួសអស់ទៅហើយ តែគួរឲ្យស្ដាយដែរចំណែកបងៗមិនលាក់ទេ បងមានប្រពន្ធហើយ គឺអូននារី !

មាណវីហាក់ស្លុតចិត្ត នាងគ្មានពាក្យអ្វីដែលត្រូវតបទៅគេវិញទៀតនោះទេ ! ស្រីជូតទឹកភ្នែកឲ្យស្រឡះព្រមទាំងតាំងស្មារតីឲ្យនឹង

សម្លឹងមុខគេបន្តិចទើបនិយាយឡើង :

- អូនមានប្ដីមែន អូនគ្មានបំណងរត់ចេញពីផ្ទះទេ គឺជារឿងថៃជន្យដោយសារតែការច្រណែនឈ្នានីសតែប៉ុណ្ណោះ ឈប់រំលឹកទៅគ្មានអ្វីដែលមានន័យសម្រាប់រូបអូនទៀតទេ វាផ្ដល់តែការឈឺចាប់ឲ្យយើងតែប៉ុណ្ណោះ !

- បានន័យថាអ្នកមីងសំអឿនជាអ្នកផ្ដើមគំនិតឲ្យអូនរត់ចេញពីផ្ទះមែនទេ ?

ស្រស់ស្រីគ្រវីក្បាលមួយៗ :

- រឿងនេះអូនមិនចង់ជម្រាបបងទេ ព្រោះថា...

- ព្រោះថាអី អូននិយាយមក !

គេបង្ខំឲ្យនាងនិយាយ ព្រោះគេហាក់ដូចជាចាប់អារម្មណ៍ក្នុងរឿងនេះណាស់ អ្នកយល់ដែរថាអ្វីៗវាបានកន្លងហួសទៅហើយ និងមិនអាចវិលត្រឡប់មកវិញបានទេ តែចង់ដឹងការពិតមួយឲ្យច្បាស់លាស់ដើម្បីរកយុត្តិធម៌ សម្រាប់ថ្លឹងថ្លែងវិនិច្ឆ័យទឹកចិត្តមនុស្សដែលរស់នៅលើផែនដី តើវាល្អឬអាក្រក់ប៉ុនណា ដូជាតិ ព្រៃផ្សៃប៉ុនណា ?

- អូននិយាយទៅ !

- ចាស អូនសម្រេចចិត្តនិយាយប្រាប់បងទៅចុះ !

មាណវីរៀបរាប់រឿងរ៉ាវ ដោយសារតែម្ដាយចុងចិត្តកំណាច

ឃោរឃៅហួតដល់ចប់ !

- ចុះសព្វថ្ងៃនេះអូននៅឯណាដែរ ?

- ចាស គឺមានលោកម្នាក់ជួយនៅក្នុងរឿងនេះ គេបានទិញខ្ញុំពីទីនោះ !

នារីទ្រឹងស្តាប់រឿងម៉ូលីយ៉ាចំហមាត់ នាងនឹកដូចជាអាណិតស្រស់ស្រីយ៉ាងច្រើនតែដូចជាបារម្ភខ្លះដែរ។ អ្នកប្រុសសញ្ជឹងគិតបន្តិចទើបបន្ត :

- ចុះអូនគិតបែបណាទៅវិញ ?

- ចាស មិនអាចរស់នៅជាមួយគេបានទេ អាចចាត់ទុកថាគេជាអ្នកមានគុណលើអូនច្រើនណាស់ តែអូនមិនទុកចិត្តគាត់ព្រោះគេនៅកំលោះ !

នាងរៀបរាប់រឿងរបស់សុជាតិប្រាប់បូរីពីអត្តចរិតរបស់គេ ! បូរីសញ្ជឹងគិតយ៉ាងយូរទឹកមុខគេស្រពោនហួសពីការថ្លែង តាំងពីណាពីណើមក បូរីកម្រសម្តែងការអស់សង្ឃឹមណាស់ គេជាមនុស្សអធនគ្រប់បែបយ៉ាង អ្នកប្រុសបញ្ឈារថយន្តទៅមាត់ទន្លេហើយឈប់នៅកន្លែងដែលមានកៅអីបង់ពីរ នារីចុះទៅទឹកមុខនាងស្រពោនដែរមកពីគេឃើញវែងឆ្ងាយ បូរីដាក់ខ្លួនអង្គុយជិតម៉ូលីយ៉ា ទឹកមុខគេនៅតែស្រពោនដដែល គេសម្លឹងទៅមាត់ទន្លេដែលត្រូវវាំយោបក់បោកបង្កើត

បានជារលកកណ្ដាលថ្ងៃបណ្ដើរកូនព្រិច១ទាំងរញ្ជួយចិត្ត ។

អ្នកប្រុសសម្លឹងមើលមុខម៉ូលីយ៉ា ដោយលួចមើលនារីបន្តិច ទាំងពីរនាក់មានទឹកមុខប្លែកគ្នា អ្នកហាក់ទទួលអារម្មណ៍ចម្លែកនូវវិប្បដិសារីដែលមកទន្ទ្រានរូបគេឲ្យទឹកស្ដាយគ្រប់បែបយ៉ាង ។

- អាយ៉ា...អូនគិតទៅណាវិញ អូនមានទិសដៅឬក៏អត់ ?

នាងឈ្ងោកមុខចុះបន្តិចហាក់មិនចង់និយាយ តែនាងប្ដូរគំនិតវិញ ស្រីងើបមុខទើបនិយាយឡើង :

- គ្មានទិសដៅទេ !

- អ៊ីចឹងទៅផ្ទះបងសិនហើយប៉ាម៉ាក់គាត់តែងលើកឈ្មោះអូន និងស្ដាយរូបអូន ថ្វីត្បិតតែកាលមុនទាំងបងទាំងរូបគាត់ ថាអូនជាស្រី គាត់នៅតែនឹកអូន ស្រឡាញ់អូនមិនបាត់ដែរ !

ម៉ូលីយ៉ាអេះអុញបន្តិចទើបឆ្លើយ :

- អូនខ្លាច ប៉ាម៉ាក់បងមិនពេញចិត្តនឹងឃើញអូនសម្រាកនៅទីនោះ !

- មិនអីទេ ទោះអូននៅទីនោះរហូតក៏មិនអីដែរ បើសិនជាគាត់ដឹងថាអូនគ្មានបំណងរត់ចោលផ្ទះអ៊ីចឹង គាត់រឹតតែអាណិត តែតាមគំនិតបង បងចង់ឲ្យអូន...

អ្នកហាក់មិនចង់និយាយ....

- តែមិនអីទេចាំដល់ផ្ទះសិនសឹមនិយាយ តោះយើងត្រឡប់ទៅផ្ទះវិញថ្ងៃត្រង់ហើយ ។

គេទាំងបីនាក់នាំគ្នាឡើងរថយន្តវិញ ម្នាក់ៗមានទឹកមុខស្ងប់ស្ងាត់រៀងខ្លួន តាមផ្លូវគេគ្មាននិយាយអ្វីបន្តិចសោះឡើយ ។

មកដល់ផ្ទះបូរីដើរទន្ទឹមនឹងម៉ូលីយ៉ាឡើងទៅលើ នារីដើរពីក្រោយដោយទឹកមុខស្រពោនចម្លែក ។ អ្នកស្រីមន្ទាយល់បូរីបណ្តើរម៉ូលីយ៉ាដើរតាមក្រោយផង គាត់សែនស្លុតចិត្តទឹកភ្នែកជរាហូរចុះមកដោយមិនដឹងខ្លួន :

- កូនយ៉ា !

- ម៉ាក់អ៊ំ !

នាងយំឱបអ្នកស្រីដោយរន្ធត់ គាត់មានសន្តានចិត្តល្អណាស់ទោះបីនាងជាស្រីមិនតប្បីដែលគួរឲ្យស្អប់ខ្ពើមក៏ដោយ តែគាត់នៅតែរាប់អាននាងដដែល ក្រសែភ្នែកដ៏ស្រវាំងរបស់គាត់ខំប្រឹងសម្តែងនូវមនោសញ្ចេតនាទន់ភ្លន់មករកនាងជានិច្ច ! នារីឥតបានឈរមើលទិដ្ឋភាពទាំងនេះទេ ស្រីចូលទៅក្នុងបាត់ភ័យព្រួយយំសសឹកតែម្នាក់ឯងខ្លាចបូរីបោះបង់នាងចោលទៅរកម៉ូលីយ៉ាវិញ គិតទៅនាងមានគំនិតក្មេងខ្ចីណាស់ អ្នកស្រីជូតទឹកភ្នែកហើយផ្តើមសួរទៅម៉ូលីយ៉ា :

- កូនយ៉ា ម៉ាក់អ៊ំមិនយល់សោះ ហេតុអីក៏កូនធ្វើយ៉ាងនេះ ?

www.lovekhmer.com

បើមិនពេញចិត្តយ៉ាងណាម៉េចក៏កូនមិននិយាយ ម៉ាក់អ៊ំឃើញកូនស្រី ដូចជាពេញចិត្តបូរីដែរ ទើបហ៊ានចូលស្តីដណ្តឹងហ្នឹងណាំ !

- អូនយ៉ាគ្មានគំនិតបែបនេះទេម៉ាក់ ស្តាប់កូននិយាយសិនតី គំនិតអ្នកមីងសំអឿនទាំងអស់ កូនស្តាយណាស់ !

អ្នកយកដៃខ្ទប់ថ្ងាសទាំងទឹកមុខស្រពោន អ្នកស្រីមន្ទាហាក់ មិនយល់ន័យគាត់ក៏សួរបញ្ជាក់ម្តងទៀត :

- ម៉ាក់ដូចជាស្តាប់មិនបានទេបូរី ! កូននិយាយថាម៉េចហើយ មីសំអឿនហ្នឹងវាបំបែកកូនយ៉ាមិនឲ្យជួបនឹងកូនមែនទេ ?

- បាទ អ៊ីចឹងមែនហើយម៉ាក់ ! មីងសំអឿនបានលក់អូនយ៉ា ទៅឲ្យមេបន (អ្នកប្រុស រៀបរាប់រឿងរ៉ាវទាំងអស់ជូនមាតាស្តាប់ យ៉ាងក្បោះក្បាយ) ។

ចំណែកម៉ូលីយ៉ានាងអង្គុយធ្មឹងដូចរូបចម្លាក់ដោយក្តីរំជួលក្នុង ឱរា អ្នកស្រីសែនអាណិតស្រីគាត់ឱបស្រីពេញដើមទ្រូង តំណក់ទឹក ភ្នែកហូរស្រក់មកលើខ្នងនាងក្តៅឧណ្ហៗ ឯទឹកភ្នែកស្រីវិញហូរពេញ ដើមទ្រូងគាត់ យូរណាស់ទម្រាំគាត់សម្រួលអារម្មណ៍អាចនិយាយបាន វិញ :

- កូនយ៉ា ម៉ាក់អ៊ំស្តាយណាស់ ស្តាយកូនណាស់ ចំណែកនារីក៏ ម៉ាក់អ៊ំពេញចិត្តដែរ តែមិនដល់កូនទេ កូនអភ័ព្វណាស់ កូននៅជា

- ទេ មិនមែនអីចឹងទេនាងសម្លាប់ខ្លួនដោយសារនាងអន់ចិត្ត នឹងព្រេងវាសនានាងដែលត្រូវពេទ្យកាត់ដៃនាងមួយចំហៀង ដោយ គ្រោះថ្នាក់ក្នុងការធ្វើដំណើរជាមួយនឹងប៉ានាង គិតទៅមនុស្សអាក្រក់ មិនដែលទទួលបានផលល្អមកវិញទេ ! ចំណែកមីងសំអឿនក៏ដូច្នោះ ដែរ បងនឹងទៅរកខុសត្រូវឲ្យទាល់តែបាន !

- កុំអីបង !

- មិនបានទេកូនយ៉ា !

អ្នកស្រីឆ្លើយកាត់ !

- វាហ្នឹងអាក្រក់មួយចប់ ពេលដែលកូនបាត់ខ្លួននេះវាបញ្ចុក បន្សីរ៉ាវីកូនវាឲ្យបូរីសម្បើមណាស់ ម៉ាក់អ៊ំស្គាល់ក្រយៅវាតាំងពីដំបូង មកម៉្លេះ វាគ្មានជាប់សាច់ជាប់ឈាមអីជាមួយនឹងម៉ាក់អ៊ំទេ មនុស្ស របៀបនេះយកមកធ្វើជាដន្លងជាមួយម៉ាក់អ៊ំមិនបានទេ ! ម៉ាក់អ៊ំចាំ មើលកូនជាង១ឆ្នាំហើយមិនឃើញ ទើបម៉ាក់អ៊ំសម្រេចចិត្តដណ្តឹងនារី ឲ្យបូរី ព្រោះវាមានឫកពារបៀបកូនឯង កូនកុំគិតច្រើនទុករឿងនេះ ឲ្យបងឯងដោះស្រាយចុះ !

- តែខ្ញុំមិនត្រឡប់ទៅនៅជាមួយនឹងលោកសុជាតិវិញទេម៉ាក់ អ៊ំ កូនខ្មាសគេណាស់ !

- វាមិនសមមែន បូរីឯងមិនគួរណាជំរុញប្អូនឲ្យទៅនៅជា

មួយនឹងគេសោះ !

- តែគេមានគុណលើអូនយ៉ាណាស់ បើកុំតែគេអូនយ៉ាមិនដឹងទៅជាយ៉ាងណាទេម៉ាក់ ! ឥឡូវកូនផ្ដល់យោបល់មួយទៀត កូននឹងនាំអូនយ៉ាឲ្យទៅជួបគេថ្មីៗ ថាបើគេពិតជាស្រឡាញ់អូនយ៉ាមែនគេនឹងចូលស្ដីដណ្ដឹងហើយ ឬក៏ឃាត់ឲ្យនៅទីនោះ !

យោបល់នេះលោកស្រីហាក់ដូចជាយល់ស្រប តែម៉ូលីយ៉ានាងហាក់ដូចជាមិនពេញចិត្តសោះ នាងប្រាប់ទៅគេវិញ :

- ចាំខ្ញុំប្រឡងហើយសិនទៅ !

- មិនអីទេ អូនបានចូលរៀនវិញពិតជាប្រសើរណាស់ គេពិតជាមនុស្សមានឧត្ដមគតិល្អមែនន !

អ្នកសរសើរសុជាតិនៅចំពោះមុខនាង ធ្វើឲ្យស្រីមិនហ៊ានហាមាត់និយាយអ្វីតទៅទៀត ។

យើងក្រឡេកមើលមកចិន្ដាវិញម្ដង ក្រោយពេលដែលកំលោះសុផាន់ណាត្រឡប់ទៅវិញ នាងចូលទៅធ្វើម្ហូបឆ្អិនបាយឆ្អិនសម្លហើយនៅមិនឃើញម៉ូលីយ៉ាមកវិញទៀត កញ្ញាកើតក្ដីសង្ស័យចូលទៅក្នុងផ្ទះ ស្រីប្រហោងពោះធ្លុងព្រោះបាត់វ៉ាលីសនិងសម្លៀកបំពាក់ម៉ូលីយ៉ាអស់រលីង នាងប្រទះឃើញសំបុត្រតូចមួយនៅលើតុ !

..........................

*ចំពោះចិន្តា !*

*ចិន្តា ឯងល្អនឹងខ្ញុំណាស់ ឯងមានសន្តានចិត្តមិនខុសពីចិន្តាមិត្ត ខ្ញុំនៅឯសៀមរាបនោះទេ តែខ្ញុំជាមនុស្សស្វែងរកសេចក្ដីសុខមិនបាន ខ្ញុំលាមិត្តហើយ បើសិនណាជាខ្ញុំបានសេចក្ដីសុខ យើងប្រាកដជាបាន ជួបគ្នានៅពេលប្រឡង ពេលនោះយើងពិតជាបានជួប !*

*ម៉ូលីយ៉ា*

..............................

អានចប់នាងជ្រួញចិញ្ចើម នាងចាប់ផ្ដើមសង្ស័យទៅលើបងប្រុសនាង សុផាន់ណាមួយរំពេច គេប្រាកដជាធ្វើអីផ្ដេសផ្ដាសយ៉ាងណាទៅលើម៉ូលីយ៉ាជាមិនខាន បានជានាងនិយាយយ៉ាងនេះ មាណវីដើរចេញមកឈរនៅមាត់ទ្វារដោយក្ដីសញ្ជប់សញ្ជឹងគិតទៅដល់មិត្តជាពន់ប្រមាណ ។

១ខែកន្លងផុតទៅ មិនយូរប៉ុន្មានថ្ងៃបិទឈោះប្រឡងក៏បានមកដល់ គឺជាថ្ងៃដែលសុជាតិរង់ចាំដោយអន្ទះសា ពេលចេញពីធ្វើការអ្នកហួសទៅសាលាបន្តិច ពេលនេះគេទិញកូនឡានថ្មីមួយហើយ ថ្មើរនេះស្ងាត់ ណាស់គ្មានអ្នកណាមកមើលឈ្មោះទៀតទេ ! គេអាចមើលបានដោយស្រួលមិនពិបាកប្រជ្រៀតដូចពីពេលព្រឹកទេ អ្នកកំលោះខំផ្ទៀងឈ្មោះនាងដោយផ្ចិតផ្ចង់ ដង្ហើមអ្នកលោតញាប់ៗ ភ័យព្រួយ

ច្របូកច្របល់ចូលគ្នា បន្តិចក្រោយមកស្រាប់តែអ្នកញញឹមតែឯង បើសិនជាមាននរណាលបមើលគេច្បាស់ជាសើចស្លាប់ហើយ ។

សុជាតិបើករថយន្តត្រឡប់មកផ្ទះវិញ ទឹកមុខអ្នកហាក់ប្លែកខុសពីសព្វមួយដង គេយកម្ហូបទៅទុក ហើយត្រឡប់មកផ្លាស់សម្លៀកបំពាក់ ទើបចូលទៅពិនិត្យអ្នកជំងឺ អ្នកមានទឹកមុខរីករាយរហូតទាល់តែគេលាន់មាត់ថា :

- លោកគ្រូពេទ្យថ្ងៃនេះរីករាយណាស់ បែបប្រពន្ធគាត់វិលត្រឡប់មកវិញហើយមើលទៅ !

- មែនហើយ តាំងពីខ្ញុំមកកំដរអាកូនតូចខ្ញុំនៅទីនេះ ដូចជាមិនដែលឃើញប្រពន្ធរបស់គាត់ម្តងណាសោះ !

- ខ្ញុំឮថាប្រពន្ធគាត់ស្អាតណាស់ ឲ្យក្មេងល្អក់ហើយនៅរៀនទៀតផង !

---

ថ្ងៃប្រឡងបានឈានចូលមកដល់ ថ្ងៃនេះពេលដែលអ្នកប្រុសយើងចេញពីធ្វើការវិញ អ្នកមកចាំឃ្លាំមើលម៉ូលីយ៉ានៅក្បែរថ្នាក់ប្រឡង តែគេមិនចេញមកក្រៅទេនៅអង្គុយក្នុងឡានដោយគ្រាន់តែបើកកញ្ចក់បន្តិច ។ រថយន្ត កង់ ម៉ូតូ ចេញពីសាលាជាហូរហែតែអ្នកមិនបានចាប់អារម្មណ៍ទេ ភ្នែករបស់គេរំពៃរកមើលតែម៉ូលីយ៉ា ពេល

វេលាកន្លងផុតទៅ ភាពអ៊ូអរចេះតែស្ងាត់បន្តិចម្ដងៗ អ្នកប្រុសអស់សង្ឃឹមត្រឡប់មកផ្ទះវិញទាំងមុខស្រពោន អ្នកនឹកព្រួយខ្លាចក្រែងតែនាងដាក់ឈ្មោះប្រឡងហើយមិនមកប្រឡងក៏មិនដឹង ។ គួរឲ្យពិបាកណាស់ គេមិនដែលខ្វល់ពីសុខទុក្ខរបស់អ្នកណាដូចជានាងឡើយ អ្នកចេះតែគិតទៅដល់នាងគ្រប់ជំហានទាំងអស់ ។

ស្អែកឡើងអ្នកប្រុសបើកឡានមកចាំទីនោះទៀត អ្នកប្រុសហាក់ដូចជាចាប់អារម្មណ៍នឹងរថយន្តមីនីពណ៌ក្រហមមួយ ដែលបើកចេញយ៉ាងលឿន បុរសសង្ហាពាក់វ៉ែនតាជាអ្នកបើកហើយមាននារី១រូបនៅអង្គុយក្បែរនោះ ។ បើអ្នកមិនច្រឡំទេ គឺពិតជាម៉ូលីយ៉ាហើយ គេរហ័សបញ្ជារថយន្តតាមពីក្រោយភ្លាម ដោយមានមនុស្សច្រើនពេកគេមិនអាចប្រជ្រៀតទៅមុខបាន មកដល់ផ្លូវបត់អ្នកត្រឡប់មកវិញទឹកមុខស្ងួតចែស អ្នកចង់ស្គាល់បុរសដែលជូនឡាននាងអម្បាញ់មិញនេះ តើគេជានរណាប្ដីឬក៏មិនមែនទេ ?

- មិនមែនប្ដីទេ ព្រោះគេមានប្រពន្ធហើយ ឯគេក៏ដឹងថាម៉ូលីយ៉ាមានប្ដីហើយដែរ ដូច្នេះគេមិនអាចទាក់ទងគ្នាទៅកើតឡើយ ឬមួយក៏ជាសង្សាររបស់នាងទេ ? ពិតមែនហើយពីថ្ងៃមុននាងមានមិត្តប្រុសក្មេងហើយសង្ហាណាស់ សក់វែងបន្តិចគេជូននាងមកផ្ទះ ហ៊ឺ.. ខ្ញុំមិនគួរគិតពីនាងទៀតទេ នាងបានសេចក្ដីសុខហើយ បើខ្ញុំជួបមុខ

នាងក៏គ្មានចំណេញអីដល់នាងដែរ ក្រៅពីការលួកកករដល់សេចក្ដីសុខនាង តែខ្ញុំចង់ស្គាល់បុរសនោះ តើគេមានចិត្តល្អឬក៏ជាព្រាននារីទេ !

ស្អែកឡើងសុជាតិប្រថុយមកចាំម្ដងទៀត គឺជាថ្ងៃបញ្ចប់នៃការប្រឡង បេះដូងអ្នកដើរញាប់ៗនាយរង់ចាំឡានពណ៌ក្រហមនោះដោយចេញមកក្រៅ បើពិតជាម៉ូលីយ៉ាមែន តើនាងមានចិត្តគួរសមជាមួយនឹងអ្នកខ្លះដែរទេ ? រថយន្តដែលអ្នកកំពុងតែរង់ចាំនោះមកឈប់ក្បែរខ្លួនរបស់អ្នក បេះដូងគេដែលកំពុងតែដើរញាប់ បបូរមាត់ញ័រតិចៗកម្រើកឥតឮសូរសំឡេងអ្វីទេ អ្នកបើកភ្នែកសម្លឹងម៉ូលីយ៉ាហើយសម្លឹងបុរសដែលអ្នកមិនទាន់ស្គាល់នោះ ។

បុរសដែលអ្នកចង់ដឹង ដើរមកចាប់ដៃអ្នករលាក់ទាំងញញឹមក្នុងន័យត្រេកអរ អ្នកប្រុសហាក់ដូចជារសាយក្នុងចិត្តបន្តិចហើយ គេខំសម្រួលអារម្មណ៍ឲ្យនឹងនរ !

- សួស្ដីប្អូនសុជាតិ បងគឺបូរី !

អ្នកសម្លឹងមុខបូរីទាំងប្លែកនៅក្នុងចិត្តរកស្មានមិនត្រូវ ហើយមិនដឹងជាត្រូវតបទៅគេវិញយ៉ាងម៉េចដែរ បូរីនិយាយមកកាន់អ្នកថា

- ប្អូនកំពុងរង់ចាំអ្នកណាម្នាក់ដែលប្អូនត្រូវមកទទួលមែនទេ!

- បាទទេ !

គេឆ្លើយទាំងស្ទាក់ស្ទើរដោយលួចឱនមុខចុះ ភក្ត្រារាងក្រហម

ប្រឿង១ហាក់ដូចជាទទួលអារម្មណ៍ចម្លែក អ្នកដឹងថា នាងកំពុងតែអៀននឹងអ្នក នេះប្រហែលជានាងទៅរស់នៅជាមួយនឹងបូរីហើយ ឬមួយក៏នាងអៀន នឹងគេដោយនាងរត់ចោលគេ ។

បុរសភ្ញាក់ព្រើត ព្រោះបូរីអង្រួនដៃអ្នក :

- ខ្ញុំចង់ជួបប្អូននិយាយការមួយ តើប្អូនអនុញ្ញាតទេ ?

- បាទ មិនអីទេបងប្រុស !

បូរីងាកមកម៉ូលីយ៉ា !

- អូននៅចាំបងកន្លែងនេះហើយ !

បូរីនាំសុជាតិទៅអង្គុយលើបង់ក្នុងសាលា គេផ្ដើមសួរទៅកាន់សុជាតិមុន :

- ប្អូនជាអ្នកជួយសង្គ្រោះម៉ូលីយ៉ាឲ្យរួចពីក្ដីវេទនា បងសូមអរគុណប្អូនណាស់ លើលោកនេះពិតជាកម្រមានមនុស្សដែលមានសន្ដានចិត្តដូចជាប្អូនណាស់ បងសូមសរសើរដោយស្មោះ !

សុជាតិកាត់ប្រយោគបូរីភ្លាម :

- នេះជាការជួយគ្នាទៅវិញទៅមកយ៉ាងសាមញ្ញទេបងប្រុស !

- មិនសាមញ្ញទេ រឿងអស់ទាំងនេះ គឺម៉ូលីយ៉ាបាននិយាយប្រាប់បងអស់ហើយ ប្អូនប្រាកដជាអន់ចិត្តនឹងម៉ូលីយ៉ាដែលលួចរត់ចេញពីផ្ទះអូនមែនទេ ?

- បាទទេ ! ខ្ញុំគ្មានចិត្តនឹកខឹងនឹងនាងទេបង ខ្ញុំនឹកស្ដាយនូវកំហុសរបស់ខ្ញុំតែប៉ុណ្ណោះ ព្រោះខ្ញុំធ្វើអំពើមិនសមរម្យចំពោះរូបនាងដែលជានារីភេទ ខ្ញុំជាមនុស្សតម្រេកបំផុតសូមបងកុំសរសើរខ្ញុំអី !

- ទេ ! ទេ ! ប្អូនយល់ច្រឡំហើយ ម៉ូលីយ៉ាមិនបានវាយតម្លៃប្អូនជាមនុស្សអាក្រក់ទេ មកទល់ពេលឥឡូវនេះនាងយល់នូវកំហុសរបស់នាងដែលរត់ចោលប្អូនជាអ្នកមានគុណលើនាង នាងចង់មកសុំទោសប្អូនហើយនឹងរស់នៅជាមួយប្អូនដូចដើមវិញ តែនាងនឹកខ្មាសអៀននឹងប្អូន ព្រោះនាងជាស្រីខ្វះសេចក្ដីក្លាហាននឹងសារភាពកំហុសទាំងនោះ !

- តែ... រស់នៅជាមួយខ្ញុំយ៉ាងដូចម្ដេច បើ...

បូរីគ្រវីក្បាលញាប់ស្ទេក !

- មិនមែនទេ បងគឺជាបងប្រុសរបស់នាងទេ ! យើងបានរាប់អានគ្នាដូចជាបងប្អូនបង្កើតទៅហើយ ព្រោះបងមានប្រពន្ធមិនអាចបង្កើតសេចក្ដីស្នេហាចំពោះនាងម្ដងទៀតបានទេ សូមប្អូនមេត្តានាងផង នាងចង់សាងអំពើល្អជាមួយប្អូនឲ្យបានច្រើន !

- ខ្ញុំមិនចិត្តអាក្រក់ទេ ខ្លាចតែនាងមិនព្រម !

- នាងប្រាកដជាព្រម ឲ្យតែប្អូនហាមាត់និយាយពីរឿងនេះតែមួយគត់នាងនឹងទៅភ្លាម !

សុជាតិសញ្ជឹងគិតបន្តិចអ្នកក៏យល់ស្របតាមសម្ដីបូរី ការពិត នោះក្នុងចិត្តវាជ្រួលច្របល់មិនតិចទេ កុំថាឡើយឲ្យត្រឹមអ្នកហៅនាងមួយម៉ាត់ ទោះបីជាអង្គុយអង្វរឲ្យបាន៣ថ្ងៃក៏អ្នកសុខចិត្តដែរ ។ តែអ្នកមិនចង់បង្ហាញពីទឹកចិត្តត្រេកអរនៅចំពោះមុខបូរី ព្រោះបូរីវាយតម្លៃអ្នកថា ជាមនុស្សមិនកើតទៅវិញ ។

អ្នកទាំងពីរត្រឡប់មកកាន់រថយន្តវិញ តែបូរីបង្គាប់ឲ្យសុជាតិដើរទៅមុនអ្នកដើម្បីនិយាយជាមួយនឹងម៉ូលីយ៉ា ចំណែកខ្លួនគេធ្វើជាបត់ជើងហើយដើរទៅបង្កន់។ ម៉ូលីយ៉ាអង្គុយក្នុងឡានទាំងមុខក្រៀមស្រពោនចិត្ត ពួកគេចេញទៅផ្ទះស្វាត់អស់ទៅហើយ បងបូរីនាងមិនទាន់ឃើញត្រឡប់មកវិញទៀត តើគេពិគ្រោះគ្នាយ៉ាងម៉េចទៅដែរ ? គិតមកដល់ត្រឹមនេះស្រីភ្ញាក់ព្រើត ព្រោះសុជាតិដែលនាងកំពុងតែគិតនោះដាក់ដៃលើកញ្ចក់ឡានដែលនាងអង្គុយ ស្រីមិនហ៊ានមើលមុខគេទេ នាងឱនចុះទាំងមិននិយាយស្ដីអ្វីទាំងអស់ ។

- ម៉ូលីយ៉ា ឈប់ខឹងនឹងបងទៅ អូនត្រូវទៅនៅជាមួយបងវិញណាអូន តើអូនសុខចិត្តដែរទេ ?

កែវល្អត្រវីក្បាលមួយៗ មុខនាងស្ងួតណាស់ អ្នកប្រុសដកដង្ហើមធំយ៉ាងតានតឹង គេធ្វើមុខស្ងួតហើយសម្លឹងទៅឆ្ងាយ នារីលួចមើលមុខគេម្ដង នាងគ្មានបំណងបដិសេធយ៉ាងនេះទេ ហេតុអ្វីក៏នាង

ធ្វើយ៉ាងនេះទៅវិញ ? ស្រីខាំបបូរមាត់ក្តៅចិត្តនឹងខ្លួនឯងដែលខ្វះភាពក្លាហានហួស គេជាអ្នកមានគុណលើនាង គួរណាស់នាងបំពេញតាមបំណងគេ តែនេះនាងមិនដែលធ្វើឲ្យគេបានសប្បាយចិត្តម្តងណាឡើយ បុរសងាកមើលមុខនាងដោយអស់សង្ឃឹម ហើយដើរទៅកាន់រថយន្តរបស់គេវិញ ។

ថ្វីបើអ្នកបានសម្រេចចិត្តថា ឲ្យនាងព្រមទៅនៅជាមួយអ្នកវិញ ទោះជាចំណាយពេលពាថ្ងៃក៏ដោយក៏អ្នកសុខចិត្តដែរ តែពេលនេះអ្នកហាក់ដូចជាធ្វើទៅមិនរួច ។ រថយន្តទាំងពីរបរទន្ទឹមគ្នានៅលើដងវិថីតែមួយ ដែលបូរីគេលួចគយគន់ស្រីដែលមានទឹកមុខស្រពាប់ស្រពោន នាយសួរទៅនាង :

- អាយ៉ាអូន អូនព្រមទៅនៅជាមួយគេវិញឬ គេបានសួរអូនពីអីខ្លះដែរ ?

- ចាសសួរ !

- ចុះអូនព្រមដែរទេ ?

- អូនមិនហ៊ានឆ្លើយទេបង មកពីអូនឆ្លើយមិនរួច ហេតុអីក៏បងជំរុញអូនខ្លាំងម្ល៉េះ ឬមួយក៏ទើសទាល់នឹងខ្ញុំដែលរស់នៅលើផ្ទះបងរាល់ថ្ងៃ ពេលប្រឡងជាប់ខ្ញុំនឹងចេញពីទីនេះហើយ !

- កុំនិយាយអ៊ីចឹង !

អ្នកយកដៃខ្ទប់មាត់នាងហើយបន្តទៀត !

- បងចង់ឲ្យអូនរស់នៅជិតបងជានិច្ច តែដើម្បីសុភមង្គលអូន បងត្រូវតែលះបង់ គេថាស្នេហាពិតត្រូវហ៊ានលះបង់ យើងត្រូវតែយល់ថាអ្វីដែលយើងចង់បាន យើងប្រាថ្នាហើយមិនបានដូចបំណង យើងត្រូវតែពេញចិត្ត អូនយល់ទេថា សុជាតិគេស្រឡាញ់អូនណាស់ គេទទួលកំហុសនៅចំពោះមុខបង នូវអំពើមិនសមរម្យដែលគេបានធ្វើចំពោះអូននេះ មកពីគេស្រឡាញ់អូន ល្អខុសគេផង តើអ្នកណាទៅឈ្នះអង្គុយទប់ចិត្តពុះកញ្ជ្រោលបាន ឈប់ខឹងនឹងគេទៅគេជាមនុស្សល្អណាស់ រឿងដែលអាក្រក់អូនត្រូវតែបំភ្លេចចោល អូនត្រូវតែផ្តើមកសាងជីវិតជាថ្មីដែលគ្មានភាពក្រេវក្រោធ !

នាងឱនភ័ក្ត្រចុះស្តាប់ការពន្យល់របស់បងប្រុស ទឹកមុខនាងលែងស្រពោនដូចមុនប្រែទៅជាក្រហមប្រឿងៗ រហូតមកដល់ផ្ទះអ្នកកំលោះសុជាតិគេអញ្ជើញឲ្យចូលទៅក្នុងផ្ទះ តែគេប្រកែកថា :

- ដល់ម៉ោងបងទៅយកប្រពន្ធបងនៅកន្លែងធ្វើការហើយ ចាំថ្ងៃក្រោយចុះ !

គេងាកមកម៉ូលីយ៉ាម្តង !

- អាយ៉ា អូននៅជាមួយគេហើយ អូនត្រូវរក្សាចិត្តថ្លើមឲ្យនឹងន កុំឆេវឆាវពេកបងលាហើយនៅឲ្យបានសុខណា៎ ! ហើយបង

ឧស្សាហ៍នាំនារីនិងប៉ាម៉ាក់មកលេងនឹងអូន !

គេចាប់ដៃនាងមកច្របាច់យ៉ាងខ្លាំងមាណវីកាន់ដៃគេវិញ !

- បងលាហើយណាំ !

អ្នកស្រែកប្រាប់សុជាតិ :

- សុជាតិ បងលាសិនហើយមិនយូរទេបងនឹងមកលេងជាមួយអូនមិនខាន !

- បាទ អញ្ជើញបង !

អ្នកនិងម៉ូលីយ៉ាដែលសម្លឹងគេបើករថយន្តចេញទៅទាំងភ្លឹក !

- អូនស្រឡាញ់បូរីណាស់ គួរឲ្យស្ដាយ... មែនទេ ?

យុវជនបោះជំហានមួយៗតម្រង់មកស្រស់ស្រី នាងមិនហ៊ានមើលមុខសុជាតិទេ អ្នកដឹងណាស់ទៅហើយថា នាងខ្មាស គេដឹកដៃនាងឲ្យចូលទៅក្នុងផ្ទះ អ្វីៗនៅទីនេះប្លែកទាំងអស់ មិនស្វាត់ដូចមុនទេ ម៉ូលីយ៉ាខំសម្លឹងទិដ្ឋភាពនៅជុំវិញខ្លួននាងគេម្នាក់ៗខំដក កលួចមើលនាង សំឡេងខ្សឹបខ្សៀវរបស់អ្នកដែលមកកំដរអ្នកជំងឺបានហើរមកប៉ះនឹងត្រចៀកនាង !

- ប្រពន្ធលោកគ្រូពេទ្យស្អាតណាស់ អីចឹងបានជាប៉ុន្មានថ្ងៃនេះដែលអ្នកស្រីមិននៅ លោកគ្រូមានមុខស្ងួតណាស់ !

ស្រស់ស្រីនាងដើរហួសទៅ ហើយមកដល់មុខបន្ទប់ស្រី នាង

ស្រឡាំងកាំងឈរធ្មឹង សុជាតិរហ័សប្រាប់ :

- អូនត្រូវទៅនៅខាងលើវិញ បន្ទប់អស់នេះបងដាក់អ្នកជំងឺអស់ហើយ បន្ទប់បងក៏ត្រូវផ្លាស់ទៅនៅខាងលើវិញដែរ មិនអាចនៅទីនេះបានទេ !

អ្នកប្រុសដឹកដៃនាងឡើងមកជាន់ខាងលើ ដែលនៅក្នុងបន្ទប់មានរូបស្រីមួយផ្ទាំងយ៉ាងធំ ដាក់តាំងដែលនាងអង្គុយនៅលើវាលស្មៅកាន់ផ្កាមួយទងយ៉ាងស្រស់ញញឹម ! សុជាតិវាចាទៅកាន់ស្រី :

- អាយ៉ា... អូនចូលផ្លាស់សម្លៀកបំពាក់ទៅ !

នាងមិនទាន់ចូលភ្លាមទេ ស្រីឈរទ្រើងដោយអារម្មណ៍រិះគិត អ្នកប្រុសវាចាបន្ត :

- សម្លៀកបំពាក់អូនមានខ្លះដែរទេតើ បងទិញបានពីរបីកំប្លេថែមទៀតដែរ !

មាណវីឈានជើងដើរមួយៗចូលទៅក្នុង នាងសម្លឹងមើលទៅសម្លៀកបំពាក់ដែលនៅក្នុងទូខោអាវ សុជាតិដាក់នៅក្នុងទូជាមួយនឹងគេ តើគេគិតយ៉ាងម៉េចបានជាយកមកដាក់រួមគ្នាយ៉ាងនេះទៅវិញ? បែបស្មានថានាងព្រមនៅក្នុងបន្ទប់ជាមួយហើយមើលទៅ ! នាងចាប់ផ្តើមផ្លាស់សម្លៀកបំពាក់ អ្នកបែរមុខចេញមួយសន្ទុះទើបគេដើរចូលមកដែរ ម៉ូលីយ៉ាបម្រុងដើរចេញទៅហើយ តែឃើញគេចូលមកនាង

ក៏ឈរទ្រឹងព្រោះចង់សួរគេពីរបីម៉ាត់ដែរ អ្នកប្រុសផ្ដើមសួរនាងមុន :

- អូនសើចអីអម្បាញ់មិញនេះ ?

- សើចដោយហួសចិត្ត ! ( នាងឆ្លើយយ៉ាងខ្លី )

សុជាតិមិនប្រកាន់នឹងសម្ដីនាងទេ គេយល់ថា ស្រីមានចិត្តស្រាលដូចសំឡី នាងចូលចិត្តងរង៉ក់ច្រើនធ្វើឲ្យគេអង្វរ !

- ហួសចិត្តពីរឿងអី អូនអង្គុយចុះមកនិយាយគ្នាសិន !

គេទាញដៃនាងឲ្យអង្គុយលើពូកក្បែរ កញ្ញាធ្វើមិនដឹង នាងសម្លក់គេទាំងដៃរបស់អ្នកប្រុសចាប់នាងជាប់ !

- អូននិយាយទៅមើល ហួសចិត្តពីរឿងអី អូនអស់សំណើចពីរោះណាស់ សើចពីរោះអស្ចារ្យ តែចំពោះមុខបងអូនមិនដែលសើចឲ្យបងមានកម្លាំងម្ដងណាទេ !

- លោកស្មានថាខ្ញុំជាមនុស្សឆ្កួតឬ ?

- មិនមែនទេ អ្នកណាហ៊ានចោទអូនដល់ថ្នាក់ហ្នឹងនោះ !

- ហ៊ឹះ !

នាងគ្រហឹមចុងច្រមុះហើយដៀងភ្នែកសម្លក់ទៅគេថ្មែ ! នរៈពោលយ៉ាងល្ងើយ :

- ហេតុអីក៏កាចម្ល៉េះទេព្រះអើយ !

- បើមិនកាចខ្លះទេ លោកពិតជាមើលងាយខ្ញុំទៀតហើយ !

- មើលងាយ !

គេធ្វើមុខស្លូតសម្លឹងមុខនាង !

- បងគ្មានគំនិតមើលងាយអូនបន្តិចណាទេ ទាំងនោះមកពីបងវារំជើបរំជួលចិត្តពេក ដោយសារតែសម្រស់របស់អូនហ្នឹងណាំ !

ខ្ញិលស្តាប់ពាក្យរបស់គេច្រើននាងដើរចេញមកឈរនៅយ៉ខាងក្រៅធ្វើព្រងើយ ! បុរសហួសចិត្តខ្ញិលគិតច្រើន គេចុះមកចាក់ថ្នាំឲ្យអ្នកជំងឺ រួចហួសទៅទិញម្ហូបតែម្តង ។ ពេលត្រឡប់មកពីផ្សារវិញអ្នករៀបចំម្ហូបបាយជាស្រេច គេគ្របចានយ៉ាងមានរបៀបទើបឡើងទៅខាងលើ ស្រស់ស្រីនាងកំពុងតែជក់អារម្មណ៍នឹងសៀវភៅពេទ្យរបស់គេ អ្នកកំលោះឈរមើលពីក្រោយខ្នងនាង ម្រាមដៃដ៏ស្រឡូនផ្ទាត់ទំព័រសៀវភៅទៅខាងមុខយ៉ាងញាប់ស្មេក នាងឈប់ដូចភ្ញាក់នូវត្រឹមចំណងជើងរបស់ " វិធីការពារមិនឲ្យមានកូន " នាងមើលវាម្តងទៀតស្រីដូចជាចាប់អារម្មណ៍ខ្លាំងនឹងវិធីការពារដោយប្រើថ្នាំ... សុជាតិប្រែទឹកមុខមិនចេះចប់ អ្នកឆ្ងល់នឹងនាងដែលចង់ដឹងពីបាតុភាពនេះ កុំឲ្យនាងចាប់អារម្មណ៍ខ្លាំងពេកអ្នកគ្រហែមបន្តិច ស្រីភ្ញាក់ព្រើត នាងបិទសៀវភៅទុក ក្រោកដើរទៅក្រៅធ្វើមិនដឹង ។ អ្នកប្រុសទឹកដូចជាហួសចិត្តពេក ដើរតាមក្រោយនាងតិចៗ !

- អាយ៉ា តោះទៅញុំាបាយអូន !

- មិនឃ្លានទេ !

- អូនមិនត្រូវរៀនអត់បាយអីចឹងទេ វានាំឲ្យខូចសុខភាពអូនណាំ កាលណាអូនញ៉ាំមិនបានទៀងទាត់បែបនេះ !

- ខូចអីក៏ខូចទៅ សព្វថ្ងៃនេះវាគ្មានអ្វីល្អទេ វាខូចខ្ទេចខ្ទីអស់ទៅហើយ !

- ម៉េចក៏បងមើលទៅមិនឃើញខូចខាតត្រង់ណាសោះអីចឹង ឬក៏គ្រូពេទ្យបងនេះភ្នែកស្អុយទៅហើយ !

នាងនៅស្ងៀមលែងឆ្លងឆ្លើយ អ្នកប្រុសដកដង្ហើមធំដោយតឹងចិត្តពេក ព្រោះនាងដូចជាពិបាកយល់ណាស់ ។

ក្រោយពេលដែលស្រស់ស្រូបហើយ គេបបួលនាងចេញទៅក្រៅដើរកម្សាន្ត ។ អ្នកកំលោះបញ្ជារថយន្តចេញផុតពីមុខផ្ទះបានបន្តិច ស្រាប់តែមានរថយន្តស្ព័រពណ៌ក្រហមមួយគ្រឿងផ្ទុកបុរស៨នាក់ច្រូងច្រាងចូលមកដល់ល្មម ពួកនេះបញ្ជារថយន្តទៅឈប់នៅមាត់ផ្លូវ ហើយនាំគ្នាចុះព្រូពីលើឡានក្នុងដំណើរយ៉ាងខែងសំដៅចូលមកក្នុងផ្ទះដោយមិនមានការអនុញ្ញាតពីនរណាទាំងអស់ ។

អ្នកជំងឺនិងអ្នកដែលមកកំដរអ្នកជំងឺធ្វើភ្នែកស្លឹមព្រោះមានការភិតភ័យដោយមិនដឹងមូលហេតុ ពួកអាជើងសក់ប្រះស្មាទាំងនោះ វាដើរចូលមកយ៉ាងគឃ្លើន លើកកាំភ្លើងសម្លុតស្រីពាក់កណ្តាលវ័យម្នាក់

ដែលកំពុងអង្គុយបក់ផ្លិតឲ្យកូន ធ្វើឲ្យគាត់ញ័រខ្លួនដូចកូនសត្វ ។

- អាដុកទ័រសុជាតិវាទៅណាហើយ ?

-ចាស...អឺ...គាត់ទើបនឹងចេញទៅដើរលេងជាមួយនឹងប្រពន្ធគាត់មុននេះទេ ចាស !

- និយាយតែផ្ដាស មីឯងឯងកុហកខ្ញុំហើយ វាគ្មានប្រពន្ធទេ !

- ចាស ទេ គឺជាប្រពន្ធគាត់ពិតមែនណាំលោកក្មួយ !

- មីឯងឯងច្រឡំទេដឹង !

- មិនច្រឡំទេ គ្រាន់តែមីឯងមិនដឹងថាលោកដុកទ័រនោះឈ្មោះអីដែរទេ តែគាត់មានប្រពន្ធពិតមែនណាំ !

- យើងច្រឡំទេដឹងអាខ្នា !

- ផ្ទះហ្នឹងហើយមិនច្រឡំទេ តោះយើង... ឡើងទៅលើ !

ពួកវានាំគ្នាឡើងទៅលើអាម្នាក់ស្រមូមក៏ពោលឡើង :

- ថ្ងៃនេះអញដឹងច្បាស់ណាស់ អាគាត់ហ្នឹងវាមិននៅផ្ទះទេ គឺប៉ះថ្ងៃយាមតែប៉ុណ្ណោះ ច្បាស់ជាបានអញទៀតហើយអ្នែងកុំឆោតពេកអ្នកស្រីគន្ធានិយាយថា ទោះជាក្រមុំឬមិនក្រមុំឲ្យតែយកទៅឲ្យគាត់នឹងបានថ្លៃជាមិនខាន !

អាម្នាក់ទៀតតប :

- អឺ បែបដូចជាមីងនេះនិយាយមែនហើយនាងនោះប្រហែល

ជារៀបការរួចហើយមែនណាំ !

- គ្មានការឯណាទេ បើវាលេងជាល្បែងអញជឿខ្លះ អាតាត់នេះមិនមែនជាមនុស្សត្រឹមត្រូវប៉ុន្មានទេ ធ្លាប់ចូលកន្លែងបងគន្ធាម្តងពីររួចមកហើយ អញចាំមុខច្បាស់ណាស់ !

- ពិតមែនហើយ នាងម៉ូលីយ៉ាស្ពីគេនោះធ្លាប់រស់នៅកន្លែងបងគន្ធាដែរទេតើ !

- កុំនិយាយឆ្កួតបើនៅលើដៃគាត់មែន មិនងាយរួចចេញមកវិញឡើយ ! យាយប៉ិគន្ធានោះប៉ិនប្រើល្បិចណាស់ អ្នែងមើលច្រឡំទេដឹង !

- នែវ៉ឺយ ផ្ទះបើកភ្លើងហើយអត់ចាក់សោទេ ប្រាកដជាមីស្រីនោះវានៅក្នុងនេះហើយ មីងនេះហ៊ានកុហកយើងផង បាញ់ចោលតែម្តងទៅ !

- នែ៎ អាក្ពក់បិទភ្លើងភ្លាមទៅ !

- កុងតាក់មិនដឹងនៅឯណាទេវ៉ឺយ !

- សាំច្រើនដល់ហើយ កាត់ខ្សែភ្លើងចោលទៅវាស្រេចទៅហើយ វារត់មិនរួចទេ គ្នាយើងមួយទ័ពឯណោះ !

- មិនខ្លាចវារត់ទេ តែខ្លាចវាស្រែកពិតជាបែកការណ៍ហើយ !

- ឲ្យឆាប់ទៅកុំឲ្យមានរឿងវ៉ឺយ បើគេចាប់បានតែម្នាក់ច្បាស់

ជាជាប់គុកមួយពូជហើយ !

- អាខ្នាំអ្នែងទៅជួយយាមផ្លូវអាមួវផង !

- មិនបាច់ទេ ឲ្យអាមួវវានៅតែម្នាក់ឯងបានហើយ !

- កុំមាត់ខ្លាំងពេកក្រែងវាឮទៅ !

ពួកវាច្របាច់ពិលខ្មែងខ្វាត់ពេញផ្ទះតាំងពីយ៉ខាងក្រៅ រហូតមកដល់ខាងក្នុងហើយមិនឃើញវាក៏ចូលទៅជាន់លើទៀត ។ ពួកវាចាប់ផ្ដើមរុះរើរកមាសប្រាក់ព្រោះមិនឃើញមនុស្ស ដើម្បីកុំឲ្យសិយវាកក្កូរកកាយទាំងអស់គ្មានសល់ !

- ឆាប់បន្តិចទៅប្រយ័ត្នវាមកទាន់ណា៎ !

- មិនបាច់ភ័យទេ អាតាត់នោះវាមិនចេះចាក់កាប់ទេ វាចេះតែចាក់ថ្នាំប៉ុណ្ណោះ !

- ឆាប់ជួយប្រមូលអីវ៉ាន់ឲ្យលឿនទៅ !

ពួកចោររុករើគ្មានចន្លោះ អ្នកជំងឺនិងអ្នកកំដរភ័យស្លន់ស្លោភ្ញែកសតែរៀង១ខ្លួន អ្នកគ្រុនចាញ់ក៏លែងចង់ញាក់ទៀតដែរ ខ្លះអុជធូបបន់ស្រន់យំយែកតែរៀងខ្លួន !

យើងក្រឡេកមើលមករថយន្តពណិសដែលបូរី និងមិត្តគេបើកនៅលើផ្លូវថ្នល់ម្ដងវិញ មិត្តរបស់គេជាអធិការប៉ូលីស១រូបរបស់ក្រុមមានសមត្ថកិច្ចខាងស៊ើបអង្កេត ។ អ្នកប្រុសបូរីបម្រុងនឹងយកវ៉ាលីស

មកឲ្យម៉ូលីយ៉ា តែដោយជួបនឹងសុវណ្ណនៅតាមផ្លូវក៏បបួលមកតែម្តង ពេលមកជិតដល់ផ្ទះរបស់សុជាតិ អ្នកប្រុសចាប់អារម្មណ៍នឹងឡានស៊្តែរពណ៌ក្រហមដែលចតនៅខាងមុខផ្ទះសុជាតិ ធ្វើឲ្យគេមានការសង្ស័យណាស់ដោយមានបុរសសក់វែងម្នាក់ នៅអង្គុយយាមខាងមុខផ្ទះផងនរៈបញ្ឈប់រថយន្តង៉ក់ក្បែររបងឆ្ងាយពីផ្លូវប្រហែលជា១០០ម អាម៉ូរយាមផ្លូវមិនចាប់អារម្មណ៍ឡើយ វាដឹងថាសុជាតិមិនមានរថយន្តនេះទេ ហើយឡានតូយ៉ូតាសនេះក៏មិនមែនជារបស់ក្រសួងមានសមត្ថកិច្ចទៀត ដូច្នេះហើយបានជាវាអង្គុយស្ងៀមដដែល ។

យើញមិត្តឈប់ដូច្នេះ សុវណ្ណក៏សួរឡើង :

- ឯងឈប់ឡានមានការអីបូរី ?

- ឡានក្រហមនេះ និងមនុស្សម្នាក់នោះគួរឲ្យសង្ស័យណាស់សុវណ្ណ !

- អ៊ុំ ផ្ទះលោកគ្រូពេទ្យសុជាតិទេតើ ! ( សុវណ្ណឧទាន )

- ក៏ជាផ្ទះប្អូនស្រីគ្នាដែរ !

ចប់វាចាគេក៏បត់ឡានទៅក្រោយវិញ !

- ឯងទៅណាវិញហ្នឹងបូរី ?

- យើងចូលផ្លូវក្រោយខាងណោះវិញ បែបមានរឿងហេតុអីមិនស្រួលហើយទេដឹង ដូចឯងដឹងស្រាប់ហើយ ប៉ុន្មានថ្ងៃនេះឡាន

ស្ព័រពណ៌ក្រហមនេះចាប់កូនក្រមុំគេទាំងថ្ងៃ សុវណ្ណឯងមិនបានដឹងទេ ឬ ក្រែងឯងជាប៉ូលីសមែនទេ ?

- គិតទៅពួកយើងដូចជាខ្វះសមត្ថភាពបង្ក្រាបពួកនេះណាស់ ពេលនេះពួកវាកាន់តែខ្លាំងដៃណាស់ហើយ !

- មកពីសង្គមនេះពុករលួយខ្លាំងពេក !

មកដល់ម៉ោង៩ទៅហើយផ្ទះដែលនៅជិតផ្ទះសុជាតិ គេសើចសប្បាយអ៊ូអរនៅឡើយ លុះឃើញរថយន្តចូលមកដល់ គេទាំងអស់នាំគ្នាដកករហង់មើលមកអ្នកទាំងពីរដែលចុះពីលើរថយន្ត !

នារីម្នាក់ដែលបីកូនស្រីតូចមួយនិយាយឡើង :

- អ៊ូ លោកបូរីទេតើប៉ា !

- អញ្ជើញអង្គុយក្មួយបូរី ក្មួយមានការអីដែរ លោកក្មួយអញ្ជើញអង្គុយសិនមក !

- បាទ មិនអីទេលោកអ៊ំ ! ខ្ញុំចង់ចូលទៅផ្ទះខាងណោះបន្តិចបែបមានការអីមិនស្រួលហើយលោកអ៊ំ លោកអ៊ំប្រញាប់បិទទ្វារទៅខ្លាចមានរឿងអីកើតឡើង !

- តែលោកគ្រូពេទ្យនោះ និងប្រពន្ធទើបតែនឹងចេញទៅមុននេះទេតើ ប្រហែលជាមានអ្នកណាមកអុកឡុកទេដឹង !

- ពិតជាមានពួកជើងឆើតវាចូលមកអុកឡុកផ្ទះគាត់មែនណាំ

លោកពូ ! លោកពូឆាប់បិទទ្វារទៅក្រែងលោមានហេតុមិនស្រួលកើតឡើងណា៎ !

ពួកគេនាំគ្នាបិទទ្វារសម្ងំស្ងាត់ឈឹង ។

បុរសទាំងពីរផ្ដោះរបង ចូលទៅខាងក្នុងជាមួយនឹងវាំចារបស់បូរីបន្ទឹទៅកាន់សុវណ្ណ :

- សុវណ្ណឯងគួរតែឲ្យដំណឹងទៅក្រសួងរបស់ឯងផងទៅព្រោះតាមគ្នាមើលទៅគ្នាវាមិនតិចទេ ក្រែងយើងពិបាកទប់ទល់ជាមួយណា៎

- ចាំចាត់ការអាអ្នកយាមនោះសិនទៅ !

ពួកគេចូលមកចាត់ការជនពាលជាបន្ទាន់ ព្រមគ្នានោះរថយន្តរបស់ប៉ូលីសក៏មកដល់ល្មមដែរ មួយស្របក់ក្រោយមកគេក៏ចាប់បានពួកទាំងនោះបញ្ចូលទៅក្នុងឡានជាមួយនឹងឡានរបស់សុជាតិមកដល់ដែរ ! អ្នកប្រុសបើកភ្នែកធំៗមើលទៅពួកប៉ូលីស តែបូរីក៏ស្រដីមុន :

- សុជាតិ ផ្ទះរបស់ប្អូនត្រូវចោរចូលប្លន់ណា៎ តែបងបានចាត់ការរួចរាល់អស់ហើយ ប្អូនឡើងទៅរៀបចំអីវ៉ាន់ទៅបងមានការទៅកាន់ប៉ុស្តិប៉ូលីសសិន !

ម៉ូលីយ៉ាភ័យឡើងភ្នែកសស្លាំង នាងសម្លឹងមុខបូរីកំពុងរៀបរាប់ទាំងដង្ហើមញាប់ៗ :

- ហេតុអីក៏បងដឹងរឿងនេះទាន់ ?

www.lovekhmer.com

- បងបម្រុងយកវ៉ាលីសខោអាវនិងសៀវភៅមកឲ្យអូន តែចៃដន្យឃើញឡានក្រហមនោះក៏សង្ស័យ ដោយមានអធិការមកជាមួយដែរ បងក៏តាមដានរឿងនេះតែម្តងទៅ !

- ចុះបងបានអីជិះទៅវិញ ?

- ឡានបងទុកនៅជិតនេះទេ !

គេសម្លឹងមើលម៉ូលីយ៉ាបន្តិចក៏ដើរចេញទៅ គេទាំងពីរនាំគ្នាឡើងមកលើផ្ទះឃើញរបស់របររាយប៉ាយ និងខ្សែភ្លើងដាច់អស់ ក៏រៀបចំសាជាថ្មីឡើងវិញ ។

ខ្យល់រាត្រីបក់មកត្រសៀកៗ មាណវីគេងលក់ដោយមិនបានដឹងថាបុរសម្នាក់កំពុងតែបោកបក់កណ្តាលរាត្រីស្ងាត់សូន្យនោះទេ ភ្លឺច្បាស់ហើយ ម៉ូលីយ៉ាភ្ញាក់ក្រញាង ព្រោះខ្លួននាងស្ថិតនៅក្នុងរង្វង់ដៃគេនាងភ័យញ័រដូចកូនសត្វ !

- លោកឯងចំជាផ្តេសផ្តាសណាស់លែងខ្ញុំភ្លាមទៅ ! ខ្ញុំស្រែកឲ្យផ្អើលគេឥឡូវហ្នឹង !

- អូនមិនបាច់ខ្មាសអីទេ នរណាក៏ដឹងថាអូនជាប្រពន្ធរបស់បងដែរ

- ហ៊ឺះ ! លែងខ្ញុំទៅ លោកឯងនេះថ្លើមធំណាស់ !

នរៈខ្សឹបដាក់ត្រចៀកស្រីតិច ៗ :

- ទោះជាតួអង្គអ្នករក្សាសីលណា ក៏មិនអាចទប់ចិត្តលើសពីបងបានដែរ បើអូនឯងគេងឱបបងយ៉ាងស្អិតបែបនេះទៅហើយ បើបងមិនឱបវិញវាដូចជាមិនសម ឬមួយក៏ថាបងនេះដាច់ធម៌មេត្តាពេកមិនថាអ៊ីចឹងឬ ?

ក្ដាញ់ណាស់សម្ដីគេមិនដែលទាល់ម្ដងណាសោះ ស្រីស្រក់ទឹកភ្នែកយ៉ាងក្ដៅក្រហាយ នាងនិយាយទាំងខ្សឹកខ្សួល :

- អ្នកណាឱបលោកឯង ? ដកយកខ្នើយឱបចេញចង់ចំណេញសម្បើមម្ល៉េះ ?

- មិនចង់ចំណេញទេ ចង់ស្រឡាញ់តែម្ដងហ្នឹងណា៎ !

- ឥឡូវមិនបាច់និយាយច្រើនទេ លែងខ្ញុំភ្លាមទៅ ខ្ញុំឈប់នៅជាមួយលោកឯងទៀតហើយ !

- អូនមិនស្ដាយទេឬ ?

- ថាឲ្យលែងខ្ញុំ !

- កុំចង់ឈ្នះបងទៀត មិនអាចទៅរួចទេទោះជាអូនខំរើក៏ដោយក៏បងមិនលែងអូនដែរ ! បងប្រាប់ឲ្យដឹងទៅបងមិនដែលចេះអង្វរអ្នកណាទាល់តែសោះ ទើបតែអូនម្នាក់គត់ដែលបងចេះអង្វរ អូនត្រូវតែអង្វរលួងលោមចិត្តបងវិញបានត្រូវ !

- លោកបំពានសិទ្ធិខ្ញុំខ្លាំងម្ល៉េះ ?

- អូនឯងនេះចិត្តរឹងណាស់ យ៉ាងម៉េចព្រមអង្វរបងទេ ?

- អង្វរហើយ សូមលោកលែងខ្ញុំទៅ ខ្ញុំចុះចាញ់លោកហើយ !

- បើចុះចាញ់ត្រូវស្តាប់បងណា៎ ! បងថាម៉េចអូនត្រូវធ្វើតាមបងឮទេ ?

- ទេ...អី...

- គ្មានទេ គ្មានអីទេ ចាប់ពីពេលនេះទៅអូនត្រូវឈប់ប្រើពាក្យលោក ហើយឈប់ងរង៉ក់ ត្រូវនិយាយតាមបងថា " លែងអូនទៅបងសុជាតិ អូនព្រមរៀបការជាមួយនឹងបងហើយ " ថាភ្លាមទៅ !

- កុំតំរាមខ្ញុំពេក ខ្ញុំមិនចេះថាតាមលោកឯងទេ !

- បើមិនថាក៏ជាសិទ្ធិរបស់អូនដែរ តែបងមានសិទ្ធិព្រោះបងជាប្តីរបស់អូន នរណាក៏គេដឹងឮអស់ទៅហើយដែរ ជាពិសេសគឺសំបុត្រអាពាហ៍ពិពាហ៍នោះអី ! ប្រាប់ឲ្យដឹងណា៎បងខំទប់មួយយប់ហើយ !

មាណវីទ្រាំមិនបានសើចឲ្យរអឹក នាងអាណិតគេណាស់តែចិត្តចង់ឈ្នះត្រូវមកចាញ់គេបាត់ទៅហើយ !

- លែងអូនទៅបងសុជាតិ...អី...អូននិយាយមិនកើតទៀតទេ

សម្តីដ៏ទន់ភ្លន់របស់ស្រីធ្វើឲ្យគេរឹតតែឱបនាងខ្លាំងឡើង អ្នកប្រុសទាញប្រាណស្រីបែរមកគេ ហើយជូតទឹកភ្នែកឲ្យនាងទាំងញញឹមជាប់ ។

- អូនដឹងទេពេលដែលបងបូរីផ្ញើសំបុត្រការគាត់មកអញ្ជើញយើងឲ្យទៅញ៉ាំការនោះ បងអាណិតអូនណាស់ តែបងមិនហ៊ានប្រាប់ឲ្យអូនដឹង រួចរឿងចុះកាសែតទៀតបងរឹតតែអាណិតអូនទ្វេឡើង តែពេលនេះអូនព្រមទទួលបងហើយ បងសប្បាយចិត្តណាស់ !

ស្រស់ស្រីនៅស្ងៀមអាចបញ្ជាក់ឲ្យដឹងថា ទំហំចិត្តស្រឡាញ់របស់នាងក៏មិនខុសពីគេដែរ ។

ជាច្រើនថ្ងៃកន្លងទៅ តាមការស្រាវជ្រាវរបស់ក្រសួងមានសមត្ថកិច្ចរួមជាមួយនឹងអ្នកកាសែតយើងមួយចំនួន ដែលជាមិត្តភក្តិរបស់បូរី អ្នកស្រីគន្ធា លោកប៊ុន លោកស្រីសំអឿន ជាម្តាយចុងរបស់ម៉ូលីយ៉ា ត្រូវចាប់បញ្ជូនទៅពន្ធនាគារដាក់ទោសតាមច្បាប់កំណត់ ។

ចំណែកវ៉ាវីកូនក្រមុំអ្នកស្រីសំអឿន ត្រូវបញ្ជូនឲ្យទៅនៅជាមួយនឹងជីដូននាងវិញ ហើយលោកចំរើនជាឪពុករបស់ម៉ូលីយ៉ា ត្រូវបានបូរីយកទៅនៅផ្ទះគេ រង់ចាំទទួលការស្តីដណ្តឹងពីសុជាតិដើម្បីរៀបចំការអ្នកទាំងពីរឲ្យពេញមុខពេញមាត់ ។

ក្រោមពន្លឺដ៏ស្រទន់នៃអគ្គិសនី ស្រស់ស្រីនាងគេងកើយដៃប្តីយ៉ាងមានសេចក្តីសុខ កែវភ្នែកស្រីខំសម្លឹងមើលទៅគេ ថានេះហើយជាសុភមង្គលពិតរបស់នាង ដែលស្រីតែងតែនឹកគិតថាគ្មានអ្នកណាល្អជាងប្តីរបស់នាងនេះទេ ! សេចក្តីស្នេហាផ្អែមល្ហែមយ៉ាងមានន័យបាន

ចូលមកបបោសអង្អែលដួងចិត្តស្រី ឲ្យទោរទន់ទៅតាមជំនោរនៃវាយោ បក់មកតាមស្នាបព្រិលបង្ហួចពិតជាត្រជាក់អ្វីម្ល៉េះទេ នេះហើយជាស្នេហាពិតដែលជារសជាតិជីវិតរបស់ស្រី បានហែលឆ្លងកាត់នាពេលកន្លងមកមិនអាចនឹងវិលទៅរកភាពជូរចត់បានទៀតឡើយ ។

03-06-2012

**ចប់ដោយបរិបូណ៌**

Love ខ្មែរ
www.lovekhmer.com

ស៊ី គីមសៀង

រូបរួម